# រៀបចំដំណើរជីវិត

មនុស្សយើងនេះ ដែលនឹងអាចមាននូវសេចក្ដីសុខយ៉ាងពិតប្រាកដទៅបាននោះ គឺត្រូវមានដំណើរជីវិតយ៉ាងត្រឹមត្រូវ ពោលគឺ ត្រូវបដិបត្តិឱ្យបានត្រឹមត្រូវចំពោះជីវិតរបស់ខ្លួន និងត្រូវបដិបត្តិឱ្យបានត្រឹមត្រូវចំពោះអ្វីៗដែលមាននៅជុំវិញខ្លួន ទាំងផ្នែកសង្គមមនុស្សសត្វ ទាំងផ្នែកវត្ថុ ទាំងផ្នែកធម្មជាតិ ។

ដំណើរជីវិតរបស់មនុស្សយើង គឺការងារផ្សេងៗដែលសម្ដែងចេញតាមផ្លូវកាយខ្លះ ផ្លូវវាចាខ្លះ និងដែលមិនបានសម្ដែងចេញមកខាងក្រៅ តែធ្វើការខាងក្នុងដែលជាការងាររបស់ចិត្តខ្លះ និយាយឱ្យងាយមក គឺការធ្វើ ការនិយាយ និងការគិត ។ បុគ្គលដែលធ្វើកម្មទាំង ៣ យ៉ាងនេះបានត្រឹមត្រូវល្អ រមែងមានដំណើរជីវិតប្រព្រឹត្តទៅបានយ៉ាងប្រពៃ ។ ចេះធ្វើ ចេះនិយាយ ចេះគិត ជីវិតរុងរឿង ។

ដំណើរជីវិតមួយផ្នែកទៀត គឺការទទួលដឹងអារម្មណ៍ និងការសោយរសនៃអារម្មណ៍តាមទ្វារទាំង ៦ ។ បើការទទួលនូវ





អារម្មណ៍ប្រព្រឹត្តទៅដោយការស្រឡាញ់ ឬស្អប់ នេះជាប្រភពនៃបញ្ហា តែបើទទួលដោយបញ្ញាដឹងតាមសេចក្ដីពិត ឬដឹងទៅតាមហេតុផល ដំណើរជីវិតរមែងរួចផុតពីបញ្ហា ប្រព្រឹត្តទៅដោយសេចក្ដីសុខស្ងប់ ។

ផ្នែកមួយផ្សេងទៀតនៃដំណើរជីវិត គឺការចូលទៅទាក់ទងជាមួយនឹងរបស់ទាំងឡាយ ដើម្បីកាន់យកនូវប្រយោជន៍អំពីរបស់នោះ ។ ការសេពគប់ ការបរិភោគ ការមើល ការអាន និងការស្ដាប់ជាដើម នេះគឺជាដំណើរជីវិតដែលមានទំនាក់ទំនងជាមួយសង្គមមនុស្សសត្វ និងវត្ថុ ។ ការគប់រកក្ដី ការបរិភោគក្ដី ការប្រើប្រាស់ក្ដី បើមិនអាស្រ័យការឆ្លាតទេ វាអាចធ្វើឱ្យជីវិតលិចលង់ទៅបាន តែបើឆ្លាត ដំណើរជីវិតនឹងដល់គោលដៅ ។ ទឹកអាចធ្វើឱ្យទូកដល់គោលដៅ តែក៏អាចឱ្យទូកលិចបានដែរ ។

សមុទ្រតែងមានរលក ជីវិតតែងមានបញ្ហា តែបញ្ញាអាចដោះស្រាយនូវបញ្ហាបាន ម្យ៉ាងទៀត អ្នកមានបញ្ញារមែងរៀបចំដំណើរជីវិតឱ្យគេចផុតពីបញ្ហា ហើយបានជួបប្រសព្វនូវផលសម្រេចក្នុងដំណើរជីវិតរបស់ខ្លួន រស់នៅដោយប្រាសចាកទុក្ខកង្វល់ ។

ដំណើរជីវិតដ៏ត្រឹមត្រូវ និងបានសម្រេចនូវផលល្អនោះ

រមែងមានការប្រព្រឹត្តទៅដោយល្អច្រើនផ្នែក ពោលដោយសរុបគឺ

១.ក្នុងផ្នែកនៃការធ្វើកម្ម បានដល់ ការពូកែគិត ការពូកែនិយាយ និងការពូកែធ្វើទាំងដែលជាសុចរិតទៀតផង ។

២.ក្នុងផ្នែកនៃការទទួលដឹង បានដល់ ការពូកែមើល ការពូកែស្តាប់ជាដើម ។

៣.ក្នុងផ្នែកទំនាក់ទំនងដ៏ប្រសើរជាមួយអ្វីៗដែលនៅជុំវិញខ្លួន បានដល់ ការពូកែបរិភោគ ការពូកែប្រើប្រាស់ និងការពូកែសេពគប់ ឬគប់រក ។

ពាក្យថា « ការពូកែ » ក្នុងទីនេះ គឺសំដៅដល់ភាពឆ្លាតឈ្លាសប្រព្រឹត្តទៅជាកុសល និងច្រើនដោយសតិសម្បជញ្ញៈ ។

៤.មានបញ្ញាសម្រាប់ដោះស្រាយនូវបញ្ហា និងចេះរៀបចំដំណើរជីវិតបញ្ចៀសពីបញ្ហា ។

មនុស្សឆ្លាតគឺមនុស្សដែលចេះជួយខ្លួនឯងឱ្យរួចពីបាបកម្ម។

ការបដិបត្តិត្រឹមត្រូវនៅក្នុងផ្នែកផ្សេងៗនៃដំណើរជីវិត ធ្វើឱ្យជីវិតមានដំណើររៀបរយល្អ និងមានរស្មីភ្លឺថ្លា ។ សេចក្តីល្អជារស្មីនៃជីវិត ។

បណ្តាការបដិបត្តិត្រឹមត្រូវនៅក្នុងផ្នែកផ្សេងៗ នៃជីវិតនេះ អាចនិយាយសរុបរួមបានថា **ការពូកែគិត** ។ ការពូកែគិតនេះ



ជាសម្បត្តិមួយដ៏សំខាន់ក្រៃលែងក្នុងដំណើរជីវិត ។

ការពូកែគិត គ្រប់គ្រងនូវការបដិបត្តិឱ្យប្រព្រឹត្តទៅបានត្រឹមត្រូវគ្រប់ផ្នែកទាំងអស់ ។

ពាក្យថា ការពូកែគិត បានដល់គំនិតល្អ ឆ្លាតនិងត្រឹមត្រូវម៉្លោះហើយ អ្វីៗដែលប្រព្រឹត្តទៅតាមគំនិតដូច្នេះ ក៏រមែងរៀបរយរាបសា ល្អត្រឹមត្រូវទៅផងដែរ ។

ការពូកែគិត ឬការចេះគិត មានការប្រកបដោយវិធីគិតផ្សេងៗ ច្រើនបែប ច្រើនយ៉ាង ។ ការហ្វឹកហាត់អប់រំចម្រើននូវគំនិតឱ្យពូកែគិត គឺជាការហ្វឹកហាត់កសាងខ្លួនហ្នឹងឯង ។

ការពូកែគិតគឺជា **យោនិសោមនសិការ** ប្រែថា ចេះធ្វើទុកក្នុងចិត្តដោយល្អត្រូវទៅតាមហេតុផល ។

☆☆☆

# សេចក្តីសំខាន់របស់យោនិសោមនសិការ

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈

« បិដកលេខ ៣៧, ទំព័រ ៦៤, សំយុត្តនិកាយ, មហាវារវគ្គ »

ម្នាលភិក្ខុទាំងឡាយ ការរះឡើងនៃអរុណ នេះជាប្រធាន នេះជាបុព្វនិមិត្តនៃព្រះអាទិត្យដែលរះឡើង ។ ម្នាលភិក្ខុទាំងឡាយ ការបរិបូណ៌ដោយយោនិសោមនសិការ នេះជាប្រធាន នេះជាបុព្វនិមិត្ត ប្រព្រឹត្តទៅដើម្បីញុំាងអរិយមគ្គប្រកបដោយអង្គ ៨ ឱ្យកើតឡើងដល់ភិក្ខុ ដោយប្រការយ៉ាងនេះដែរ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនេះជាទីសង្ឃឹមរបស់ភិក្ខុដែលបរិបូណ៌ដោយយោនិសោមនសិការ ភិក្ខុនោះនឹងចម្រើនអរិយមគ្គប្រកបដោយអង្គ ៨ ឱ្យច្រើនឡើង ។

« បិដកលេខ ៣៧, ទំព័រ ២៣៥ »

ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយឯណានីមួយ ជាកុសល ជាចំណែកនៃកុសល ជាបក្ខពួកនៃកុសល ធម៌ទាំងអស់នោះ មានយោនិសោមនសិការជាឫសគល់ មានយោនិសោមនសិការជាទីប្រជុំចុះ យោនិសោមនសិការប្រាកដជាកំពូលនៃធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនោះនឹងប្រាកដដល់ភិក្ខុដែលបរិបូណ៌



ដោយយោនិសោមនសិការ ភិក្ខុនោះនឹងចម្រើននូវពោជ្ឈង្គទាំង៧ នឹងធ្វើឱ្យច្រើននូវពោជ្ឈង្គទាំង ៧ ។

« បិដកលេខ ៣៧, ទំព័រ ១៧០ »

ម្នាលភិក្ខុទាំងឡាយ កាយនេះរមែងតាំងនៅដោយសារអាហារ អាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហារតាំងនៅមិនបានទេ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ នីវរណៈទាំង៥ រមែងតាំងនៅដោយសារអាហារ អាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហាររមែងតាំងនៅមិនបានឡើយក៏យ៉ាងនោះដែរ ។

ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារដែលញុំាងកាមច្ឆន្ទៈមិនទាន់កើតឡើង ឱ្យកើតឡើង ឬញុំាងកាមច្ឆន្ទៈដែលកើតឡើងហើយ ឱ្យរឹតតែកើតធំទូលាយឡើង ។ ម្នាលភិក្ខុទាំងឡាយ សុភនិមិត្តរមែងមាន ការធ្វើឱ្យច្រើននូវអយោនិសោមនសិការក្នុងសុភនិមិត្តនោះ នេះជាអាហារដែលញុំាងកាមច្ឆន្ទៈមិនទាន់កើតឡើង ឱ្យកើតឡើង ឬញុំាងកាមច្ឆន្ទៈដែលកើតឡើងហើយ ឱ្យរឹតតែកើតធំទូលាយទៅ ។

ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារដែលញុំាងព្យាបាទមិនទាន់កើតឡើង ឱ្យកើតឡើង ឬញុំាងព្យាបាទដែលកើតឡើងហើយ

ឱ្យរីតតែកើតធំទូលាយទៅ ។ ម្នាលភិក្ខុទាំងឡាយ បដិឃនិមិត្ត រមែងមាន ការធ្វើឱ្យច្រើននូវអយោនិសោមនសិការក្នុងបដិឃ-និមិត្តនោះ នេះជាអាហារដែលញ៉ាំងព្យាបាទមិនទាន់កើតឡើង ឱ្យកើតឡើង ឬញ៉ាំងព្យាបាទដែលកើតឡើងហើយ ឱ្យរីតតែកើតធំទូលាយទៅ ។

ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារដែលញ៉ាំងថីនមិទ្ធមិនទាន់កើតឡើង ឱ្យកើតឡើង ឬញ៉ាំងថីនមិទ្ធដែលកើតឡើងហើយ ឱ្យរីតតែកើតធំទូលាយទៅ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីធុញទ្រាន់ សេចក្តីខ្ជិល ការមិនពត់កាយ ការពុលបាយ ការរួញរាចិត្តរមែងមាន ការធ្វើឱ្យច្រើននូវអយោនិសោមនសិការក្នុងភាវៈទាំងអស់នោះ នេះជាអាហារដែលញ៉ាំងថីនមិទ្ធមិនទាន់កើតឡើង ឱ្យកើតឡើង ឬញ៉ាំងថីនមិទ្ធដែលកើតឡើងហើយ ឱ្យរីតតែកើតធំទូលាយទៅ ។

ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារដែលញ៉ាំងឧទ្ធច្ចកុក្កុច្ចមិនទាន់កើតឡើង ឱ្យកើតឡើង ឬញ៉ាំងឧទ្ធច្ចកុក្កុច្ចដែលកើតឡើងហើយ ឱ្យរីតតែកើតធំទូលាយទៅ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីមិនស្ងប់ចិត្តរមែងមាន ការធ្វើឱ្យច្រើននូវអយោនិសោមនសិការក្នុងសេចក្តីមិនស្ងប់ចិត្តនោះ នេះជាអាហារដែលញ៉ាំងឧទ្ធច្ចកុក្កុច្ច



មិនទាន់កើតឡើង ឱ្យកើតឡើង ឬញ៉ាំងឧទ្ធច្ចកុក្កុច្ចដែលកើតឡើងហើយ ឱ្យរីតតែកើតធំទូលាយទៅ ។

ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារដែលញ៉ាំងវិចិកិច្ឆាមិនទាន់កើតឡើង ឱ្យកើតឡើង ឬញ៉ាំងវិចិកិច្ឆាដែលកើតឡើងហើយ ឱ្យរីតតែកើតធំទូលាយទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាទីតាំងនៃវិចិកិច្ឆារមែងមាន ( បានដល់អារម្មណ៍របស់វិចិកិច្ឆា ) ការធ្វើឱ្យច្រើននូវអយោនិសោមនសិការក្នុងធម៌ទាំងនោះ (ធម៌ដែលជាទីតាំងនៃវិចិកិច្ឆា ) នេះជាអាហារដែលញ៉ាំងវិចិកិច្ឆា មិនទាន់កើតឡើង ឱ្យកើតឡើង ឬញ៉ាំងវិចិកិច្ឆាដែលកើតឡើងហើយ ឱ្យរីតតែកើតធំទូលាយទៅ ។

ម្នាលភិក្ខុទាំងឡាយ កាយនេះរមែងតាំងនៅព្រោះអាហារ អាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហារតាំងនៅមិនបានទេ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ នីវរណៈទាំង ៥ នេះឯង រមែងតាំងនៅព្រោះអាហារ អាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហាររមែងតាំងនៅមិនបានឡើយក៏យ៉ាងនោះដែរ ។

ម្នាលភិក្ខុទាំងឡាយ កាយនេះរមែងតាំងនៅព្រោះអាហារ អាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហារតាំងនៅមិន

បានទេ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយពោជ្ឈង្គទាំង ៧ រមែងតាំងនៅព្រោះអាហារ អាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហាររមែងតាំងនៅមិនបានឡើយ ក៏យ៉ាងនោះដែរ ។

ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារនាំសតិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឱ្យកើតឡើង ឬនាំសតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឱ្យរីតតែចម្រើនពេញលេញឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាទីតាំងនៃសតិសម្ពោជ្ឈង្គរមែងមាន (បានដល់អារម្មណ៍របស់សតិ) ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងធម៌ទាំងនោះ ( ធម៌ដែលជាទីតាំងនៃសតិសម្ពោជ្ឈង្គ ) នេះជាអាហារនាំសតិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឱ្យកើតឡើង ឬនាំសតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឱ្យរីតតែចម្រើនពេញ-លេញឡើងបាន ។

ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារនាំធម្មវិចយសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឱ្យកើតឡើង ឬនាំធម្មវិចយសម្ពោជ្ឈង្គដែលកើតឡើងហើយ ឱ្យរីតតែចម្រើនពេញលេញឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាកុសលនិងអកុសល ធម៌ដែលប្រកបដោយទោសនិងមិនមានទោស ធម៌ថោកទាបនិងឧត្តម ធម៌ជាចំណែកខុសគ្នា គឺធម៌ខ្មៅនិងធម៌ស រមែងមាន ការធ្វើឱ្យ



ច្រើននូវយោនិសោមនសិការក្នុងធម៌ទាំងនោះ នេះជាអាហារនាំធម្មវិចយសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឱ្យកើតឡើង ឬនាំធម្មវិចយសម្ពោជ្ឈង្គដែលកើតឡើងហើយ ឱ្យរីតតែចម្រើនពេញ-លេញឡើងបាន ។

ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារនាំវីរិយសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឱ្យកើតឡើង ឬនាំវីរិយសម្ពោជ្ឈង្គដែលកើតឡើងហើយ ឱ្យរីតតែចម្រើនពេញលេញឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ ធាតុគឺការផ្ដួចផ្ដើម ធាតុគឺសេចក្ដីព្យាយាម ធាតុគឺសេចក្ដីខ្នះខ្នែងប្រឹងប្រែង រមែងមាន ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងធាតុទាំងនោះ នេះជាអាហារនាំវីរិយ-សម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឱ្យកើតឡើង ឬនាំវីរិយ-សម្ពោជ្ឈង្គដែលកើតឡើងហើយ ឱ្យរីតតែចម្រើនពេញលេញឡើងបាន ។

ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារនាំបីតិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឱ្យកើតឡើង ឬនាំបីតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឱ្យរីតតែចម្រើនពេញលេញឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីតាំងនៃបីតិសម្ពោជ្ឈង្គ រមែងមាន ( បានដល់អារម្មណ៍របស់បីតិសម្ពោជ្ឈង្គ ) ការធ្វើឱ្យច្រើននូវយោនិសោ-

មនសិការក្នុងធម៌ទាំងនោះ (ធម៌ដែលជាទីតាំងនៃបីតិសម្ពោជ្ឈង្គ) នេះជាអាហារនាំបីតិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឱ្យកើតឡើង ឬនាំបីតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឱ្យរីតតែចម្រើនពេញលេញឡើងបាន ។

ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារនាំបស្សទ្ធិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឱ្យកើតឡើង ឬនាំបស្សទ្ធិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឱ្យរីតតែចម្រើនពេញលេញឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីស្ងប់កាយ សេចក្ដីស្ងប់ចិត្ត រមែងមាន ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងសេចក្ដីស្ងប់ទាំងនោះ នេះជាអាហារនាំបស្សទ្ធិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឱ្យកើតឡើង ឬនាំបស្សទ្ធិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឱ្យរីតតែចម្រើនពេញលេញឡើងបាន ។

ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារនាំសមាធិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឱ្យកើតឡើង ឬនាំសមាធិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឱ្យរីតតែចម្រើនពេញលេញឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ និមិត្តនៃការតាំងចិត្តមាំ និមិត្តនៃការមិនរាយមាយ រមែងមាន ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងនិមិត្តទាំងនោះ នេះជាអាហារនាំសមាធិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង





ឱ្យកើតឡើង ឬនាំសមាធិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឱ្យរីតតែចម្រើនពេញលេញឡើងបាន ។

ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារនាំឧបេក្ខាសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឱ្យកើតឡើង ឬនាំឧបេក្ខាសម្ពោជ្ឈង្គដែលកើតឡើងហើយ ឱ្យរីតតែចម្រើនពេញលេញឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គ រមែងមាន (បានដល់អារម្មណ៍របស់ឧបេក្ខាសម្ពោជ្ឈង្គ) ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងធម៌ទាំងនោះ (ធម៌ជាទីតាំងនៃឧបេក្ខា-សម្ពោជ្ឈង្គ) នេះជាអាហារនាំឧបេក្ខាសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឱ្យកើតឡើង ឬនាំឧបេក្ខាសម្ពោជ្ឈង្គដែលកើតឡើងហើយ ឱ្យរីតតែចម្រើនពេញលេញឡើងបាន ។

ម្នាលភិក្ខុទាំងឡាយ កាយនេះរមែងតាំងនៅព្រោះអាហារ អាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហារតាំងនៅមិនបានទេ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះឯង រមែងតាំងនៅព្រោះអាហារ អាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហាររមែងតាំងនៅមិនបានឡើយ ក៏យ៉ាងនោះដែរ ។

« បិដកលេខ ៤០ អង្គុត្តរនិកាយ, ឯកនិបាត, ទំព័រ ២៥ »

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញនូវសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកកុសលធម៌មិនទាន់កើតឡើង ឱ្យកើតឡើងបានក្តី ពួកអកុសលធម៌ដែលកើតឡើងហើយឱ្យសាបសូន្យទៅក្តី ដូចជាយោនិសោមនសិការនេះសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមាននូវយោនិសោមនសិការ ពួកកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងផង ពួកអកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

« បិដកលេខ ៤០ , ទំព័រ ៣២ »

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញនូវសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដ៏ធំធេង ដូចជាយោនិសោមនសិការនេះសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ មានតែយោនិសោមនសិការនេះប៉ុណ្ណោះ ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដ៏ធំធេង ។

« បិដកលេខ ៤០ , ទំព័រ ៤១ »

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញនូវសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឋិតនៅ





មិនវិនាស មិនអន្តរធាននូវព្រះសទ្ធម្ម ដូចជាយោនិសោមនសិការនេះសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ មានតែយោនិសោមនសិការនេះប៉ុណ្ណោះ ទើបប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធាននូវព្រះសទ្ធម្ម ។

« បិដកលេខ ៤០ , ទំព័រ ៣៦ និង ៣៧ »

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជា **អង្គខាងក្នុង** សូម្បីតែអង្គ ១ ដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ដ៏ធំធេង ដូចជាយោនិសោមនសិការនេះសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ មានតែយោនិសោមនសិការនេះប៉ុណ្ណោះ ទើបប្រព្រឹត្តទៅដើម្បីប្រយោជន៍ដ៏ធំធេង ។

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជា **អង្គខាងក្រៅ** សូម្បីតែអង្គ ១ ដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ដ៏ធំធេង ដូចជាការមាននូវកល្យាណមិត្តនេះសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ មានតែការមាននូវកល្យាណមិត្តនេះប៉ុណ្ណោះ ទើបប្រព្រឹត្តទៅដើម្បីប្រយោជន៍ដ៏ធំធេង ។

☆ ☆ ☆

# អត្ថន័យរបស់យោនិសោមនសិការ

**យោនិសោមនសិការ** ប្រែថា ការធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនង ឬត្រូវតាមហេតុ ត្រូវតាមសេចក្តីពិត បានដល់ការយកចិត្តទុកដាក់នឹកគិតពិចារណា ឱ្យបានត្រឹមត្រូវទៅតាមហេតុផល ។

គិតដោយវិធីត្រឹមត្រូវ គិតមានរបៀបរៀបរយ គិតតាមហេតុផល និងគិតហើយកុសលធម៌ក៏កើតឡើង ការគិតពិចារណាដ៏ត្រឹមត្រូវដូច្នេះឯង គឺជាយោនិសោមនសិការ ។ ពិតមែនតែយោនិសោមនសិការពូកែគិត ប៉ុន្តែចំពោះបុគ្គលដែលខ្វះនូវបារមីដើម្បីត្រាស់ដឹងដោយខ្លួនឯង គឺចាំបាច់ត្រូវអាស្រ័យកល្យាណមិត្ត ព្រោះកល្យាណមិត្តជួយនិយាយពន្យល់ប្រាប់ហេតុផល ដែលជាបរតោឃោសៈផ្នែកល្អ ។

ប្រសិនបើមិនបានស្តាប់ មិនបានសិក្សានូវព្រះពុទ្ធវចនៈទេ មនុស្សយើងពិតជាមិនអាចចេះគិតដោយខ្លួនឯង នូវរូបធម៌និងនាមធម៌ ដែលថាមិនគួរប្រកាន់ថាជារបស់មាំមួន មានការកើតរលត់ មិនមានអត្តាតួខ្លួនជាដើមនោះឡើយ ។



អំណាចនៃ **បរតោឃោសៈ** (ពាក្យឃោសនារបស់អ្នកដទៃ ) មានកម្លាំងខ្លាំងក្លាណាស់មនុស្សរាប់លាននាក់ មានការយល់ថា លោកនេះគឺព្រះអាទិទេពជាអ្នកបង្កើត នេះព្រោះមកអំពីពាក្យឃោសនាដែលជាអង្គប្រកបខាងក្រៅហ្នឹងឯង ។

ដូច្នេះ ដើម្បីការរួចផុតចាកទុក្ខ មនុស្សយើងត្រូវសិក្សានូវព្រះពុទ្ធភាសិត ដើម្បីឱ្យបានជាឧបការៈដល់យោនិសោមនសិការ។ យោនិសោមនសិការ គឺមានការគិតត្រឹមត្រូវ ជាអង្គធម៌ដ៏សំខាន់ក្រៃលែងក្នុងការសិក្សា ឬក្នុងការកសាងខ្លួន ។ ជាចំណុចខ្លឹមសារនៃការចម្រើនបញ្ញា ។ ជាអង្គធម៌ដែលចាំបាច់សម្រាប់ការសាងជីវិតឱ្យរុងរឿងភ្លឺស្វាង សម្រាប់ដោះស្រាយបញ្ហាក្នុងជីវិត និងសម្រាប់ឱ្យពឹងខ្លួនឯងបាន ។

ការសិក្សានូវព្រះពុទ្ធភាសិតនាំមកនូវសទ្ធាផង យោនិសោ-មនសិការផង ដូច្នេះរមែងរួចផុតអំពីការភ្ញាក់ផ្អើលផ្សេងៗ មានមង្គលភ្ញាក់ផ្អើលជាដើម សម្រេចបាននូវសម្មាទិដ្ឋិដែលជាមង្គលដ៏ឧត្តម។

វិធីគិតពិចារណាដែលជាយោនិសោមនសិការ ប្រមូលជាបែបជាក្រុមធំៗ មានដូចតទៅ :

១.វិធីគិតពិចារណា តាមបែបការស្រាវជ្រាវរាវរកហេតុរកបច្ច័យ

២.វិធីគិតពិចារណា តាមបែបការរំលែកចែកបំបែកការប្រជុំរួម

៣.វិធីគិតពិចារណា តាមបែបត្រៃលក្ខណ៍

៤.វិធីគិតពិចារណា តាមបែបអរិយសច្ច

៥.វិធីគិតពិចារណាតាមបែបដំណើរការបដិបត្តិនិងទិសដៅ

៦.វិធីគិតពិចារណា តាមបែបការឃើញគុណទោសនិងការរលាស់ចោល

៧.វិធីគិតពិចារណា តាមបែបការដឹងនូវរបស់ពិតនិងរបស់ក្លែងក្លាយ

៨.វិធីគិតពិចារណា តាមបែបការញ៉ាំងនូវគុណធម៌ឱ្យចម្រើន

៩.វិធីគិតពិចារណា តាមបែបរស់នៅជាមួយនឹងបច្ចុប្បន្ន

១០.វិធីគិតពិចារណា តាមបែបការចែកធម៌ ។

☆☆☆





## ១.វិធីគិតពិចារណាតាមបែបការស្រាវជ្រាវរាវរកហេតុរកបច្ច័យ

« បិដកលេខ ៣១ , ទំព័រ ២០ »

ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតនៅជាពោធិសត្វមិនទាន់បានត្រាស់ដឹងនៅឡើយ ក្នុងកាលមុនអំពីការត្រាស់ដឹង តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ឱហ្ន៎ សត្វលោកនេះ ដល់នូវសេចក្តីលំបាកណាស់ តែងកើត ចាស់ ស្លាប់ ច្យុត និងបដិសន្ធិ ថែមទាំងមិនដឹងច្បាស់អំពីការរលាស់ចោលនូវសេចក្តីទុក្ខ គឺ ជរា និងមរណៈនេះទៀតផង ។ កាលណាទៅហ្ន៎ ទើបការរលាស់ចោលនូវសេចក្តីទុក្ខ គឺជរា និងមរណៈនេះនឹងប្រាកដឡើងបាន ។

ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎កើតមាន ទើបជរានិងមរណៈកើតមាន ជរានិងមរណៈកើតមានព្រោះអ្វីជាបច្ច័យ ។

ម្នាលភិក្ខុទាំងឡាយ តថាគតនោះក៏បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះ **យោនិសោមនសិការ** ថា កាលបើជាតិកើតមាន ជរា និងមរណៈក៏កើតមាន ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ។

ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះ ថា កាលអ្វីហ្ន៎កើតមាន ទើបជាតិកើតមាន ។ល។ ភព... ឧបាទាន... តណ្ហា... វេទនា... ផស្ស:... សឡាយតនៈ... នាមរូប... វិញ្ញាណ... កាលអ្វីហ្ន៎កើតមានទើបសង្ខារទាំងឡាយកើតមាន សង្ខារទាំងឡាយកើតមាន ព្រោះអ្វីជាបច្ច័យ ។

ម្នាលភិក្ខុទាំងឡាយ តថាគតនោះ ក៏បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះ **យោនិសោមនសិការ** ថា កាលបើអវិជ្ជាកើតមាន សង្ខារទាំងឡាយក៏កើតមាន សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។

ព្រោះហេតុដូច្នេះ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ។ល។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់បានស្តាប់ក្នុងកាលមុនថា **សមុទយោ សមុទយោតិ** ការកើតឡើងព្រម ការកើតឡើងព្រម ដូច្នេះសោះ ។

ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះ



ថា កាលអ្វីហ្ន៎មិនមាន ទើបជរានិងមរណៈមិនមាន ការរលត់នៃជរានិងមរណៈ ព្រោះការរលត់នៃអ្វី ។

ម្នាលភិក្ខុទាំងឡាយ តថាគតនោះ ក៏បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះ **យោនិសោមនសិការ** ថា កាលបើជាតិមិនមាន ជរានិងមរណៈក៏មិនមាន ការរលត់នៃជរានិងមរណៈ ព្រោះការរលត់នៃជាតិ ។

ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះ ថា កាលអ្វីហ្ន៎មិនមាន ទើបជាតិមិនមាន ។ល។ ភព... ឧបាទាន... តណ្ហា... វេទនា... ផស្ស:... សឡាយតនៈ... នាមរូប... វិញ្ញាណ... កាលអ្វីហ្ន៎មិនមានទើបសង្ខារទាំងឡាយមិនមាន ការរលត់នៃសង្ខារ ព្រោះការរលត់នៃអ្វី ។

ម្នាលភិក្ខុទាំងឡាយ តថាគតនោះ ក៏បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះ **យោនិសោមនសិការ** ថា កាលបើអវិជ្ជាមិនមាន សង្ខារទាំងឡាយក៏មិនមាន ការរលត់នៃសង្ខារ ព្រោះការរលត់នៃអវិជ្ជា ។

ព្រោះហេតុដូច្នេះ ការរលត់នៃសង្ខារ ព្រោះការរលត់នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់សង្ខារ ។ល។ ការរលត់នៃកងទុក្ខទាំងនុ៎ះ រមែងមានយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់បានស្តាប់ក្នុងកាលមុនថា **និរោធោ និរោធោតិ** ការរលត់ ការរលត់ ដូច្នេះ សោះ ។

☆ ☆ ☆





## ២-វិធីគិតពិចារណាតាមបែបការរំលែក ចែកការប្រជុំរួម

« បិដកលេខ ៣០ , ទំព័រ ២០ »

## វជិរាសូត្រ

ខ្ញុំបានស្តាប់មកយ៉ាងនេះ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។

គ្រានោះ វជិរាភិក្ខុនី ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកអំពីបិណ្ឌបាតវិញក្នុងបច្ឆាភត្ត ក៏ដើរសំដៅទៅកាន់អន្ធវ័ន ដើម្បីសម្រាកក្នុងវេលាថ្ងៃ លុះចូលទៅដល់អន្ធវ័នហើយ ក៏អង្គុយសម្រាកក្នុងវេលាថ្ងៃក្រោមម្លប់ឈើមួយ ។

គ្រានោះមារមានចិត្តបាប មាននូវសេចក្តីប្រាថ្នាញុំាងភ័យសេចក្តីតក់ស្លុតនិងសេចក្តីព្រឺរោមឱ្យកើតឡើងដល់វជិរាភិក្ខុនី លុះចូលទៅដល់ហើយបានពោលគាថានឹងវជិរាភិក្ខុនីដោយសេចក្តីថា:

សត្វនេះ បុគ្គលណាតាក់តែងឡើង បុគ្គលអ្នកតាក់តែងសត្វឋិតនៅក្នុងទីណា សត្វកើតឡើងក្នុងទីណា សត្វរលត់ទៅក្នុងទីណា ?

លំដាប់នោះ វជិរាភិក្ខុនីមានសេចក្តីត្រិះរិះ យ៉ាងនេះថា អ្នកនេះជាអ្វីហ្ន៎ ជាមនុស្ស ឬជាអមនុស្ស មកពោលនូវគាថាដូច្នេះ ។ ទើបវជិរាភិក្ខុនីមានសេចក្តីដឹងថា នេះពិតជាមារមានចិត្តបាប ប្រាថ្នាញុាំងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឱ្យកើតឡើងដល់អាត្មាអញ មានប្រាថ្នាឱ្យអាត្មាអញឃ្លាតចាកសមាធិ បានជាពោលនូវគាថា ។

លំដាប់នោះវជិរាភិក្ខុនីដឹងច្បាស់ថា នេះជាមារមានចិត្តបាបហើយ ក៏បានពោលគាថាទាំងឡាយនឹងមារមានចិត្តបាបថា :

**កឹ នុ សត្តោតិ បច្ចេតិ មារ ទិដ្ឋិគតំ នុ តេ**
**សុទ្ធសង្ខារបុញ្ជោយំ នយិធ សត្តូបលព្ភតិ ។**

ម្នាលមារ ទិដ្ឋិរបស់អ្នកយល់ថា សត្វមែនឬ ? នេះជាគំនរនៃសង្ខារសុទ្ធ ក្នុងគំនរនៃសង្ខារនេះ អ្នករកសត្វមិនឃើញឡើយ។

**យថា ហិ អង្គសម្ភារា ហោតិ សទ្ទោ រថោ ឥតិ**
**ឯវំ ខន្ធេសុ សន្តេសុ ហោតិ សត្តោតិ សម្មុតិ ។**

ដូចសព្ទថា រថ ដូច្នេះ កើតឡើងបានព្រោះបរិបូណ៌ដោយអង្គ (មានកង់ទូកប្រែកជាដើម ) យ៉ាងណាមិញ កាលបើខន្ធមានហើយ ការសន្មតថា សត្វដូច្នេះក៏មាន យ៉ាងនោះឯង ។





**ទុក្ខមេវ ហិ សម្ភោតិ ទុក្ខំ តិដ្ឋតិ វេតិ ច**
**នាញ្ញត្រ ទុក្ខា សម្ភោតិ នាញ្ញត្រ ទុក្ខា និរុជ្ឈតីតិ។**

ដោយពិត មានតែទុក្ខទេដែលកើតឡើង មានតែទុក្ខទេដែលតាំងនៅ និងមានតែទុក្ខទេដែលផ្លាស់ប្តូរប្រែប្រួលទៅ ធម្មជាតិដទៃក្រៅពីទុក្ខមិនមានអ្វីកើត ធម្មជាតិដទៃក្រៅពីទុក្ខមិនមានអ្វីរលត់ ។

លំដាប់នោះ មារមានចិត្តបាបដឹងថា វជិរាភិក្ខុនីស្គាល់អញហើយ ក៏មានសេចក្តីទុក្ខ តូចចិត្ត បាត់អំពីទីនោះទៅ ។

## អដ្ឋកថាវជិរាសូត្រ

បទថា **នយិធ សត្តូបលព្ភតិ** មានសេចក្តីថា ក្នុងកងសង្ខារសុទ្ធនេះ ពោលដោយបរមត្ថ គឺមិនបានដល់នូវភាវៈជាសត្វឡើយ ។ បទថា **ខន្ធេសុ សន្តេសុ** ដោយសេចក្តីថា កាលខន្ធ ៥ នៅមាន លោកកំណត់យកដោយអាការនោះៗ ។ បទថា **សម្មុតិ** គឺគ្រាន់តែសមញ្ញា (ឈ្មោះនាម )ថាសត្វប៉ុណ្ណោះ ។ បទថា **ទុក្ខំ** បានដល់ទុក្ខគឺខន្ធ ៥ ។ បទថា **នាញ្ញត្រ ទុក្ខា** ដោយសេចក្តីថា ក្រៅអំពីទុក្ខ សភាវៈយ៉ាងដទៃមិនមានអ្វីកើត មិនមានអ្វីរលត់ ។

(ចប់អដ្ឋកថាវជិរាសូត្រ)

« បិដកលេខ ២១ , ទំព័រ ២១១ »

## មហាហត្ថិបទោបមសូត្រ

ម្នាលអ្នកដ៏មានអាយុទាំងឡាយ អាកាស គឺទីវាលដែលអាស្រ័យគ្រឿងឈើខ្លះ អាស្រ័យវល្លិសម្រាប់ចងខ្លះ អាស្រ័យដីសម្រាប់លាបខ្លះ អាស្រ័យស្បូវប្រក់ខ្លះ ផ្គុំជាមួយគ្នាហើយ ក៏រាប់ហៅបានថាជាផ្ទះ យ៉ាងណាមិញ ម្នាលអ្នកដ៏មានអាយុទាំងឡាយ អាកាសដែលអាស្រ័យឆ្អឹងខ្លះ អាស្រ័យសរសៃខ្លះ អាស្រ័យសាច់ខ្លះ អាស្រ័យស្បែកខ្លះ រួបរួមជាមួយគ្នាហើយ ទើបហៅបានថាជារូបដូច្នោះឯង ។

ម្នាលអ្នកដ៏មានអាយុទាំងឡាយ បើចក្ខុខាងក្នុងមិនសាបសូន្យទេ តែរូបទាំងឡាយខាងក្រៅមិនបានមកកាន់គន្លងនៃចក្ខុផង ការពិចារណាអារម្មណ៍ដែលកើតអំពីចក្ខុ និងរូបនោះមិនមានផង (គឺមិនមានបញ្ចទ្វារាវជ្ជនៈ ) ព្រោះហេតុដូច្នោះ ចំណែកនៃវិញ្ញាណដែលកើតអំពីចក្ខុនិងរូបនោះ ក៏មិនទាន់កើតប្រាកដឡើងដែរ ។

ម្នាលអ្នកដ៏មានអាយុទាំងឡាយ បើចក្ខុខាងក្នុងមិនសាបសូន្យទេ ហើយរូបទាំងឡាយជាខាងក្រៅក៏មកកាន់គន្លងនៃចក្ខុដែរ តែការពិចារណាអារម្មណ៍ដែលកើតអំពីចក្ខុ និងរូបនោះ





មិនមានទេ ចំណែកនៃវិញ្ញាណដែលកើតអំពីចក្ខុនិងរូបនោះ ក៏នៅតែមិនទាន់កើតប្រាកដនៅឡើយ ។

ម្នាលភិក្ខុទាំងឡាយ កាលណាបើចក្ខុខាងក្នុងមិនសាបសូន្យផង រូបទាំងឡាយជាខាងក្រៅមកកាន់គន្លងនៃចក្ខុផង ហើយការពិចារណាអារម្មណ៍ដែលកើតអំពីចក្ខុនិងរូបនោះ ក៏កើតមានផង ទើបចំណែកនៃវិញ្ញាណដែលកើតអំពីចក្ខុនិងរូបនោះ អាចកើតឡើងបាន ដោយប្រការដូច្នេះឯង ។

រូបណាដែលកើតជាមួយនឹងចក្ខុវិញ្ញាណ រូបនោះសង្គ្រោះចូលក្នុងរូបូបាទានក្ខន្ធ ។ វេទនាដែលកើតជាមួយនឹងចក្ខុវិញ្ញាណ វេទនានោះសង្គ្រោះចូលក្នុងវេទនូបាទានក្ខន្ធ ។ សញ្ញាណា ដែលកើតជាមួយនឹងចក្ខុវិញ្ញាណ សញ្ញានោះសង្គ្រោះចូលក្នុងសញ្ញូបាទានក្ខន្ធ ។ សង្ខារទាំងឡាយណាដែលកើតជាមួយនឹងចក្ខុវិញ្ញាណ សង្ខារទាំងឡាយនោះ សង្គ្រោះចូលក្នុងសង្ខារូបាទានក្ខន្ធ ។ វិញ្ញាណណា ដែលកើតជាមួយចក្ខុ វិញ្ញាណនោះសង្គ្រោះចូលក្នុងវិញ្ញាណូបាទានក្ខន្ធ ។ ភិក្ខុនោះតែងដឹងច្បាស់ យ៉ាងនេះថា ការសង្គ្រោះគឺប្រមូលប្រជុំនូវឧបាទានក្ខន្ធទាំង ៥ នេះ យ៉ាងនេះឯង។

ម្យ៉ាងវិញទៀត ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា បុគ្គលណាឃើញបដិច្ចសមុប្បាទ (គឺការកើតឡើងព្រោះអាស្រ័យ

បច្ច័យ ) បុគ្គលនោះ ឈ្មោះថាឃើញធម៌ បុគ្គលណាឃើញធម៌ បុគ្គលនោះ ឈ្មោះថាឃើញបដិច្ចសមុប្បាទ ។

ឧបាទានក្ខន្ធ ៥ ណាដែលមាននៅ ឧបាទានក្ខន្ធ ៥ នោះឯង កើតឡើងព្រមព្រោះអាស្រ័យបច្ច័យ ។ សេចក្ដីពេញចិត្ត សេចក្ដីអាល័យ សេចក្ដីត្រេកអរនិងសេចក្ដីជ្រប់ចុះក្នុងឧបាទានក្ខន្ធ ៥ នោះណា សេចក្ដីពេញចិត្តជាដើមនោះ ឈ្មោះថាទុក្ខសមុទយៈ (ហេតុជាទីកើតឡើងនៃទុក្ខ ) ។ ការកម្ចាត់បង់នូវតម្រេកដោយអំណាចនៃតណ្ហា និងការលះបង់នូវឆន្ទរាគៈក្នុងឧបាទានក្ខន្ធ ៥ នោះ ឈ្មោះថា ទុក្ខនិរោធ ។

ម្នាលអ្នកដ៏មានអាយុទាំងឡាយ ពាក្យប្រដៅរបស់ព្រះ-មានព្រះភាគ ឈ្មោះថាភិក្ខុនោះធ្វើជារឿយៗហើយ ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។

ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្ដាត ផ្លូវកាយ និងផ្លូវចិត្ត ព្រះសារីបុត្តសម្ដែងមានន័យដូចជាផ្លូវភ្នែកដែរ ។

« បិដកលេខ ៣៣ , ទំព័រ ៣២០ »

សម័យមួយព្រះមានព្រះភាគ ទ្រង់គង់ទៀបឆ្នេរនៃស្ទឹងគង្គា ជិតក្រុងអយុជ្ឈា ។ ក្នុងទីនោះ ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ដូចជាស្ទឹងគង្គានេះ





បន្សាត់ទៅនូវដុំនៃពពុះទឹកដ៏ធំ ។ បុរសមានភ្នែកក្រឡេកមើលឃើញដុំនៃពពុះទឹកនោះ ហើយពិចារណា ដោយឧបាយ ។ កាលបើបុរសនោះក្រឡេកមើលឃើញ ពិចារណាដោយឧបាយ ដុំពពុះទឹកនោះ ក៏ប្រាកដជារបស់សោះសូន្យ ប្រាកដជារបស់ទទេ ប្រាកដជារបស់មិនមានខ្លឹម ។ ម្នាលភិក្ខុទាំងឡាយ ខ្លឹមនឹងមានក្នុងដុំនៃពពុះទឹកដូចម្ដេចបាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ រូបឯណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ។ល។ រូបឯណា ក្នុងទីឆ្ងាយក្ដី ក្នុងទីជិតក្ដី ភិក្ខុក្រឡេកមើលឃើញរូបនោះ ពិចារណា ដោយឧបាយ ។ កាលបើភិក្ខុនោះក្រឡេកមើលឃើញ ពិចារណា ដោយឧបាយ រូបនោះក៏ប្រាកដជារបស់សោះសូន្យ ប្រាកដជារបស់ទទេ ប្រាកដជារបស់មិនមានខ្លឹម ។ ម្នាលភិក្ខុទាំងឡាយ ខ្លឹមនឹងមានក្នុងរូបដូចម្ដេចបាន ក៏យ៉ាងនោះឯង ។

ជាបន្តព្រះអង្គទ្រង់ត្រាស់សម្ដែងអំពីវេទនា សញ្ញា សង្ខារ និងវិញ្ញាណ រួចហើយទ្រង់សម្ដែងនូវព្រះគាថាសរុប :

**ផេណបិណ្ឌូបមំ រូបំ វេទនា ពុព្វុឡូបមា**
**មរីចិកូបមា សញ្ញា សង្ខារា កទលូបមា**
**មាយូបមញ្ច វិញ្ញាណំ ទេសិតាទិច្ចពន្ធុនា ។**

ព្រះពុទ្ធមានផៅពង្សដូចជាព្រះអាទិត្យ សម្ដែងហើយថា

រូបដូចជាដុំនៃពពុះទឹក វេទនាដូចជាក្រពេញទឹក សញ្ញាដូចជាថ្ងៃបណ្តើរកូន សង្ខារដូចជាដើមចេក វិញ្ញាណដូចជាកលមាយា ។

**យថា យថា និជ្ឈាយតិ យោនិសោ ឧបបរិក្ខតិ**
**រិត្តកំ តុច្ឆកំ ហោតិ យោ នំ បស្សតិ យោនិសោ ។**

បុគ្គលសម្លឹងពិនិត្យមើលដោយប្រការណា១ រមែង <u>ពិចារ-ណាដោយឧបាយ</u> ដោយប្រការនោះ១ បុគ្គលណាឃើញនូវបញ្ចក្ខន្ធនោះដោយឧបាយ បញ្ចក្ខន្ធនោះក៏ប្រាកដជារបស់សោះ-សូន្យទទេ ។

**ឥមញ្ច កាយំ អារព្ភ ភូរិបញ្ញេន ទេសិតំ**
**បហានំ តិណ្ណំ ធម្មានំ រូបំ បស្សថ ឆឌ្ឌិតំ ។**

ការលះបង់នូវធម៌ទាំង ៣ ដែលព្រះមានព្រះភាគមានបញ្ញាដូចជាផែនដី ទ្រង់ប្រារព្ធនូវកាយនេះហើយសម្តែង អ្នកទាំងឡាយចូរឃើញនូវរូបដែលគេចោលហើយ ។

**អាយុ ឧស្មា ច វិញ្ញាណំ យទា កាយំ ជហន្តិមំ**
**អបវិទ្ធោ តទា សេតិ បរភត្តំ អចេតនំ ។**

អាយុក្តី ភ្លើងធាតុក្តី វិញ្ញាណក្តី កាលបើលះបង់នូវកាយនេះ ក្នុងកាលណាហើយ ក្នុងកាលនោះ កាយនេះគេតែងចោលឱ្យដេកនៅលើផែនដី មិនមានចេតនា ជាចំណីនៃសត្វដទៃ ។





**ឯតាទិសាយំ សន្តានោ មាយាយំ ពាលលាបិនី**
**វធកោ ឯកោ អក្ខាតោ សារោ ឯត្ថ ន វិជ្ជតិ ។**

ធម៌ជាតំណនេះ ប្រាកដដូច្នេះឯង កលមាយានេះជាគ្រឿងប្រលោមនូវជនពាល ខន្ធនេះតថាគតពោលថាជាពេជ្ឈឃាតម្នាក់ ឯខ្លឹមរមែងមិនមានក្នុងខន្ធនេះឡើយ ។

**ឯវំ ខន្ធេ អវេក្ខេយ្យ ភិក្ខុ អារទ្ធវីរិយោ**
**ទិវា វា យទិ វា រត្តិំ សម្បជានោ បដិស្សតោ ។**

ភិក្ខុប្រារព្ធនូវសេចក្តីព្យាយាម មានសតិសម្បជញ្ញៈ គប្បីពិចារណានូវខន្ធយ៉ាងនេះ ទាំងយប់ទាំងថ្ងៃ ។

**បជហេ សព្វសំយោគំ ករេយ្យ សរណត្តនោ**
**ចរេយ្យាទិត្តសីសោវ បត្ថយំ អច្ចុតំ បទន្តិ ។**

បុគ្គលកាលប្រាថ្នានូវព្រះនិព្វានដែលមិនមានចុតិ គប្បីលះបង់នូវសំយោជនៈទាំងពួង ធ្វើនូវទីពឹងសម្រាប់ខ្លួន ដោយមានការប្រព្រឹត្តដូចជាបុគ្គលមានភ្លើងឆេះក្បាលដូច្នោះឯង ។

☆ ☆ ☆

## ៣-វិធីគិតពិចារណាតាមបែបត្រៃលក្ខណ៍

វិធីពិចារណាតាមបែបត្រៃលក្ខណ៍ ឬវិធីគិតតាមបែប ធម្មតានៃសង្ខារធម៌ គឺសម្លឹងមើលយ៉ាងច្បាស់លាស់ពីការប្រព្រឹត្តទៅនៃសភាវៈទាំងឡាយ ដែលត្រូវប្រព្រឹត្តទៅយ៉ាងណានោះ តាមធម្មតារបស់សភាវៈនោះៗ ។ សភាវធម៌រមែងកើតចាកហេតុ ចាកបច្ច័យផ្សេងៗ រមែងប្រព្រឹត្តទៅតាមហេតុតាមបច្ច័យ ។

ពាក្យដែលថា ធម្មតានៃសង្ខារធម៌ បានដល់អាការនៃសភាវៈទាំងឡាយ ដែលកើតអំពីបច្ច័យតាក់តែង កាលដែលកើតឡើងហើយ ក៏ត្រូវតែរលត់ទៅវិញ មិនទៀងទាត់ មិនមាំមួន មិនយឺនយូរ មិនឋិតនៅជារហូតទៅបានឡើយ ហៅថា **អនិច្ចំ** ។

របស់ណាមិនទៀង របស់នោះជា **ទុក្ខ** របស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា របស់នោះគឺមិនមែនជារបស់អ្នកណាឡើយ ហើយមិនមែនជាតួខ្លួននៃខ្លួនឯងទៀតផង គ្រាន់តែជាផលរបស់បច្ច័យប៉ុណ្ណោះ ។

សង្ខារធម៌មិនប្រព្រឹត្តទៅតាមការបង្គាប់បញ្ជា និងមិនប្រព្រឹត្តទៅតាមសេចក្តីប្រាថ្នារបស់បុគ្គលណាឡើយ ។ មិនមានអ្នកណាជាម្ចាស់គ្រប់គ្រងលើសង្ខារធម៌ជាដាច់ខាត ព្រោះសង្ខារ-





ធម៌ប្រព្រឹត្តទៅតាមតែហេតុ តាមតែបច្ច័យ មិនមែនប្រព្រឹត្តទៅតាមចិត្តចង់របស់អ្នកណាម្នាក់នោះទេ នេះហៅថា **អនត្តា** ។

រួមសេចក្តីមកគឺថា ដឹងទាន់នូវសភាវៈទាំងឡាយជាធម្មជាតិ ។ ធម្មជាតិនេះមានលក្ខណៈស្មើគ្នាតាមធម្មតា ក្នុងឋានៈដែលជារបស់តាក់តែង ឋិតក្នុង **អនិច្ចំ ទុក្ខំ អនត្តា** អាចហៅថា សាមញ្ញលក្ខណៈ គឺលក្ខណៈស្មើគ្នា ។

វិធីគិតពិចារណាតាមបែបត្រៃលក្ខណ៍នេះ នាំឱ្យសម្រេចផលចែកចេញជាពីរថ្នាក់ :

**-ថ្នាក់ទី ១** គឺដឹងទាន់និងព្រមទទួលនូវសេចក្តីពិត នេះជាថ្នាក់ដាក់ចិត្តដាក់គំនិត ស្របទៅតាមសេចក្តីពិតរបស់ធម្មជាតិ ជាគំនិតប្រកបដោយបញ្ញា និងជាគំនិតមានភាពជាឥស្សរៈ មិនចងខ្លួនឯងដោយសេចក្តីប្រកាន់ឡើយ ។ ទោះបីមានការជួបប្រសព្វនូវហេតុការណ៍ដែលមិនជាទីប្រាថ្នា ឬមានរឿងរ៉ាវដែលមិនត្រូវតាមអធ្យាស្រ័យរបស់ខ្លួន ក៏គិតឃើញថា ហេតុការណ៍នោះៗ សភាវធម៌នោះៗ ប្រព្រឹត្តទៅតាមដំណើរធម្មតា គឺទៅតាមហេតុ តាមបច្ច័យរបស់វា ។ ការគិតឃើញត្រូវទៅតាមសេចក្តីពិត នាំឱ្យរើខ្លួនរួចបាន ហើយរមែងរួចចាកអំពីសេចក្តីទុក្ខ ឬយ៉ាងហោចណាស់ក៏គង់កាត់បន្ថយនូវសេចក្តីទុក្ខនោះៗ ។

តាមការពិត គឺមិនសាងតួខ្លួនឯងឱ្យមកទទួលទុក្ខ គឺគ្រាន់តែសម្លឹងមើលនូវសេចក្តីពិតប៉ុណ្ណោះ មិនសម្លឹងមើលដោយចង់ឱ្យទៅជាយ៉ាងនេះ ចង់មិនឱ្យទៅជាយ៉ាងនោះឡើយ ។

**-ថ្នាក់ទី ២** គឺកែខៃនិងធ្វើទៅតាមហេតុតាមបច្ច័យ នេះជាថ្នាក់បដិបត្តិស្របទៅតាមសេចក្តីពិតរបស់ធម្មជាតិ ជាការបដិបត្តិប្រកបដោយបញ្ញា និងជាការបដិបត្តិមានភាពជាឥស្សរៈ មិនមែនជាការបដិបត្តិចងខ្លួនឯងទុកក្នុងទុក្ខនោះឡើយ ។

កាលបើបានដឹងថា សង្ខារធម៌ទាំងឡាយប្រព្រឹត្តទៅតាមហេតុតាមបច្ច័យ ដូច្នេះ បើយើងត្រូវការឱ្យបានសម្រេចផលយ៉ាងណានោះ ត្រូវសិក្សាឱ្យយល់អំពីហេតុ អំពីបច្ច័យទាំងឡាយ ដែលនឹងធ្វើឱ្យបានសម្រេចនូវផលនោះៗ រួចហើយត្រូវកែខៃ ត្រូវរៀបចំត្រូវធ្វើនូវហេតុនូវបច្ច័យឱ្យបានបរិបូណ៌ ។ កាលបើធ្វើហេតុ ធ្វើបច្ច័យឱ្យបានដល់ព្រម និងបរិបូណ៌ពេញលេញ ល្មមនឹងឱ្យផលសម្រេចទៅបានហើយ ផលក៏រមែងប្រព្រឹត្តទៅយ៉ាងនោះ ទោះជាយើងចង់បាន ឬមិនចង់បានក៏ដោយ ។ តែបើហេតុនិងបច្ច័យមិនបានដល់ព្រម មិនបានគ្រប់គ្រាន់បរិបូណ៌ពេញលេញទេ ផលក៏រមែងប្រព្រឹត្តទៅមិនបានដែរ ទោះជាយើងប្រាថ្នាត្រូវការយ៉ាងណាក៏ដោយ ។



ពោលដោយសរុបខ្លីគឺ ត្រូវកែខៃដោយការចេះដឹង និងកែខៃនៅត្រង់ហេតុត្រង់បច្ច័យ មិនមែនកែខៃដោយចំណង់នោះឡើយ ។ បើចំណង់កើតមានឡើង ត្រូវកំណត់ដឹងនូវចំណង់នោះហើយកែខៃ រៀបចំ ធ្វើការសាងហេតុសាងបច្ច័យនៃសេចក្តីសុខសេចក្តីចម្រើនដោយខ្លួនឯង ។

កាលបដិបត្តិយ៉ាងនេះ ក៏បានរឺខ្លួនជាឥស្សរៈ មិនជាទាសៈនៃតណ្ហា មិនត្រូវចំណង់តណ្ហានាំខ្លួនទៅឡើយ ពោលគឺមិនសាងតួខ្លួនមកទទួលនូវទុក្ខហ្នឹងឯង ។ នេះជាការបដិបត្តិមិនចងខ្លួនទុកក្នុងបញ្ញា គឺថាបដិបត្តិត្រង់ត្រឹមត្រូវតាមហេតុតាមបច្ច័យ ទាំងព្រមសុខចិត្តឱ្យសភាវធម៌ទាំងឡាយ ប្រព្រឹត្តទៅតាមហេតុ តាមបច្ច័យពិតៗ មិនទំនាស់នឹងដំណើរពិតនៃសង្ខារធម៌ឡើយ ។

ម្យ៉ាងទៀត ការបដិបត្តិយ៉ាងនេះ ជាការបដិបត្តិទាំងបានផលល្អជាទីបំផុតផង ទាំងធ្វើឱ្យខ្លួនឯងអ្នកបដិបត្តិមិនជាទុក្ខក្នុងពេលដំណើរការបដិបត្តិផង ។

ការបដិបត្តិតាមវិធីគិតពិចារណាបែបទី ៣ (ពិចារណាតាមបែបត្រៃលក្ខណ៍ ) ថ្នាក់ទី ២ នេះ មានសម្ពន្ធទាក់ទងនឹងវិធីគិតតាមបែបទី ៤ ដែលនឹងពោលតទៅក្នុងវិធីគិតពិចារណាតាមបែបអរិយសច្ច ។

មានព្រះពុទ្ធដីកា ដែលព្រះអង្គសម្តែងឱ្យមានយោនិសោ-មនសិការ តាមវិធីគិតពិចារណាបែបទី ២ និងបែបទី ៣ ដោយការពិចារណាទៅព្រមៗគ្នា សូមលើកយកមកខ្លះៗជាតួយ៉ាង :

« បិដកលេខ ៣៣ , ទំព័រ ១១៨ »

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរធ្វើទុកក្នុងចិត្តចំពោះរូបដោយឧបាយផង ចូរពិចារណាតាមពិតនូវរូបថាមានសេចក្តីមិនទៀងផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុធ្វើទុកក្នុងចិត្តចំពោះរូបដោយឧបាយផង ពិចារណាឃើញតាមពិតនូវរូបថាមានសេចក្តីមិនទៀងផងហើយ រមែងនឿយណាយក្នុងរូប ។ ការអស់ទៅនៃតម្រេក ព្រោះអស់ទៅនៃសេចក្តីរីករាយ ការអស់ទៅនៃសេចក្តីរីករាយ ព្រោះអស់ទៅនៃតម្រេក ចិត្តដែលរួចស្រឡះហើយ ព្រោះអស់ទៅនៃសេចក្តីរីករាយនិងតម្រេក ហៅថារួចស្រឡះដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរធ្វើទុកក្នុងចិត្តចំពោះវេទនាដោយឧបាយផង ចូរពិចារណាតាមពិតនូវវេទនាថាមានសេចក្តីមិនទៀងផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុធ្វើទុកក្នុងចិត្ត ចំពោះវេទនាដោយឧបាយ ពិចារណាតាមពិតនូវវេទនាថាមានសេចក្តីមិនទៀងផងហើយ រមែងនឿយណាយក្នុងវេទនា ។ ការអស់ទៅនៃតម្រេក ព្រោះអស់ទៅនៃសេចក្តីរីករាយ





ការអស់ទៅនៃសេចក្តីរីករាយ ព្រោះអស់ទៅនៃតម្រេក ចិត្តដែលរួចស្រឡះហើយ ព្រោះការអស់ទៅនៃសេចក្តីរីករាយ និងតម្រេក ហៅថារួចស្រឡះដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ (អ្នកទាំងឡាយចូរធ្វើទុកក្នុងចិត្ត ) ចំពោះសញ្ញា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរធ្វើទុកក្នុងចិត្ត ចំពោះសង្ខារដោយឧបាយផង ចូរពិចារណាតាមពិតនូវសង្ខារថាមានសេចក្តីមិនទៀងផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុធ្វើទុកក្នុងចិត្ត ចំពោះសង្ខារដោយឧបាយ ពិចារណាតាមពិតនូវសង្ខារថាមានសេចក្តីមិនទៀងហើយ រមែងនឿយណាយក្នុងសង្ខារ ។ ការអស់ទៅនៃតម្រេក ព្រោះការអស់ទៅនៃសេចក្តីរីករាយ ការអស់ទៅនៃសេចក្តីរីករាយ ព្រោះអស់ទៅនៃតម្រេក ចិត្តដែលរួចស្រឡះហើយ ព្រោះការអស់ទៅនៃសេចក្តីរីករាយ និងតម្រេក ហៅថារួចស្រឡះដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរធ្វើទុកក្នុងចិត្តចំពោះវិញ្ញាណដោយឧបាយផង ចូរពិចារណាតាមពិតនូវវិញ្ញាណថាមានសេចក្តីមិនទៀងផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុធ្វើទុកក្នុងចិត្តចំពោះវិញ្ញាណដោយឧបាយ ពិចារណាតាមពិតនូវវិញ្ញាណថា មានសេចក្តីមិនទៀងហើយ រមែងនឿយ-ណាយក្នុងវិញ្ញាណ ។ ការអស់ទៅនៃតម្រេក ព្រោះការអស់ទៅ

នៃសេចក្តីរីករាយ ការអស់ទៅនៃសេចក្តីរីករាយ ព្រោះការអស់ទៅនៃតម្រេក ចិត្តដែលរួចស្រឡះហើយ ព្រោះការអស់ទៅនៃសេចក្តីរីករាយនិងតម្រេក ហៅថារួចស្រឡះដោយប្រពៃ ។

« បិដកលេខ ៣៤ , ទំព័រ ២២ »

សម័យមួយ ព្រះសារីបុត្តមានអាយុ និងព្រះមហាកោដ្ឋិតៈមានអាយុ នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ គ្រានោះ ព្រះមហាកោដ្ឋិតៈមានអាយុ ចេញចាកទីសម្ងំក្នុងសាយណ្ហសម័យ ហើយចូលទៅរកព្រះសារីបុត្តមានអាយុ ។បេ។ បានពោលពាក្យនេះថា ម្នាលអាវុសោសារីបុត្ត ភិក្ខុអ្នកមានសីលគួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះធម៌ដូចម្តេច ។ ម្នាលអាវុសោកោដ្ឋិតៈ ភិក្ខុអ្នកមានសីល គួរធ្វើទុកក្នុងចិត្ត ដោយឧបាយប្រាជ្ញាចំពោះឧបាទានក្ខន្ធ ៥ ថាមិនទៀង ជាទុក្ខ ជារោគ ជាបូស ជាសរ ជាជំងឺ ជាអាពាធ ជារបស់ដទៃ ជារបស់វិនាស ជារបស់សូន្យ ជារបស់មិនមែនខ្លួន ។ ឧបាទានក្ខន្ធទាំង ៥ ដូចម្តេច ។ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលអាវុសោកោដ្ឋិតៈ ភិក្ខុអ្នកមានសីល គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា





ចំពោះឧបាទានក្ខន្ធ ៥ នេះ ថាមិនទៀង ជាទុក្ខ ជារោគ ជាបូស ជាសរ ជាជំងឺ ជាអាពាធ ជារបស់ដទៃ ជារបស់វិនាស ជារបស់សូន្យ ជារបស់មិនមែនខ្លួន ។ ម្នាលអាវុសោ ហេតុនេះតែងមានប្រាកដ គឺនៅត្រង់ដែលភិក្ខុមានសីល កាលធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះថា មិនទៀង ។បេ។ ជារបស់មិនមែនខ្លួន នឹងធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផលបាន ។

ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុជាសោតាបន្ន គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះធម៌ដូចម្តេច ។ ម្នាលអាវុសោកោដ្ឋិតៈ ទោះបីភិក្ខុជាសោតាបន្ន ក៏គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះថា មិនទៀង ។បេ។ ជារបស់មិនមែនខ្លួន ។ ម្នាលអាវុសោ ហេតុនេះតែងមានប្រាកដ គឺត្រង់ដែលភិក្ខុជាសោតាបន្ន កាលធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះថា មិនទៀង ។បេ។ ជារបស់មិនមែនខ្លួន នឹងធ្វើឱ្យជាក់ច្បាស់នូវសកទាគាមិផលបាន ។

ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុជាសកទាគាមី គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះធម៌ដូចម្តេច ។ ម្នាលអាវុសោកោដ្ឋិតៈ ទោះបីភិក្ខុជាសកទាគាមី ក៏គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះថា មិនទៀង ។បេ។

ជារបស់មិនមែនខ្លួន ។ ម្នាលអាវុសោ ហេតុនេះតែងមានប្រាកដ គឺត្រង់ដែលភិក្ខុជាសកទាគាមី កាលធ្វើទុកក្នុងចិត្ត ដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះថា មិនទៀង ។បេ។ ជារបស់មិនមែនខ្លួន នឹងធ្វើឱ្យជាក់ច្បាស់នូវអនាគាមិផលបាន ។

ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុជាអនាគាមី គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះធម៌ដូចម្តេច ។ ម្នាលអាវុសោកោដ្ឋិតៈ ទោះបីភិក្ខុជាអនាគាមី ក៏គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះថា មិនទៀង ។បេ។ ជារបស់មិនមែនខ្លួន ។ ម្នាលអាវុសោ ហេតុនេះតែងមានប្រាកដ គឺត្រង់ដែលភិក្ខុជាអនាគាមី កាលធ្វើទុកក្នុងចិត្ត ដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះថា មិនទៀង ។បេ។ ជារបស់មិនមែនខ្លួន នឹងធ្វើឱ្យជាក់ច្បាស់នូវអរហត្តផលបាន ។

ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុជាព្រះអរហន្ត គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះធម៌ដូចម្តេច ។ ម្នាលអាវុសោកោដ្ឋិតៈ ទោះបីភិក្ខុជាព្រះអរហន្ត ក៏គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះថា មិនទៀង ជាទុក្ខ ជារោគ ជាបូស ជាសរ ជាជំងឺ ជាអាពាធ ជារបស់ដទៃ ជា របស់វិនាស ជារបស់សូន្យ ជារបស់មិនមែនខ្លួន ។ ម្នាលអាវុសោ





សេចក្តីសន្សំរបស់ភិក្ខុជាព្រះអរហន្ត ដែលធ្វើករណីយកិច្ចតទៅទៀតឥតមានទេ ប៉ុន្តែធម៌ទាំងនេះ ដែលព្រះអរហន្តបានចម្រើនបានធ្វើរឿយៗហើយ រមែងប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្នផង ដើម្បីសតិសម្បជញ្ញៈផង ។

តទៅនេះ ជាព្រះពុទ្ធវចនៈសម្តែងអំពីការគិតពិចារណាដោយយោនិសោមនសិការ តាមបែបស្រាវជ្រាវរាវរកហេតុនិងបន្តដោយការគិតពិចារណា តាមបែបត្រៃលក្ខណ៍ ឬសាមញ្ញលក្ខណៈ បំណងដើម្បីឱ្យបានដឹងច្បាស់តាមសេចក្តីពិត ឱ្យមានចិត្តជាឥស្សរៈ និងមិនឱ្យកើតទុក្ខ ។

« បិដកលេខ ៣៣ , ទំព័រ ៩៦ »

ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកខ្លួនជាទីពឹង យកខ្លួនជាទីរឭក កុំយករបស់ដទៃជាទីពឹងទីរឭកឡើយ ចូរយកធម៌ជាទីពឹង យកធម៌ជាទីរឭក កុំយករបស់ដទៃជាទីពឹងទីរឭកឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលបើយកខ្លួនជាទីពឹង យកខ្លួនជាទីរឭក មិនយករបស់ដទៃជាទីពឹងទីរឭក យកធម៌ជាទីពឹង យកធម៌ជាទីរឭក មិនយករបស់ដទៃជាទីពឹងទីរឭកហើយ គប្បីពិចារណារកហេតុដោយឧបាយថា សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស និង

សេចក្តីចង្អៀតចង្អល់ចិត្ត កើតមកអំពីអ្វី មានមកអំពីអ្វី ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត កើតមកអំពីអ្វី មានមកអំពីអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងអរិយធម៌ មិនសិក្សាក្នុងអរិយធម៌ មិនបានឃើញពួកសប្បុរស មិនឈ្លាសវៃ ក្នុងសប្បុរិសធម៌ មិនសិក្សាក្នុងសប្បុរិសធម៌ រមែងពិចារណាឃើញនូវរូបថាជាខ្លួនខ្លះ ឃើញនូវខ្លួនថាមានរូបខ្លះ ឃើញនូវរូបថាមានក្នុងខ្លួនខ្លះ ឃើញនូវខ្លួនថាមានក្នុងរូបខ្លះ លុះរូបនោះ របស់បុគ្គលនោះប្រែប្រួលវិបត្តិផ្សេងៗទៅ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតឡើងដល់បុគ្គលនោះ ព្រោះរូបប្រែប្រួលវិបត្តិទៅផ្សេងៗ ។ បុគ្គលនោះពិចារណាឃើញនូវវេទនាថាជាខ្លួនខ្លះ ឃើញនូវខ្លួនថាមានវេទនាខ្លះ ឃើញនូវវេទនាថាមានក្នុងខ្លួនខ្លះ ឃើញនូវខ្លួនថាមានក្នុងវេទនាខ្លះ លុះវេទនានោះ របស់បុគ្គលនោះប្រែប្រួលវិបត្តិផ្សេងៗទៅ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតឡើងដល់បុគ្គលនោះ ព្រោះវេទនាប្រែប្រួលវិបត្តិទៅផ្សេងៗ ។ ឃើញនូវសញ្ញា ។ ពិចារណា





ឃើញនូវសង្ខារថាជាខ្លួន ។បេ។ ពិចារណាឃើញនូវវិញ្ញាណថាជាខ្លួនខ្លះ ឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ ឃើញនូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ ឃើញនូវខ្លួនថាមានក្នុងវិញ្ញាណខ្លះ លុះវិញ្ញាណនោះរបស់បុគ្គលនោះប្រែប្រួលវិបត្តិផ្សេងៗ ទៅ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតឡើងដល់បុគ្គលនោះ ព្រោះ វិញ្ញាណប្រែប្រួលវិបត្តិទៅផ្សេងៗ ។

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុដឹងច្បាស់ នូវសេចក្តីមិនទៀង សេចក្តីប្រែប្រួល សេចក្តីវិនាស និងសេចក្តីរលត់នៃរូប ហើយឃើញច្បាស់តាមពិតដោយប្រាជ្ញាដ៏ប្រពៃ នូវរូបនុ៎ះយ៉ាងនេះថា រូបក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី រូបទាំងអស់ មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ភិក្ខុនោះ ក៏លះបង់សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តចេញបាន កាលបើភិក្ខុនោះ លះបង់នូវសេចក្តីសោកជាដើមទាំងនោះចេញហើយ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុតហើយ រមែងនៅជាសុខ ភិក្ខុអ្នកមានធម៌ជាគ្រឿងនៅជាសុខ ហៅថា អ្នករំលត់កិលេសដោយអង្គនៃវិបស្សនានោះៗ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុដឹងច្បាស់ នូវសេចក្តីមិនទៀង

សេចក្តីប្រែប្រួល សេចក្តីវិនាស និងសេចក្តីរលត់នៃវេទនា ហើយ ឃើញច្បាស់តាមពិតដោយប្រាជ្ញាដ៏ប្រពៃ នូវវេទនានុ៎ះយ៉ាងនេះ ថា វេទនាក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី វេទនាទាំងអស់ មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ភិក្ខុនោះ ក៏លះបង់សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តចេញបាន កាលបើភិក្ខុនោះ លះបង់សេចក្តីសោកជាដើមទាំងនោះចេញហើយ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុតហើយ រមែងនៅជាសុខ ភិក្ខុអ្នកមានធម៌ជាគ្រឿងនៅជាសុខ ហៅថាអ្នករំលត់កិលេសដោយអង្គនៃវិបស្សនានោះៗ ។ ( កាលបើភិក្ខុដឹងច្បាស់ នូវសេចក្តីមិនទៀង ) នៃសញ្ញា ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុដឹងច្បាស់ នូវសេចក្តីមិនទៀង សេចក្តីប្រែប្រួល សេចក្តីវិនាស និងសេចក្តីរលត់នៃសង្ខារហើយ បានឃើញច្បាស់តាមពិតដោយប្រាជ្ញាដ៏ប្រពៃ នូវសង្ខារនុ៎ះយ៉ាងនេះថា សង្ខារក្នុងកាលមុនក្តី សង្ខារក្នុងកាលឥឡូវនេះក្តី សង្ខារទាំងអស់ មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ភិក្ខុនោះ ក៏លះបង់សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តចេញបាន កាលបើភិក្ខុនោះ លះបង់សេចក្តីសោកជាដើម





ទាំងនោះចេញហើយ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុតហើយ រមែងនៅជាសុខ ភិក្ខុអ្នកមានធម៌ជាគ្រឿងនៅជាសុខ ហៅថាអ្នករំលត់កិលេសដោយអង្គនៃវិបស្សនានោះៗ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុដឹងច្បាស់ នូវសេចក្តីមិនទៀង សេចក្តីប្រែប្រួល សេចក្តីវិនាស និងសេចក្តីរលត់នៃវិញ្ញាណហើយ បានឃើញច្បាស់តាមពិតដោយប្រាជ្ញាដ៏ប្រពៃ នូវវិញ្ញាណនុ៎ះយ៉ាងនេះថា វិញ្ញាណក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី វិញ្ញាណទាំងអស់ មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ភិក្ខុនោះ ក៏លះបង់សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តចេញបាន កាលបើភិក្ខុនោះ លះបង់សេចក្តីសោកជាដើមទាំងនោះចេញហើយ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុតហើយ រមែងនៅជាសុខ ភិក្ខុអ្នកមានធម៌ជាគ្រឿងនៅជាសុខ ហៅថាអ្នករំលត់កិលេសដោយអង្គនៃវិបស្សនានោះៗ ( **តទង្គនិព្វុតោ** )។

## ៤.វិធីគិតពិចារណាតាមបែបអរិយសច្ច

វិធីគិតតាមបែបអរិយសច្ច ឬគិតតាមបែបការដោះស្រាយនូវបញ្ហា ពោលគឺវិធីនៃការរំលត់ទុក្ខ ។

« បិដកលេខ ២០ , ទំព័រ ២៩ »

ភិក្ខុនោះ មាននូវយោនិសោមនសិការថា នេះទុក្ខ មាននូវយោនិសោមនសិការថា នេះតណ្ហាជាដែនឱ្យកើតទុក្ខ មាននូវយោនិសោមនសិការថា នេះនិព្វានធម៌ជាទីរលត់ទុក្ខ មាននូវយោនិសោមនសិការថា នេះការប្រតិបត្តិ ដើម្បីដល់នូវព្រះនិព្វានជាទីរលត់ទុក្ខ ។ កាលភិក្ខុនោះ មាននូវយោនិសោមនសិការយ៉ាងនេះហើយ សំយោជនៈទាំងឡាយ ៣ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈរមែងសាបសូន្យទៅ ។

វិធីគិតពិចារណាតាមបែបអរិយសច្ចនេះ មានលក្ខណៈទូទៅ ២ ប្រការ គឺ

១.ជាវិធីគិតតាមហេតុនិងផល បានដល់ការគិតពិចារណាពីផលដេញទៅរកហេតុ ហើយដោះស្រាយកែខៃ និងបដិបត្តិត្រង់ចំពោះដើមហេតុ ចាត់ជា ២ គូ :





គូទី ១ .**ទុក្ខ** ជាផល ជាតួបញ្ហា ជាសភាពនៃធម៌ដែលមិនជាទីប្រាថ្នា ។

.**សមុទ័យ** ជាហេតុ ជាទីកើតនៃបញ្ហា ជាចំណុចដែលត្រូវកម្ចាត់ ឬកែខៃ ទើបអាចផុតពីបញ្ហាបាន ។

គូទី ២ .**និរោធ** ជាផល ជាទីអស់បញ្ហា ជាទិសដៅដែលត្រូវការនឹងចូលដល់ ។

.**មគ្គ** ជាហេតុ ជាវិធីការ ជាផ្នែកបដិបត្តិដែលត្រូវធ្វើការកែខៃ ដោះស្រាយកម្ចាត់នូវហេតុនៃទុក្ខ ដើម្បីបានសម្រេចនូវទិសដៅគឺព្រះនិព្វានដែលមិនមាននូវបញ្ហា ។

២.ជាវិធីគិតសំដៅចំត្រង់ចំណុច ដែលមានការទាក់ទងនឹងជីវិត គិតចំត្រង់ចំណុចបញ្ហា និងគិតបដិបត្តិកម្ចាត់បញ្ហា ឆ្ពោះមុខទៅរកទីបំផុតទុក្ខ ។

ក្នុងលក្ខណៈនៃវិធីគិតទី ២ នេះ គឺជាការបញ្ចៀសនូវគំនិតរវើរវាយក្នុងរឿងឥតប្រយោជន៍ផ្សេងៗ ។ គំនិតឥតប្រយោជន៍ គឺជាគំនិតដែលមិនមែនជាការគិតដោះស្រាយបញ្ហា ។

ដើម្បីបញ្ជាក់ឱ្យបានច្បាស់នូវលក្ខណៈនៃវិធីគិតទី ២ នេះ សូមលើកយក **ចូឡមាលុង្ក្យោវាទសូត្រ** បិដកលេខ ២៣ ទំព័រ ២៤៥ មកបញ្ជាក់ដូចតទៅ ។

## ចូឡមាលុង្ក្យោវាទសូត្រ

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមាលុង្ក្យបុត្រដ៏មានអាយុ ចូលទៅសម្ងំនៅក្នុងទីរហោឋាន ក៏មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា ទិដ្ឋិទាំងឡាយណាថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃសរីរៈក៏ដទៃដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ព្រះមានព្រះភាគ មិនបានសំដែង គ្រាន់តែតម្កល់ទុកហើយទ្រង់ហាមឃាត់ ព្រះមានព្រះភាគមិនបានសំដែងទិដ្ឋិទាំងនោះដល់អញទេ ព្រះមានព្រះភាគ មិនបានសំដែងទិដ្ឋិទាំងឡាយណាដល់អញ ដំណើរដែលមិនបានសំដែងទិដ្ឋិនោះ មិនគាប់ចិត្តអញទេ ដំណើរដែលមិនបានសំដែងទិដ្ឋិនោះ មិនបានពេញចិត្តអញឡើយ អញឯងនឹងចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរដំណើរនុ៎ះ ប្រសិន-បើ ព្រះមានព្រះភាគ នឹងសំដែងប្រាប់អញថា លោកទៀងដូច្នេះក្តី





។បេ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី កាលបើយ៉ាងនេះ អាត្មាអញ នឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ តែប្រសិនបើព្រះមានព្រះភាគ មិនបានសំដែងថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃ សរីរៈក៏ដទៃដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី កាលបើយ៉ាងនេះ អាត្មាអញ នឹងលះបង់សិក្ខា ហើយត្រឡប់មកកាន់ហីនភេទវិញ ។

គ្រានោះឯង ព្រះមាលុង្ក្យបុត្រមានអាយុ ក្រោកចេញអំពីសំណិង ក្នុងវេលាសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះមាលុង្ក្យបុត្រមានអាយុអង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូល នូវដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនេះ ខ្ញុំព្រះអង្គចូលទៅសម្ងំនៅក្នុងទីរហោឋាន ក៏មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា

ទិដ្ឋិទាំងឡាយណាថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃសរីរៈក៏ដទៃ ដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ព្រះមានព្រះភាគ មិនបានសំដែង គ្រាន់តែតម្កល់ទុក ហើយទ្រង់ហាមឃាត់ ព្រះមានព្រះភាគមិនទាន់សំដែងទិដ្ឋិទាំងនោះ ប្រាប់អាត្មាអញនៅឡើយ ព្រះមានព្រះភាគ មិនបានសំដែងទិដ្ឋិទាំងឡាយណា ដល់អាត្មាអញ ដំណើរដែលមិនបានសំដែងទិដ្ឋិនោះ មិនគាប់ចិត្តដល់អាត្មាអញទេ ដំណើរដែលមិនបានសំដែងទិដ្ឋិនោះ មិនពេញចិត្តដល់អាត្មាអញឡើយ អាត្មាអញនឹងចូលទៅគាល់ព្រះមានព្រះភាគ ហើយក្រាបទូលសួរនូវដំណើរនុ៎ះ បើព្រះមានព្រះភាគ សំដែងប្រាប់អាត្មាអញថា លោកទៀងក្តី ថា លោកមិនទៀងក្តី ថា លោកមានទីបំផុតក្តី ថា លោកមិនមានទីបំផុតក្តី ថា ជីវិតនោះក៏គឺសរីរៈនោះក្តី ថា ជីវិតដទៃសរីរៈក៏ដទៃក្តី ថា សត្វស្លាប់ហើយកើតទៀតក្តី ថា សត្វស្លាប់ហើយមិនកើតទៀតក្តី ថា សត្វស្លាប់ហើយកើតទៀត

-៤៩-

ក៏មាន មិនកើតទៀតក៏មានក្តី ថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី កាលបើយ៉ាងនេះ ទើបអាត្មាអញ នឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះមានព្រះភាគ បើព្រះមានព្រះភាគ មិនបានសំដែងថា លោកទៀងក្តី ។បេ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី កាលបើយ៉ាងនេះ អាត្មាអញ នឹងលាសិក្ខាហើយត្រឡប់មកកាន់ហីនភេទវិញ ។ បើព្រះមានព្រះភាគទ្រង់ជ្រាបថា លោកទៀងដូច្នេះហើយ សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា លោកទៀងដូច្នេះ ឱ្យទាន បើព្រះមានព្រះភាគ ទ្រង់ជ្រាបថា លោកមិនទៀង សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា លោកមិនទៀងដូច្នេះ ឱ្យទាន បើព្រះមានព្រះភាគ មិនជ្រាបថា លោកទៀងក្តី ថា លោកមិនទៀងក្តី កាលបើព្រះមានព្រះភាគ មិនជ្រាបមិនឃើញហើយ ក៏ត្រូវគ្នានឹងខ្ញុំព្រះអង្គដែលមិនដឹងមិនឃើញដែរ ។ បើព្រះមានព្រះភាគ ជ្រាបថា លោកមានទីបំផុត សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា លោកមានទីបំផុតដូច្នេះ ឱ្យទាន បើព្រះមានព្រះភាគ ជ្រាបថា លោកមិនមានទីបំផុត សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា លោកមិនមានទីបំផុតដូច្នេះ ឱ្យទាន បើព្រះមានព្រះភាគ មិនជ្រាបថា

-៥០-

លោកមានទីបំផុតក្តី ថា លោកមិនមានទីបំផុតក្តី កាលបើព្រះមានព្រះភាគ មិនជ្រាប មិនឃើញហើយ ក៏ត្រូវគ្នានឹងខ្ញុំព្រះអង្គដែលមិនដឹង មិនឃើញដែរ ។ បើព្រះមានព្រះភាគ ជ្រាបថា ជីវិតនោះក៏គឺសរីរៈនោះ សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា ជីវិតនោះក៏គឺសរីរៈនោះដូច្នេះ ឱ្យទាន បើព្រះមានព្រះភាគ ជ្រាបថា ជីវិតដទៃសរីរៈក៏ដទៃ សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា ជីវិតដទៃសរីរៈក៏ដទៃដូច្នេះ ឱ្យទាន បើព្រះមានព្រះភាគ មិនជ្រាបថា ជីវិតនោះក៏គឺសរីរៈនោះក្តី ថា ជីវិតដទៃសរីរៈក៏ដទៃក្តី កាលបើព្រះមានព្រះភាគ មិនជ្រាប មិនឃើញហើយ ក៏ត្រូវគ្នានឹងខ្ញុំព្រះអង្គដែលមិនដឹងមិនឃើញដែរ ។ បើព្រះមានព្រះភាគ ជ្រាបថា សត្វស្លាប់ហើយកើតទៀត សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា សត្វស្លាប់ហើយកើតទៀតដូច្នេះ ឱ្យទាន បើព្រះមានព្រះភាគ ជ្រាបថា សត្វស្លាប់ហើយមិនកើតទៀត សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា សត្វស្លាប់ហើយមិនកើតទៀតដូច្នេះ ឱ្យទាន បើព្រះមានព្រះភាគ មិនជ្រាបថា សត្វស្លាប់ហើយកើតទៀតក្តី ថា សត្វស្លាប់ហើយមិនកើតទៀតក្តី កាលបើព្រះមានព្រះភាគ មិនជ្រាប មិនឃើញហើយ ក៏ត្រូវគ្នានឹងខ្ញុំព្រះអង្គ ដែលមិនដឹង មិនឃើញដែរ ។ បើព្រះមាន





ព្រះភាគ ជ្រាបថា សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះ ឱ្យទាន បើព្រះមានព្រះភាគ ជ្រាបថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះ ឱ្យទាន បើព្រះមានព្រះភាគ មិនជ្រាបថា សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានក្តី ថា សត្វកើតស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី កាលបើព្រះមានព្រះភាគ មិនជ្រាប មិនឃើញហើយ ក៏ត្រូវគ្នានឹងខ្ញុំព្រះអង្គ ដែលមិនដឹង មិនឃើញដែរ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលមាលុង្ក្យបុត្រ ចុះតថាគត បាននិយាយនឹងអ្នកយ៉ាងនេះថា ម្នាលមាលុង្ក្យ បុត្រ អ្នកចូរមកអាយ អ្នកចូរប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់តថាគតចុះ តថាគតនឹងសំដែងប្រាប់អ្នកថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃសរីរៈក៏ដទៃដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយ

មិនកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ឬអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នេះទេ ។ ចុះអ្នកបាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះមានព្រះភាគ ឱ្យតែព្រះមានព្រះភាគ នឹងសំដែងប្រាប់ខ្ញុំព្រះអង្គថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃ សរីរៈក៏ដទៃដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ឬអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នេះទេ ។ ម្នាលមាលុង្ក្យបុត្រ បានឮថា តថាគត មិនបាននិយាយនឹងអ្នកថា ម្នាលមាលុង្ក្យបុត្រ អ្នកចូរមកអាយ ចូរអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់តថាគតចុះ តថាគតនឹងសំដែងប្រាប់អ្នកថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី ។បេ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ទាំងបានឮថា អ្នកក៏





មិនបាននិយាយថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះមានព្រះភាគ ឱ្យតែព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី ។បេ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ម្នាលមោឃបុរស កាលបើហេតុយ៉ាងនេះទេ ចុះអ្នកជាអុក ជាទុក្ខ ប្រាប់អ្នកណា ។

ម្នាលមាលុង្ក្យបុត្រ បុគ្គលណា និយាយយ៉ាងនេះថា ខ្ញុំមិនទាន់ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះមានព្រះភាគទេ ព្រោះព្រះមានព្រះភាគ មិនទាន់សំដែងប្រាប់ខ្ញុំព្រះអង្គថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី ។បេ។ សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ម្នាលមាលុង្ក្យ - បុត្រ តថាគតនឹងសំដែងនូវដំណើរនោះឱ្យស្តាប់មិនទាន់ទេ បុគ្គលនោះមុខជានឹងធ្វើមរណកាលទៅ (មុនសំដែង ) ដោយពិត ។ ម្នាលមាលុង្ក្យបុត្រ ដូចជា បុរសមុតព្រួញ (របស់សេនានៃស្តេចដទៃ ) ដែលលាបប្រឡាក់ដោយថ្នាំពិសដ៏ក្រាស់ មិត្តអាមាត្យញាតិនិងសាលោហិតរបស់បុរសនោះ ក៏ចូលទៅរកពេទ្យជាអ្នកវះ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំ

មិនទាន់ស្គាល់បុរសដែលបាញ់ខ្ញុំនោះ ជាក្សត្រ ឬព្រាហ្មណ៍ ឬវេស្សៈ ឬសុទ្ទៈ នៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់បុរសដែលបាញ់ខ្ញុំនោះថាមាននាមយ៉ាងនេះ ឬមានគោត្រយ៉ាងនេះ នៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់បុរសដែលបាញ់ខ្ញុំនោះ ជាមនុស្សខ្ពស់ឬទាប ឬកណ្តាលនៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់បុរសដែលបាញ់ខ្ញុំនោះ ជាមនុស្សសម្បុរខ្មៅ ឬសណ្តែកបាយ ឬប្រផេះនៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់បុរសដែលបាញ់ខ្ញុំនោះនៅស្រុកឬនិគម ឬនគរឯណោះៗនៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ធ្នូដែលប្រើបាញ់ខ្ញុំនោះជាធ្នូ ឬកៅទណ្ឌប្រភេទណានៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ខ្សែបន្លោះដែលបាញ់ខ្ញុំនោះ ជាសម្បករាក់ ឬពន្លុងឫស្សី ជាសរសៃសត្វ ឬសម្បកខ្លែងព័រ ឬវល្លិទឹកដោះនៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់





ព្រួញដែលមុតខ្ញុំនោះ ជាព្រួញឈើព្រៃ ឬ ព្រួញឈើដែលគេដាំនៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ ព្រួញដែលមុតខ្ញុំនោះ ជាព្រួញដែលគេសៀតដោយស្លាបណា សត្វនោះជាត្មាត ឬប្រមង់ខ្លែង ឬក្ងោក ឬទុង នៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ព្រួញដែលមុតខ្ញុំនោះ ជាព្រួញដែលគេរុំដោយសរសៃគោ ឬក្របី សរសៃសីហៈខ្មៅឬស្វា នៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ព្រួញដែលមុតខ្ញុំនោះ ជាព្រួញមានមុខមូល ឬមានមុខសំប៉ែតដូចមុខកាំបិត ព្រួញមានងៀង ឬមានមុខស្រោបដែក ព្រួញមានមុខដូចពន្លាក ឬព្រួញធ្វើអំពីទ្រនុងធាងទ្រាំងនៅឡើយ ។ ម្នាលមាលុង្ក្យបុត្រ បុរសនោះចាំដឹងដំណឹងនោះមិនទាន់ទេ មុខជាបុរសនោះនឹងធ្វើមរណកាលទៅពុំខាន ។ ម្នាលមាលុង្ក្យបុត្រ បុគ្គលណានិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះមានព្រះភាគទេ ព្រោះព្រះមានព្រះភាគ មិនទាន់សំដែងប្រាប់ខ្ញុំថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្តី

ជីវិតដទៃ សរីរៈក៏ដទៃដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ម្នាលមាលុង្ក្យបុត្រ តថាគតមិនសំដែងដំណើរនោះឱ្យស្តាប់ទេ បុគ្គលនោះ មុខជានឹងធ្វើមរណកាលទៅពុំខាន មានឧបមេយ្យ ដូចជាបុរសដែលត្រូវព្រួញមុតនោះឯង ។

ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា លោកទៀងដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា លោកមិនទៀងដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា លោកទៀង ឬថាលោកមិនទៀងដូច្នេះហើយ ជាតិក៏មាន ជរាក៏មាន មរណៈក៏មាន សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតូចចិត្ត សេចក្តីក្រៀមក្រំចិត្តក៏មាន ជាធម៌ដែលតថាគតបញ្ញត្តថា មានសេចក្តីវិនាសក្នុងបច្ចុប្បន្ន ។ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា លោកមានទីបំផុតដូច្នេះហើយ សេចក្តី





យល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា លោកមិនមានទីបំផុតដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា លោកមានទីបំផុត ឬថាលោកមិនមានទីបំផុតដូច្នេះហើយ ជាតិក៏មាន ជរាក៏មាន សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតូចចិត្ត សេចក្តីក្រៀមក្រំចិត្តក៏មាន ជាធម៌ដែលតថាគតបញ្ញត្តថា មានសេចក្តីវិនាសក្នុងបច្ចុប្បន្ន ។ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា ជីវិតនោះក៏គឺសរីរៈនោះ ដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមានដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា ជីវិតដទៃ សរីរៈក៏ដទៃដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា ជីវិតនោះក៏គឺសរីរៈនោះ ឬថា ជីវិតដទៃ សរីរៈក៏ដទៃដូច្នេះហើយ ជាតិក៏មាន ។បេ។ បញ្ញត្តថាមានសេចក្តីវិនាស ។ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា សត្វស្លាប់ហើយកើតទៀតដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំ

ព្រហ្មចរិយធម៌ នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា សត្វស្លាប់ហើយមិនកើតទៀត ដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា សត្វស្លាប់ហើយកើតទៀត ឬថា សត្វស្លាប់ហើយមិនកើតទៀតដូច្នេះហើយ ជាតិក៏មាន ។បេ។ ជាធម៌ដែលតថាគតបញ្ញត្តថាមានសេចក្តីវិនាសក្នុងបច្ចុប្បន្ន ។ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន ដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា សត្វស្លាប់ហើយកើតទៀត ក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន ឬថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះហើយ ជាតិក៏មាន ជរាក៏មាន មរណៈក៏មាន សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតូចចិត្ត សេចក្តី



ក្រៀមក្រំចិត្តក៏មាន ជាធម៌ដែលតថាគតបញ្ញត្តថា មានសេចក្តីវិនាសក្នុងបច្ចុប្បន្ន ។

ម្នាលមាលុង្ក្យបុត្រ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរចាំទុកនូវសេចក្តី ដែលតថាគតមិនបានសំដែងហើយ តាមសេចក្តីដែលតថាគតមិនបានសំដែង ទាំងចូរចាំទុកនូវសេចក្តី ដែលតថាគតបានសំដែងហើយ តាមសេចក្តីដែលតថាគតបានសំដែងចុះ ។ ម្នាលមាលុង្ក្យបុត្រ ចុះតថាគតមិនបានសំដែងសេចក្តីដូចម្តេចខ្លះ ម្នាលមាលុង្ក្យបុត្រ តថាគតមិនបានសំដែងថា លោកទៀង ម្នាលមាលុង្ក្យបុត្រ តថាគតមិនបានសំដែងថា លោកមិនទៀង ម្នាលមាលុង្ក្យបុត្រ តថាគតមិនបានសំដែងថា លោកមានទីបំផុត ម្នាលមាលុង្ក្យបុត្រ តថាគតមិនបានសំដែងថា លោកមិនមានទីបំផុត ម្នាលមាលុង្ក្យបុត្រ តថាគតមិនបានសំដែងថា ជីវិតនោះក៏គឺសរីរៈនោះ តថាគតមិនបានសំដែងថា ជីវិតដទៃ សរីរៈក៏ដទៃ តថាគតមិនបានសំដែងថា សត្វស្លាប់ហើយកើតទៀត តថាគតមិនបានសំដែងថា សត្វស្លាប់ហើយមិនកើតទៀត តថាគតមិនបានសំដែងថា សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន តថាគតមិនបានសំដែងថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។ ម្នាលមាលុង្ក្យបុត្រ ព្រោះ

ហេតុអ្វីបានជាតថាគតមិនសំដែងទិដ្ឋិនុ៎ះ ម្នាលមាលុង្ក្យបុត្រ ព្រោះទិដ្ឋិនោះមិនប្រកបដោយប្រយោជន៍ មិនមែនជាខាងដើមនៃព្រហ្មចរិយធម៌ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាករាគៈ មិនប្រព្រឹត្តទៅដើម្បីសេចក្តីរំលត់ទុក្ខ មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីសេចក្តីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីសេចក្តីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ព្រោះហេតុនោះ បានជាតថាគតមិនសំដែងទិដ្ឋិនោះ ។ ម្នាលមាលុង្ក្យបុត្រ ចុះសេចក្តីដូចម្តេចដែលតថាគតតែងសំដែង ម្នាលមាលុង្ក្យបុត្រ តថាគតតែងសំដែងថា នេះជាទុក្ខ ម្នាលមាលុង្ក្យបុត្រ តថាគតតែងសំដែងថា នេះជាហេតុប្រជុំកើតឡើងនៃទុក្ខ តថាគត តែងសំដែងថា នេះជាទីរលត់ទុក្ខ តថាគតតែងសំដែងថា នេះសេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ម្នាលមាលុង្ក្យបុត្រ ហេតុដូចម្តេចបានជាតថាគតសំដែងពាក្យនុ៎ះ ម្នាលមាលុង្ក្យបុត្រ ព្រោះថាពាក្យនុ៎ះប្រកបដោយប្រយោជន៍ ពាក្យនុ៎ះជាខាងដើមនៃព្រហ្មចរិយធម៌ ពាក្យនុ៎ះប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ប្រព្រឹត្តទៅដើម្បីប្រាសចាករាគៈ ប្រព្រឹត្តទៅដើម្បីសេចក្តីរំលត់ទុក្ខ ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ប្រព្រឹត្តទៅដើម្បីសេចក្តីដឹងច្បាស់ ប្រព្រឹត្តទៅដើម្បី





សេចក្តីត្រាស់ដឹង ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ព្រោះហេតុនោះ បានជាតថាគតសំដែងពាក្យនោះ ។ ម្នាលមាលុង្ក្យបុត្រ ព្រោះហេតុនោះ អ្នកទាំងឡាយចូរចាំទុកនូវសេចក្តីដែលតថាគតមិនបានសំដែងហើយ តាមសេចក្តីដែលតថាគតមិនបានសំដែងហើយផង ចូរចាំទុកនូវសេចក្តីដែលតថាគតបានសំដែងហើយ តាមសេចក្តីដែលតថាគតបានសំដែងហើយផង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងព្រះសូត្រនេះចប់ហើយ ព្រះមាលុង្ក្យបុត្រដ៏មានអាយុ ក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

សារៈសំខាន់របស់វិធីគិតពិចារណាតាមបែបអរិយសច្ចនេះ គឺត្រូវចាប់ផ្តើមអំពីបញ្ហា ដោយការកំណត់ដឹង ឬដោយការយល់ច្បាស់លាស់ត្រឹមត្រូវនូវបញ្ហាគឺសេចក្តីទុក្ខនោះឯង ។ បន្ទាប់មកគឺការស្រាវជ្រាវរកហេតុដើម្បីនឹងលះបង់។ ក្នុងពេលជាមួយគ្នានោះត្រូវកំណត់ទិសដៅរបស់ខ្លួនឱ្យបានច្បាស់ពិតប្រាកដថាជាអ្វី នឹងប្រព្រឹត្តទៅបានឬទេ ហើយប្រព្រឹត្តទៅបានយ៉ាងណា ។ បន្ទាប់មកគឺត្រូវគិតដាក់វិធីបដិបត្តិដែលអាចកម្ចាត់នូវហេតុនៃបញ្ហា មានការស្របគ្នានឹងផលសម្រេច គឺទិសដៅដែលបានកំណត់ទុកហើយ ។

ក្នុងការដែលមាននូវយោនិសោមនសិការតាមវិធីនេះ គឺត្រូវតែគិតឱ្យធ្ងន់ដល់កិច្ច ឬនាទីដែលគប្បីបដិបត្តិចំពោះអរិយសច្ចនីមួយៗ ឱ្យបានយ៉ាងត្រឹមត្រូវ ដូចជាត្រូវបដិបត្តិកំណត់ដឹងនូវទុក្ខជាដើម ។ ដើម្បីបញ្ជាក់សេចក្តីក្នុងកិច្ចការនេះ សូមពោលដល់គោលអរិយសច្ច និងវិធីបដិបត្តិដោយសង្ខេបដូចតទៅ :

**ទុក្ខ** គឺជាតួបញ្ហាដែលកើតមានដល់ជីវិតមនុស្សសត្វ បើពោលដោយបរមត្ថ គឺជាសង្ខារធម៌ ឬជាឧបាទានក្ខន្ធ ៥ ។ សង្ខារធម៌ធ្លាក់ចូលក្នុងអំណាចនៃច្បាប់ធម្មតា ជារបស់មិនទៀង ជាទុក្ខព្រោះត្រូវបែកធ្លាយ និងជាអនត្តា ព្រោះថាប្រព្រឹត្តទៅតាមតែហេតុ តាមតែបច្ច័យ មិនមានប្រព្រឹត្តទៅតាមអំណាចខ្លួនឯងឡើយ ។

ចំពោះទុក្ខសច្ច យើងមាននាទីត្រឹមតែកំណត់ដឹង គឺត្រូវធ្វើនូវការយល់ដឹង និងកំណត់ព្រំដែនឱ្យបានច្បាស់លាស់ ដូចជាពេទ្យបានកំណត់ដឹង ឬត្រួតពិនិត្យដឹងថា វាជារោគអ្វីដូច្នោះឯង ។ នាទីនេះហៅថា **បរិញ្ញា** ជានាទីរបស់បញ្ញា ពោលគឺបញ្ញាធ្វើការកំណត់ដឹង ។

ក្នុងនាទីនេះគឺមិនត្រូវយកទុក្ខមកគិតខ្វល់ មកទូលរែកឱ្យជាភារៈធ្ងន់ ឬត្រូវទាស់ ត្រូវក្រោធ ត្រូវបដិបក្ខជាមួយទុក្ខនោះ





ឡើយ ឬថាត្រូវខ្វល់ដោយការហួងហែងគិតចង់ឱ្យអស់ទុក្ខនោះក៏ទេដែរ ព្រោះវាមានតែធ្វើឱ្យទុក្ខច្រើនឡើងថែមទៀត ។ យើងចង់លះបង់នូវទុក្ខ នេះមិនជាអ្វីឡើយ តែយើងមិនអាចលះបង់នូវទុក្ខបានដោយការចង់ឡើយ ។ យើងត្រូវលះបង់ទុក្ខដោយការស្គាល់ទុក្ខ និងការកម្ចាត់បង់នូវហេតុរបស់ទុក្ខហ្នឹងឯង ។

ចំពោះទុក្ខសច្ចនេះ ក្រៅអំពីការកំណត់ដឹងហើយ គឺនៅមានការដាក់ចិត្តដាក់គំនិតទៅតាមគតិធម្មតា ដូចដែលបានពោលហើយនៅក្នុង **ថ្នាក់ទី ១** នៃ **វិធីគិតពិចារណាតាមបែបត្រៃលក្ខណ៍** ។ កាលដែលបានកំណត់ដឹងនូវទុក្ខ ឬយល់ពីទុក្ខ ដែលហៅថា ធ្វើ **បរិញ្ញាកិច្ច** ដូច្នេះហើយ ក៏ជាការបដិបត្តិនូវកិច្ច នាទីចំពោះទុក្ខសច្ចបានសម្រេចដោយពិត ។

**សមុទ័យ** គឺហេតុដែលនាំឱ្យទុក្ខកើតឡើង ឬជាមូលហេតុនៃបញ្ហា ។ តណ្ហាជាហេតុនៃកង្វល់ ជាហេតុនៃការចង្អៀតចង្អល់ និងជាហេតុនៃការខ្វះខាត ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា «កាមទាំងឡាយមានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀត-ចង្អល់ច្រើន » ។

យើងត្រូវបដិបត្តិស្វែងរកហេតុនៃទុក្ខឱ្យឃើញ ហើយធ្វើនូវកិច្ចនាទីចំពោះហេតុ គឺតណ្ហានោះឱ្យបានត្រឹមត្រូវ គឺ **បហាន**

បានដល់កម្ចាត់ឬលះបង់ ។

តួហេតុជាទុក្ខសមុទយៈដែលនៅមានជាប្រចាំក្នុងជីវិត គូជាមួយនឹងទុក្ខសច្ច ប្រព្រឹត្តទៅជាវដ្តទុក្ខ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថា តណ្ហាជាទុក្ខសមុទយៈ គឺហេតុនៃសេចក្តីទុក្ខ និងម្យ៉ាងទៀត ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីការទាក់ទងតៗគ្នានៃដំណើរសង្ខារធម៌ ចាប់ផ្តើមពីអវិជ្ជាតាមគោលបដិច្ចសមុប្បាទធម៌ ។

**និរោធ** គឺទីរលត់ទុក្ខ ឬការផុតចាកទុក្ខ ផុតចាកបញ្ហា ជាចំណុចទិសដៅដែលគ្រប់គ្នាត្រូវការ និងត្រូវធ្វើឱ្យជាក់ច្បាស់ ត្រូវធ្វើឱ្យពិតប្រាកដ ត្រូវធ្វើឱ្យសម្រេច ត្រូវធ្វើឱ្យដល់ កិច្ចនាទីនេះហៅថា **សច្ឆិកិរិយា** ។

និរោធសច្ចនេះ ជាចំណុចទិសដៅដែលគ្រប់គ្នាត្រូវការ ព្រោះថាជាការរួចផុតចាកទុក្ខ គ្រាន់តែមនុស្សយើងដែលមិនទាន់បានជាក់ច្បាស់ ក៏មានការសង្ស័យក្នុងន័យដែលថា តើផុតចាកទុក្ខយ៉ាងណា តើបានសុខយ៉ាងដូចម្តេច បើព្រះនិព្វានមិនមានខន្ធ មិនមានការសោយអារម្មណ៍ ឬជាអនត្តាមិនមានតួខ្លួនផងនោះ ។

និរោធសច្ច គឺព្រះនិព្វានជាធម៌ដែលត្រូវជាក់ច្បាស់ដោយបញ្ញា ដូច្នេះអ្នកបដិបត្តិ ត្រូវកំណត់ឱ្យបានថា ចំណុចទិសដៅដែលត្រូវការគឺអ្វី អាចប្រព្រឹត្តទៅបានឬទេ ត្រូវប្រព្រឹត្តយ៉ាងណា មាន





គោលបដិបត្តិយ៉ាងដូចម្តេចទើបអាចចូលទៅដល់ និងមានការកាត់បន្ថយនូវទុក្ខយ៉ាងណាខ្លះ ក្នុងរវាងនៃការបដិបត្តិ ។

**មគ្គ** គឺផ្លូវទៅកាន់ទីរលត់ទុក្ខ ឬធម៌បដិបត្តិឱ្យដល់ទីរលត់ទុក្ខ បានដល់វិធីការកែខៃដោះស្រាយនូវបញ្ហា កម្ចាត់ហេតុ កម្ចាត់បច្ច័យនៃសេចក្តីទុក្ខ ដើម្បីឱ្យបានចូលដល់ទិសដៅដែលត្រូវការ ។

កិច្ចបដិបត្តិនេះ ជា **ភាវេតព្វកិច្ច** គឺជាកិច្ចត្រូវធ្វើឱ្យច្រើន ត្រូវអប់រំ ត្រូវចម្រើន ។ ធម៌បដិបត្តិដែលជាធម៌ត្រូវចម្រើននេះ គឺត្រូវឱ្យស្របគ្នានឹងចំណុចទិសដៅដែលត្រូវការ គឺបដិបត្តិកម្ចាត់កិលេសដែលជាហេតុនៃទុក្ខ មានសេចក្តីសុខបណ្តើរៗ រហូតដល់អស់ទុក្ខ ។

« បិដកលេខ ៤១ ,ទំព័រ ១៨៩ »

ម្នាលភិក្ខុទាំងឡាយ ទុក្ខអរិយសច្ច តើដូចម្តេច ។ គឺជាតិ-ទុក្ខ ជរាទុក្ខ មរណទុក្ខ សោកទុក្ខ បរិទេវទុក្ខ ទុក្ខទុក្ខទោមនស្សទុក្ខ ឧបាយាសទុក្ខ អប្បិយេហិ សម្បយោគទុក្ខ បិយេហិវិប្បយោគទុក្ខ យម្បិច្ឆំ ន លភតិ តម្បិទុក្ខ សង្ខិត្តេន បញ្ចុបា-ទានក្ខន្ធទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាទុក្ខអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខសមុទយអរិយសច្ច តើដូចម្តេច ។ គឺសង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះ

សង្ខារជាបច្ច័យ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតមានព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ សេចក្តីសោកខ្សឹកខ្សួលទុក្ខទោមនស្ស តានតឹងក៏កើតមានព្រម ។ សេចក្តីកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខសមុទយអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខនិរោធអរិយសច្ច តើដូចម្តេច ។ សេចក្តីរលត់សង្ខារ ព្រោះវិនាសព្រោះរលត់មិនមានសេសសល់នៃអវិជ្ជា សេចក្តីរលត់វិញ្ញាណ ព្រោះរលត់សង្ខារ សេចក្តីរលត់នាមរូប ព្រោះរលត់វិញ្ញាណ សេចក្តីរលត់សឡាយតនៈ ព្រោះរលត់នាមរូប សេចក្តីរលត់ផស្សៈ ព្រោះរលត់សឡាយតនៈ សេចក្តីរលត់វេទនា ព្រោះរលត់ផស្សៈ សេចក្តីរលត់តណ្ហា ព្រោះរលត់វេទនា សេចក្តីរលត់ឧបាទាន ព្រោះរលត់តណ្ហា សេចក្តីរលត់ភព ព្រោះរលត់ឧបាទាន សេចក្តីរលត់ជាតិ ព្រោះរលត់ភព សេចក្តីចាស់ ស្លាប់ រលត់ ព្រោះរលត់ជាតិ សេចក្តី





សោកខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងការចង្អៀតចង្អល់ចិត្តទាំងឡាយក៏រលត់ទៅ ។ សេចក្តីរលត់នៃកងទុក្ខទាំងអស់នេះ តែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខនិរោធអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខនិរោធ-គាមិនីបដិបទាអរិយសច្ច តើដូចម្តេច ។ មគ្គប្រកប ដោយអង្គ ៨ ដ៏ប្រសើរនេះឯង គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ និង សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។

☆ ☆ ☆

## ៥-វិធីគិតពិចារណាតាមបែបដំណើរការ បដិបត្តិនិងទិសដៅ

វិធីគិតពិចារណានេះ មានសេចក្ដីសំខាន់ណាស់ ក្នុងការចូលខ្លួនមកបដិបត្តិធម៌ ឬការធ្វើនូវកិច្ចការយ៉ាងណាមួយ ដើម្បីឱ្យបានផលដែលជាទិសដៅនៃជីវិត កុំឱ្យមានការឃ្វៀងឃ្វាតទៅជាមិនបានប្រយោជន៍សមតាមប្រាថ្នា ។

ដំណើរការបដិបត្តិ គឺជា **ធម្ម** ជាគោលបដិបត្តិ រួមទាំងពាក្យទូន្មានប្រៀនប្រដៅប្រាប់ឱ្យធ្វើការបដិបត្តិបានត្រឹមត្រូវផង ។

ទិសដៅជា **អត្ថ** បានដល់ផលប្រយោជន៍ដែលត្រូវបានសម្រេចពីការបដិបត្តិហ្នឹងឯង ។

ក្នុងការបដិបត្តិធម៌ ឬក្នុងការធ្វើនូវកិច្ចការអ្វីក៏ដោយ គឺត្រូវយល់អំពីផលសម្រេចដែលជាអត្ថប្រយោជន៍ តើបដិបត្តិដើម្បីអ្វី មានការនាំទៅរកផលយ៉ាងណាខ្លះ ផលជាចុងក្រោយ គឺជាអ្វី និងផលជាបណ្ដើរៗ គឺជាអ្វីដែរ ។

ការយល់អំពី **ធម្ម** និង **អត្ថ** នេះ នាំឱ្យមានការបដិបត្តិត្រឹមត្រូវ ដែលហៅថា **ធម្មានុធម្មប្បដិបត្តិ** ។





ធម្មានុធម្មប្បដិបត្តិ ជាធម៌សំខាន់ណាស់ ព្រោះជាការបដិបត្តិសមគួរដល់ធម៌ បដិបត្តិត្រូវ បដិបត្តិស្របតាមអត្ថ បដិបត្តិសមគួរដល់លោកុត្តរធម៌ ។ បើមិនមានធម្មានុធម្មប្បដិបត្តិទេ ការបដិបត្តិធម៌ ឬដំណើរជីវិតរមែងឃ្វៀងឃ្វាត ខុសផ្លូវ ប្រាសចាកប្រយោជន៍ និងអាចមានផលជាទុក្ខជាទោសទៀតផង ។

**ធម្ម** គ្រប់យ៉ាងរមែងមាន **អត្ថ** ដំណើរការបដិបត្តិរមែងមានទិសដៅ បើនឹងធ្វើអ្វី ត្រូវគិតថា ដើម្បីអ្វី នឹងសម្រេចផលដល់ទិសដៅបានយ៉ាងណា ។

នៅក្នុងផ្លូវធម៌ ព្រះសម្មាសម្ពុទ្ធទ្រង់សង្កត់ធ្ងន់ក្នុងសេចក្ដីសំខាន់នៃការគិតពិចារណា ទាក់ទងនៅក្នុងសេចក្ដីនេះខ្លាំងណាស់ ទាំងក្នុងផ្នែកគុណសម្បត្តិរបស់បុគ្គល ទាំងក្នុងផ្នែកលំដាប់ថ្នាក់នៃការបដិបត្តិ ។

ផ្នែកគុណសម្បត្តិរបស់បុគ្គល ដូចជា សប្បុរិសធម៌ ៧ ប្រការ និងបដិសម្ភិទា ៤ ជាដើម ។

ផ្នែកលំដាប់ថ្នាក់នៃការបដិបត្តិ ដូចជា បញ្ញាវុឌ្ឍិធម៌ ជាដើម ។

ដើម្បីជួយជ្រោមជ្រែងឱ្យកាន់តែយល់ច្បាស់ឡើង យើងនឹងសិក្សានូវព្រះពុទ្ធវចនៈដូចតទៅ :

« បិដកលេខ ៤៧ , ទំព័រ ២០៦ »

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្ត ដ៏ប្រសើររបស់សត្វលោក ។ ប្រកបដោយធម៌ ៧ យ៉ាងតើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកដឹងនូវធម៌ ១ ដឹងនូវអត្ថ (របស់ធម៌)១ ដឹងខ្លួន ១ ដឹងប្រមាណ ១ ដឹងកាលគួរ ១ ដឹងបរិសទ្យ ១ ដឹងបុគ្គលដែលគួរគប់រក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកដឹងនូវធម៌ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងនូវធម៌ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្ម វេទល្លៈ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុ មិនគប្បីដឹងនូវធម៌គឺ សុត្តៈ...វេទល្លៈទេ តថាគត មិនគប្បីហៅថា ជាអ្នកដឹងនូវធម៌ក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកឯភិក្ខុដឹងនូវធម៌គឺ សុត្តៈ...វេទល្លៈ ព្រោះហេតុនោះ ទើបតថាគតហៅថា អ្នកដឹងនូវធម៌ ភិក្ខុជាអ្នកដឹងនូវធម៌ យ៉ាងនេះឯង ។ ចុះភិក្ខុអ្នកដឹងនូវអត្ថ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងនូវអត្ថនៃភាសិតនោះៗថា នេះជាអត្ថរបស់ភាសិតនេះ នេះជាអត្ថរបស់ភាសិតនេះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុ មិនដឹងនូវអត្ថនៃ



ភាសិតនោះៗថា នេះជាអត្ថរបស់ភាសិតនេះ នេះជាអត្ថរបស់ភាសិតនេះទេ តថាគតមិនហៅថា អ្នកដឹងនូវអត្ថក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកឯភិក្ខុដឹងនូវអត្ថរបស់ភាសិតនុ៎ះៗថា នេះជាអត្ថរបស់ភាសិតនេះ នេះជាអត្ថរបស់ភាសិតនេះ ព្រោះហេតុនេះ ទើបតថាគតហៅថា អ្នកដឹងនូវអត្ថ អ្នកដឹងនូវធម៌ ដឹងនូវអត្ថ យ៉ាងនេះឯង ។ ចុះភិក្ខុដឹងនូវខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងខ្លួនថា អាត្មាអញជាអ្នកប្រកបដោយសទ្ធា មានសីលៈ សុតៈ ចាគៈ បញ្ញា បដិភាណៈ ត្រឹមប៉ុណ្ណេះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុ មិនដឹងខ្លួនថា អាត្មាអញជាអ្នកប្រកបដោយសទ្ធា មានសីលៈ សុតៈ ចាគៈ បញ្ញា បដិភាណៈ ត្រឹមប៉ុណ្ណេះទេ តថាគតមិនហៅថា អ្នកដឹងខ្លួនក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកឯភិក្ខុ អ្នកដឹងខ្លួនថា អាត្មាអញជាអ្នកប្រកបដោយសទ្ធា មានសីលៈ សុតៈ ចាគៈ បញ្ញា បដិភាណៈ ត្រឹមប៉ុណ្ណេះ ព្រោះហេតុនោះ ទើបតថាគតហៅថា អ្នកដឹងខ្លួន ភិក្ខុអ្នកដឹងធម៌ ដឹងអត្ថ ដឹងខ្លួន យ៉ាងនេះឯង ។ ចុះភិក្ខុ អ្នកដឹងប្រមាណ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងប្រមាណក្នុងការទទួលនូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ។ ម្នាលភិក្ខុទាំងឡាយ

បើភិក្ខុ មិនដឹងប្រមាណ ក្នុងការទទួលចីវរបិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទេ តថាគតមិនហៅថា អ្នកដឹងប្រមាណ ក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងភិក្ខុដឹងប្រមាណ ក្នុងការទទួល ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ព្រោះហេតុនោះ ទើបតថាគតហៅថា អ្នកដឹងប្រមាណ ភិក្ខុអ្នកដឹងធម៌ ដឹងអត្ថ ដឹងខ្លួន ដឹងប្រមាណ យ៉ាងនេះឯង ។ ចុះភិក្ខុអ្នកដឹងនូវកាល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងនូវកាលថា នេះជាកាលគួររៀនបាលី នេះជាកាលគួរសាកសួរ នេះជាកាលគួរប្រកប នេះជាកាលគួរពួនសម្ងំ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុ មិនដឹងនូវកាលថា នេះជាកាលគួររៀនបាលី នេះជាកាលគួរសាកសួរ នេះជាកាលគួរប្រកប នេះជាកាលគួរពួនសម្ងំទេ តថាគតមិនហៅថា អ្នកដឹងកាលក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងភិក្ខុអ្នកដឹងនូវកាលថា នេះជាកាលគួររៀនបាលី នេះជាកាលគួរសាកសួរ នេះជាកាលគួរប្រកប នេះជាកាលគួរពួនសម្ងំ ព្រោះហេតុនោះ ទើបតថាគតហៅថា អ្នកដឹងនូវកាល ភិក្ខុអ្នកដឹងធម៌ ដឹងអត្ថ ដឹងខ្លួន ដឹងប្រមាណ ដឹងកាលយ៉ាងនេះឯង ។ ចុះភិក្ខុអ្នកដឹងបរិសទ្យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុង



សាសនានេះ ដឹងបរិសទ្យថា នេះជាខត្តិយបរិសទ្យ នេះជាព្រាហ្មណបរិសទ្យ នេះជាគហបតិបរិសទ្យ នេះជាសមណបរិសទ្យ អាត្មាអញ គួរចូលទៅរកយ៉ាងនេះ គួរឈរយ៉ាងនេះ គួរធ្វើយ៉ាងនេះ គួរអង្គុយយ៉ាងនេះ គួរនិយាយយ៉ាងនេះ គួរស្ងៀមយ៉ាងនេះ ចំពោះបរិសទ្យទាំងនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនដឹងបរិសទ្យថា នេះជាខត្តិយបរិសទ្យ ... គួរស្ងៀមយ៉ាងនេះ តថាគតមិនហៅថា អ្នកដឹងបរិសទ្យ ក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងភិក្ខុ ដឹងបរិសទ្យថា នេះជាខត្តិយបរិសទ្យ ... គួរស្ងៀមយ៉ាងនេះ ព្រោះហេតុនេះ ទើបតថាគតហៅថា អ្នកដឹងបរិសទ្យ ភិក្ខុអ្នកដឹងធម៌ ដឹងអត្ថ ដឹងខ្លួន ដឹងប្រមាណ ដឹងកាល ដឹងបរិសទ្យ យ៉ាងនេះឯង ។ ចុះភិក្ខុ ដឹងបុគ្គលគួរគប់រក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងដឹងច្បាស់នូវបុគ្គលពីរពួក ឯបុគ្គលពីរពួកគឺ មួយពួក ជាអ្នកចង់ជួបប្រទះពួកព្រះអរិយៈ មួយពួក មិនចង់ជួបប្រទះពួកព្រះអរិយៈ ។ បុគ្គលណាមិនចង់ជួបប្រទះពួកព្រះអរិយៈ បុគ្គលនោះ គេគប្បីតិះដៀល ដោយហេតុនោះៗយ៉ាងនេះ ។ បុគ្គលណា ចង់ជួបប្រទះពួកព្រះអរិយៈ បុគ្គលនោះ គេគប្បីសរសើរ ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលពីរពួក ចង់ជួបប្រទះពួកព្រះអរិយៈគឺ

មួយពួក ចង់ស្តាប់ព្រះសទ្ធម្ម មួយពួក មិនចង់ស្តាប់ព្រះសទ្ធម្ម ។ បុគ្គលណា មិនចង់ស្តាប់ព្រះសទ្ធម្ម បុគ្គលនោះគេគប្បីតិះដៀល ដោយហេតុនោះ១ យ៉ាងនេះ ។ បុគ្គលណា ចង់ស្តាប់ព្រះសទ្ធម្ម បុគ្គលនោះ គេគប្បីសរសើរ ដោយហេតុនោះ១ យ៉ាងនេះ ។ បុគ្គលពីរពួក ចង់ស្តាប់នូវព្រះសទ្ធម្ម គឺបុគ្គលមួយពួក មានត្រចៀក ផ្ទៀងស្តាប់នូវធម៌ បុគ្គលមួយពួក មានត្រចៀក មិនផ្ទៀងស្តាប់នូវធម៌ ។ បុគ្គលណា មានត្រចៀក មិនផ្ទៀងស្តាប់នូវធម៌ បុគ្គលនោះ គេគប្បីតិះដៀល ដោយហេតុនោះ១ យ៉ាងនេះ ។ បុគ្គលណា មានត្រចៀក ផ្ទៀងស្តាប់នូវធម៌ បុគ្គលនោះ គេគប្បីសរសើរ ដោយហេតុនោះ១ យ៉ាងនេះ ។ បុគ្គលពីរពួក មានត្រចៀក ផ្ទៀងស្តាប់នូវធម៌ គឺមួយពួក ស្តាប់ហើយចាំទុកនូវធម៌ មួយពួក ស្តាប់ហើយមិនចាំទុកនូវធម៌ ។ បុគ្គលណា ស្តាប់ហើយ មិនចាំទុកនូវធម៌ បុគ្គលនោះ គេគប្បីតិះដៀល ដោយហេតុនោះ១ យ៉ាងនេះ ។ បុគ្គលណា ស្តាប់ហើយចាំទុកនូវធម៌ បុគ្គលនោះ គេគប្បីសរសើរ ដោយហេតុនោះ១ យ៉ាងនេះ ។ បុគ្គលពីរពួក ស្តាប់ហើយចាំទុកនូវធម៌ មួយពួក ពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនចាំទុកហើយ មួយពួក មិនពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនចាំទុកហើយទេ ។ បុគ្គលណា មិនពិចារណានូវអត្ថនៃធម៌ទាំងឡាយ



ដែលខ្លួនចាំទុកហើយ បុគ្គលនោះ គេគប្បីតិះដៀល ដោយហេតុនោះ១ យ៉ាងនេះ ។ បុគ្គលណា ពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនចាំទុកហើយ បុគ្គលនោះ គេគប្បីសរសើរ ដោយហេតុនោះ១ យ៉ាងនេះ ។ បុគ្គលពីរពួក ពិចារណា នូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនចាំទុកហើយ គឺមួយពួក ដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ មួយពួក ដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយមិនប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ ។ បុគ្គលណា ដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយមិនប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ បុគ្គលនោះ គេគប្បីតិះដៀល ដោយហេតុនោះ១ យ៉ាងនេះ ។ បុគ្គលណា ដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ បុគ្គលនោះ គេគប្បីសរសើរ ដោយហេតុនោះ១ យ៉ាងនេះ ។ បុគ្គលពីរពួក ដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ គឺមួយពួក ប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន មិនប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ មួយពួក ប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង ។ បុគ្គលណា ប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន មិនប្រតិបត្តិ ដើម្បីប្រយោជន៍បុគ្គលដទៃ បុគ្គលនោះ គេគប្បីតិះដៀល ដោយហេតុនោះ១ យ៉ាងនេះ ។ បុគ្គល

ណា ប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង បុគ្គលនោះ គេគប្បីសរសើរ ដោយហេតុនោះ១ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងច្បាស់បុគ្គលពីរពួក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដឹងនូវបុគ្គលដែលគួរគប់រកយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាងនេះ ជាអ្នកគួរទទួលចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

« បិដកលេខ ៤២ , ទំព័រ ១៣ »

ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ គឺបុគ្គលចេះដឹងតិច មិនបានប្រកបដោយការចេះដឹង ១ មានសេចក្តីចេះដឹងតិច បានប្រកបដោយការចេះដឹង ១ មានសេចក្តីចេះដឹងច្រើន មិនបានប្រកបដោយការចេះដឹង ១ មានសេចក្តីចេះដឹងច្រើន ហើយបានប្រកបដោយការចេះដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានសេចក្តីចេះដឹងតិច មិនបានប្រកបដោយការចេះដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្ម





វេទល្លៈ មានតិចដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ បុគ្គលនោះមិនចេះអដ្ឋកថា មិនចេះបាលីនៃពុទ្ធវចនៈមានប្រមាណតិចនោះ មិនប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងឈ្មោះថា បុគ្គលមានសេចក្តីចេះដឹងតិចមិនបានប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានសេចក្តីចេះដឹងតិច បានប្រកបដោយការចេះដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ ។បេ។ វេទល្លៈ មានតិចដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ បុគ្គលនោះ ចេះអដ្ឋកថា ចេះបាលីនៃពុទ្ធវចនៈមានប្រមាណតិចនោះ ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងឈ្មោះថា បុគ្គលមានសេចក្តីចេះដឹងតិច បានប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានសេចក្តីចេះដឹងច្រើន តែមិនបានប្រកបដោយការចេះដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ ។បេ។ វេទល្លៈ មានច្រើនដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ បុគ្គលនោះ មិនចេះអដ្ឋកថា មិនចេះបាលីនៃពុទ្ធវចនៈមានប្រមាណច្រើននោះ មិនប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងឈ្មោះថា បុគ្គលមានសេចក្តីចេះដឹងច្រើន តែមិនបានប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុ

ទាំងឡាយ ចុះបុគ្គលមានសេចក្តីចេះដឹងច្រើន ប្រកបដោយការចេះដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្ម វេទល្លៈ មានច្រើនដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ បុគ្គលនោះចេះអដ្ឋកថា (**អត្ថមញ្ញាយ**) ចេះបាលី (**ធម្មមញ្ញាយ**) នៃពុទ្ធវចនៈមានប្រមាណច្រើននោះ ហើយប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា បុគ្គលមានសេចក្តីចេះដឹងច្រើនប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង រមែងមាននៅក្នុងលោក ។

**អប្បស្សុតោបិ ចេ ហោតិ សីលេសុ អសមាហិតោ**
**ឧភយេន នំ គរហន្តិ សីលតោ ច សុតេន ច ។**

បើបុគ្គលមានសេចក្តីចេះដឹងតិច ទាំងមិនបានឋិតនៅក្នុងសីលទាំងឡាយ អ្នកប្រាជ្ញទាំងឡាយ រមែងតិះដៀលបុគ្គលនោះដោយហេតុទាំង ២ គឺសីល ១ សេចក្តីចេះដឹង ១ ។

**អប្បស្សុតោបិ ចេ ហោតិ សីលេសុ សុសមាហិតោ**
**សីលតោ នំ បសំសន្តិ នាស្ស សម្បជ្ជតេ សុតំ ។**

បើបុគ្គលមានសេចក្តីចេះដឹងតិច តែឋិតនៅខ្ជាប់ខ្ជួនក្នុងសីលទាំងឡាយ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរបុគ្គលនោះ





តែដោយសីល ប៉ុន្តែ សេចក្តីចេះដឹង មិនសម្រេចដល់បុគ្គលនោះទេ។

**ពហុស្សុតោបិ ចេ ហោតិ សីលេសុ អសមាហិតោ**
**សីលតោ នំ គរហន្តិ តស្ស សម្បជ្ជតេ សុតំ ។**

បើបុគ្គលមានសេចក្តីចេះដឹងច្រើន តែមិនឋិតនៅក្នុងសីលទាំងឡាយទេ អ្នកប្រាជ្ញទាំងឡាយ រមែងតិះដៀលបុគ្គលនោះដោយសីល ប៉ុន្តែសេចក្តីចេះដឹងរមែងសម្រេចដល់បុគ្គលនោះ ។

**ពហុស្សុតោបិ ចេ ហោតិ សីលេសុ សុសមាហិតោ**
**ឧភយេន នំ បសំសន្តិ សីលតោ ច សុតេន ច ។**

បើបុគ្គលមានសេចក្តីចេះដឹងច្រើន ទាំងតាំងនៅខ្ជាប់ខ្ជួនក្នុងសីលទាំងឡាយ អ្នកប្រាជ្ញទាំងឡាយ រមែងសរសើរបុគ្គលនោះ ដោយហេតុទាំង ២ គឺសីល ១ សេចក្តីចេះដឹង ១ ។

**ពហុស្សុតំ ធម្មធរំ សប្បញ្ញំ ពុទ្ធសាវកំ**
**នេក្ខំ ជម្ពោនទស្សេវ កោ តំ និន្ទិតុមរហតិ**
**ទេវាបិ នំ បសំសន្តិ ព្រហ្មុនាបិ បសំសិតោតិ ។**

អ្នកណាគួរនិន្ទាបុគ្គលអ្នកមានសេចក្តីចេះដឹងច្រើន ទ្រទ្រង់នូវធម៌ប្រកបដោយបញ្ញា ជាពុទ្ធសាវ័កនោះ ដែលដូចជាដុំនៃមាសជម្ពូនទៈបាន ទេវតា និងមនុស្សទាំងឡាយ រមែងសរសើរបុគ្គល

នោះ សូម្បីព្រហ្មក៏សរសើរដែរ ។

« បិដកលេខ ៤៣ , ទំព័រ ៩០ »

គ្រានោះ ភិក្ខុមួយរូប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីដឹកនាំសត្វលោកទៅ អ្វីទង់ទាញសត្វលោកទៅ មួយទៀត សត្វលោកលុះអំណាចរបស់អ្វីដែលកើតឡើង ។ ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ សេចក្តីឆ្លាតរបស់អ្នកប្រសើរហើយ សេចក្តីវាងវៃរបស់អ្នក ចម្រើនហើយ សេចក្តីសាកសួរល្អហើយ ម្នាលភិក្ខុ ដ្បិតថា អ្នកបានសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីដឹកនាំសត្វលោកទៅ អ្វីទង់ទាញសត្វលោកទៅ មួយទៀត សត្វលោកលុះអំណាចរបស់អ្វីដែលកើតឡើង ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះមែន ។ ម្នាលភិក្ខុ ចិត្តដឹកនាំសត្វលោកទៅ ចិត្តទង់ទាញសត្វលោកទៅ សត្វលោក លុះអំណាចចិត្តដែលកើតឡើង ។ ភិក្ខុនោះ ត្រេកអរីករាយនឹងភាសិតរបស់ព្រះដ៏មានព្រះភាគថា សាធុព្រះអង្គ ហើយក៏បានសួរប្រស្នា នឹងព្រះដ៏មានព្រះភាគ តទៅ



ទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា ជាពហុស្សូតអ្នកទ្រទ្រង់ធម៌ ជាពហុស្សូតអ្នកទ្រទ្រង់ធម៌ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលជាពហុស្សូតអ្នកទ្រទ្រង់ធម៌ តើដោយហេតុដូចម្តេច ។ ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ សេចក្តីឆ្លាតរបស់អ្នកប្រសើរហើយ សេចក្តីវាងវៃរបស់អ្នកចម្រើនហើយ សេចក្តីសាកសួរល្អហើយ ម្នាលភិក្ខុ ដ្បិតអ្នកបានសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា ជាពហុស្សូតអ្នកទ្រទ្រង់ធម៌ ជាពហុស្សូតអ្នកទ្រទ្រង់ធម៌ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលជាពហុស្សូតអ្នកទ្រទ្រង់ធម៌ តើដោយហេតុដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះមែន ។ ម្នាលភិក្ខុ ធម៌ទាំងឡាយដែលតថាគត សំដែងទុកច្រើនយ៉ាង គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្ម វេទល្លៈបើភក្ខុដឹងអត្ថ (**អត្ថមញ្ញាយ** ) និងដឹងធម៌ (**ធម្មមញ្ញាយ** ) របស់គាថា ត្រឹមតែ ៤ បាទហើយ ជាអ្នកប្រតិបត្តិធម៌សមគួរដល់ធម៌ ក៏គួរហៅថា ជាពហុស្សូតអ្នកទ្រទ្រង់ធម៌បាន ។ ភិក្ខុនោះត្រេកអរីករាយនឹងភាសិតរបស់ព្រះដ៏មានព្រះភាគថា សាធុព្រះអង្គ ហើយក៏សួរ ប្រស្នានឹងព្រះដ៏មានព្រះភាគតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា បុគ្គលអ្នក

បានស្តាប់ មានប្រាជ្ញាចាក់ធ្លុះ បុគ្គលអ្នកបានស្តាប់ មានប្រាជ្ញាចាក់ធ្លុះដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលអ្នកបានស្តាប់ មានប្រាជ្ញាចាក់ធ្លុះ តើដោយហេតុដូចម្តេច ។ ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ សេចក្តីឆ្លាតរបស់អ្នកប្រសើរហើយ សេចក្តីវាងវៃរបស់អ្នកចម្រើនហើយ សេចក្តីសាកសួរល្អហើយ ម្នាលភិក្ខុ ដ្បិតថា អ្នកបានសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា បុគ្គលអ្នកបានស្តាប់ មានប្រាជ្ញាចាក់ធ្លុះ បុគ្គលអ្នកបានស្តាប់ មានប្រាជ្ញាចាក់ធ្លុះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលអ្នកបានស្តាប់ មានប្រាជ្ញាចាក់ធ្លុះ ដោយហេតុដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនេះមែន ។ ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ បានស្តាប់ថា នេះទុក្ខ ក៏ចាក់ធ្លុះយល់សេចក្តីនៃធម៌នោះដោយប្រាជ្ញា បានស្តាប់ថា នេះទុក្ខសមុទ័យ ក៏ចាក់ធ្លុះយល់សេចក្តីនៃធម៌នោះដោយប្រាជ្ញា បានស្តាប់ថា នេះទុក្ខនិរោធ ក៏ចាក់ធ្លុះយល់សេចក្តីនៃធម៌នោះដោយប្រាជ្ញា បានស្តាប់ថា នេះទុក្ខនិរោធគាមិនីបដិបទា ក៏ចាក់ធ្លុះយល់សេចក្តីនៃធម៌នោះដោយប្រាជ្ញា ម្នាលភិក្ខុ បុគ្គលអ្នកបានស្តាប់ មានប្រាជ្ញាចាក់ធ្លុះយ៉ាងនេះឯង ។ ភិក្ខុនោះ ត្រេកអររីករាយនឹងភាសិតរបស់ព្រះដ៏មានព្រះភាគថា សាធុ ព្រះអង្គ ហើយក៏សួរប្រស្នានឹង



ព្រះដ៏មានព្រះភាគតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា បណ្ឌិតអ្នកមានប្រាជ្ញាច្រើន បណ្ឌិតអ្នកមានប្រាជ្ញាច្រើន ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលជាបណ្ឌិតអ្នកមានប្រាជ្ញាច្រើន តើដោយហេតុដូចម្តេច ។ ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ ម្នាលភិក្ខុ សេចក្តីឆ្លាតរបស់អ្នកប្រសើរហើយ សេចក្តីវាងវៃរបស់អ្នកចម្រើនហើយ សេចក្តីសាកសួររបស់អ្នកល្អហើយ ដ្បិតអ្នកបានសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា បណ្ឌិតអ្នកមានប្រាជ្ញាច្រើន បណ្ឌិតអ្នកមានប្រាជ្ញាច្រើន ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលជាបណ្ឌិតអ្នកមានប្រាជ្ញាច្រើន តើដោយហេតុដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនេះមែន ។ ម្នាលភិក្ខុ ភិក្ខុជាបណ្ឌិតអ្នកមានប្រាជ្ញាច្រើនក្នុងសាសនានេះ មិនគិតដើម្បីបៀតបៀនខ្លួន មិនគិតដើម្បីបៀតបៀនអ្នកដទៃ មិនគិតបៀតបៀនទាំងពីរខាង កាលបើគិត ក៏គិតតែ ប្រយោជន៍ខ្លួន ប្រយោជន៍អ្នកដទៃ ប្រយោជន៍ទាំងពីរខាង និងប្រយោជន៍ដល់លោកទាំងមូល ម្នាលភិក្ខុ ភិក្ខុជាបណ្ឌិតអ្នកមានប្រាជ្ញាច្រើនយ៉ាងនេះឯង ។

« បិដកលេខ ៤៥ , ទំព័រ ៩៥ »

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីឱ្យ

ព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក្នុងសាសនានេះ មិនស្តាប់ធម៌ដោយគោរព ១ មិនរៀនធម៌ដោយគោរព ១ មិនទ្រទ្រង់ (ចាំទុក ) នូវធម៌ដោយគោរព ១ មិនពិចារណាអត្ថនៃធម៌ដែលខ្លួនទ្រទ្រង់ហើយដោយគោរព ១ ដឹងអត្ថ ដឹងធម៌ហើយ មិនប្រតិបត្តិធម៌តាមសមគួរដល់ធម៌ដោយគោរព ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីឱ្យព្រះសទ្ធម្មសាប-សូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីឱ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក្នុងសាសនានេះ ស្តាប់ធម៌ដោយគោរព ១ រៀនធម៌ដោយគោរព ១ ទ្រទ្រង់ធម៌ដោយគោរព ១ ពិចារណាអត្ថនៃធម៌ដែលខ្លួនទ្រទ្រង់ហើយដោយគោរព ១ ដឹងអត្ថ ដឹងធម៌ហើយ ប្រតិបត្តិធម៌តាមសមគួរដល់ធម៌ដោយគោរព ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីឱ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។

គប្បីសង្កេតគោលធម៌នៅក្នុងព្រះសូត្រនេះ ដែលជាឧបការៈត១គ្នា :



ស្តាប់និងរៀននូវធម៌ដោយគោរព → ទ្រទ្រង់ធម៌ដោយគោរព → ពិចារណាអត្ថ (**អត្ថំ ឧបបរិក្ខន្តិ** ) ដោយគោរព → ធម្មានុធម្មប្បដិបត្តិដោយគោរព ។

គោលធម៌ដូចគ្នានេះ មាននៅក្នុងព្រះសូត្រដទៃទៀតច្រើនណាស់ ដូចជាបិដកលេខ ៤២ ទំព័រ ២៤០ , បិដកលេខ៤៨ ទំព័រ ១២៩ ទំព័រ ២៧១ ទំព័រ ៣៣៣ ទំព័រ ៣៥០ , បិដកលេខ ៤៩ ទំព័រ ៧៤ , បិដកលេខ ៥០ ទំព័រ ២៧៤ ទំព័រ៣៣៤ ជាដើម ។

ដូច្នេះគោលធម៌នេះ ជាសេចក្តីសំខាន់ក្នុងការសិក្សា និងបដិបត្តិតាមគោលព្រះពុទ្ធសាសនាខ្លាំងណាស់ ។ កាលបានសិក្សានូវគោលនេះហើយ គប្បីសិក្សាប្រៀបធៀបជាមួយនឹងគោលធម៌សម្រាប់ចម្រើនបញ្ញា ឬគុណសម្បត្តិដែលធ្វើឱ្យបានជាសោតាបន្ន ៤ ប្រការ ដែលព្រះអង្គទ្រង់ត្រាស់ដូចនេះថា :

« បិដកលេខ ៤៣ , ទំព័រ ២៦២ »

ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការនេះ ប្រព្រឹត្តទៅដើម្បីចម្រើនបញ្ញា ។ ធម៌ ៤ ប្រការគឺអ្វីខ្លះ ។ គឺ **សប្បុរិសសំសេវោ** ការសេពគប់សប្បុរស ១ **សទ្ធម្មស្សវនំ** ការស្តាប់ធម៌របស់សប្បុរស ១ **យោនិសោមនសិការោ** ការយកចិត្តទុកដាក់ដោយឧបាយ ១ **ធម្មានុធម្មប្បដិបត្តិ** ការប្រព្រឹត្តនូវធម៌ដ៏សមគួរតាម

ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៤ ប្រការរមែង ប្រព្រឹត្ត ទៅដើម្បីចម្រើនបញ្ញា ។

នៅក្នុងព្រះសូត្រជាប់គ្នាព្រះអង្គទ្រង់ត្រាស់នូវធម៌ ៤ យ៉ាង ដដែលនេះថា ជាធម៌មានឧបការៈច្រើនដល់មនុស្ស ។

កាលប្រៀបធៀបគ្នាហើយ ក៏នឹងឃើញបានថា ក្នុងពួក ធម៌ដែលមាន **យោនិសោមនសិការ** មានសារៈសំខាន់ដូចគ្នា ។ ព្រះសូត្រដែលអាងខាងដើម ប្រើពាក្យថា **អត្ថំ ឧបបរិក្ខន្តិ** (ពិចារណាអត្ថ ) ជំនួសពាក្យ **យោនិសោមនសិការ** គឺជាការចាំបាច់ ក្នុងការបញ្ជាក់ន័យសេចក្តីនៃយោនិសោមនសិការ ។ កាលដែល បានយល់ **ធម្ម** និង **អត្ថ** ព្រមទាំងដំណើរការបដិបត្តិ និងទិសដៅ ស្របគ្នាល្អហើយ ក៏ឈានទៅរកធម្មានុធម្មប្បដិបត្តិ មានការ ប្រព្រឹត្តបានយ៉ាងត្រឹមត្រូវ ។

ប្រសិនបើមិនច្បាស់ថា **ធម្ម** និង **អត្ថ** មានទំនាក់ទំនងគ្នា យ៉ាងណា ជាហេតុ ជាផលយ៉ាងដូចម្តេចទេនោះ សូមលើកយក ធម៌ដែលសម្តែងអំពី **ធម្ម** និង **អត្ថ** ផ្សេងៗទៀត មានច្រើនកន្លែង មកបញ្ជាក់ពន្យល់ដូចតទៅ :

« បិដកលេខ ៥១ , ទំព័រ ២៩ »

ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈ **អធម្ម** (មិនមែន





ធម៌ )ផង សភាវៈ **អនត្ថ** (មិនមែនប្រយោជន៍ )ផង គប្បីដឹង **ធម្ម** ផង **អត្ថ** ផង លុះដឹងច្បាស់សភាវៈ **អធម្ម** ផង សភាវៈ **អនត្ថ** ផង ដឹងនូវ **ធម្ម** ផង **អត្ថ** ផងហើយ **ធម្ម** យ៉ាងណា **អត្ថ** យ៉ាងណា ភិក្ខុគប្បីបដិបត្តិតាមយ៉ាងនោះ ។

ម្នាលភិក្ខុទាំងឡាយ សភាវៈ **អធម្ម** តើដូចម្តេច **ធម្ម** តើ ដូចម្តេច សភាវៈ **អនត្ថ** តើដូចម្តេច **អត្ថ** តើដូចម្តេច ។ ម្នាល ភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិ ... មិច្ឆាសង្កប្បៈ ...មិច្ឆាវាចា ... មិច្ឆាកម្មន្តៈ ... មិច្ឆាអាជីវៈ ... មិច្ឆាវាយាមៈ ... មិច្ឆាសតិ ... មិច្ឆាសមាធិ ... មិច្ឆាញាណ ... មិច្ឆាវិមុត្តិជាសភាវៈ **អធម្ម** ។

សម្មាទិដ្ឋិ...សម្មាសង្កប្បៈ...សម្មាវាចា... សម្មាកម្មន្តៈ ... សម្មាអាជីវៈ ... សម្មាវាយាមៈ ... សម្មាសតិ ...សម្មាសមាធិ ... សម្មាញាណ ... សម្មាវិមុត្តិជា **ធម្ម** ។

ពួកអកុសលធម៌ដ៏លាមកច្រើនប្រការណា ដែលមាន មិច្ឆាទិដ្ឋិ។ល។មិច្ឆាវិមុត្តិជាបច្ច័យឱ្យកើតឡើងព្រម នេះជា **អនត្ថ**។

ពួកកុសលធម៌ច្រើនប្រការមានសម្មាទិដ្ឋិ ។ល។ សម្មាវិមុត្តិ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជា **អត្ថ** ។

នេះជាការស្រង់យកមកដោយការរួបរួម ។ បិដកលេខ ៥១ ទំព័រ ៩៨ ដល់ ១១៧ ព្រះអង្គទ្រង់សម្តែងអំពីអកុសលកម្មបថ ១០

និងកុសលកម្មបថ ១០ ក្នុងន័យដូចគ្នា ។

« បិដកលេខ ១៣ , ទំព័រ ១៩៤ »

វិន័យដើម្បី **អត្ថ** គឺប្រយោជន៍ដល់ការសង្រួម សេចក្ដីសង្រួមដើម្បីអត្ថ គឺការមិនក្ដៅក្រហាយចិត្ត សេចក្ដីមិនក្ដៅក្រហាយចិត្ត ដើម្បីអត្ថ គឺបាមុជ្ជៈ (ការរីករាយទន់ ) បាមុជ្ជៈ ដើម្បីអត្ថគឺបីតិ (ការរីករាយខ្លាំងក្លា ) បីតិដើម្បីអត្ថគឺបស្សទ្ធិ (ការស្ងប់រម្ងាប់ ) បស្សទ្ធិដើម្បីអត្ថគឺសុខ សុខដើម្បីអត្ថគឺសមាធិ សមាធិដើម្បីអត្ថគឺ យថាភូតញ្ញាណទស្សនៈ (ការដឹងសង្ខារ ដោយវិបស្សនាទន់ខ្ចី ) យថាភូតញ្ញាណទស្សនៈ ដើម្បីអត្ថគឺ និព្វិទា (ការនឿយណាយក្នុងសង្ខារដោយវិបស្សនាមានកម្លាំងខ្លាំង ) និព្វិទាដើម្បីអត្ថគឺ វិរាគៈ (ការប្រាសចាកតម្រេកដោយអរិយមគ្គ )វិរាគៈដើម្បីអត្ថគឺវិមុត្តិ (ការរួចផុតដោយអរហត្តផល ) វិមុត្តិដើម្បីអត្ថគឺវិមុត្តិញ្ញាណទស្សនៈ (បច្ចវេក្ខណញ្ញាណ ) វិមុត្តិញ្ញាណទស្សនៈដើម្បីអត្ថគឺអនុបាទាបរិនិព្វាន (ទីរលត់ទុក្ខ ) ។

« បិដកលេខ ២១ ក្នុងរថវិនីតសូត្រ »

សីលវិសុទ្ធិមានអត្ថត្រឹមតែចិត្តវិសុទ្ធិ ចិត្តវិសុទ្ធិមានអត្ថត្រឹម



តែទិដ្ឋិវិសុទ្ធិ ទិដ្ឋិវិសុទ្ធិមានអត្ថត្រឹមតែកង្ខាវិតរណវិសុទ្ធិ កង្ខា-វិតរណវិសុទ្ធិមានអត្ថត្រឹមតែមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ មគ្គា-មគ្គញ្ញាណទស្សនវិសុទ្ធិមានអត្ថត្រឹមតែបដិបទាញាណទស្សនវិសុទ្ធិ បដិបទាញាណទស្សនវិសុទ្ធិ មានអត្ថត្រឹមតែញាណទស្សនវិសុទ្ធិ ញាណទស្សនវិសុទ្ធិ មានអត្ថត្រឹមអនុបាទាបរិនិព្វាន ។

សេចក្ដីនៅក្នុងព្រះសូត្រមានដូចតទៅ :

« បិដកលេខ ២១ , ទំព័រ ៨០ »

ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង ភិក្ខុទាំងឡាយច្រើនរូប អ្នកនៅក្នុងជាតិភូមិ នៅចាំវស្សាក្នុងជាតិភូមិហើយ ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បណ្ដាជាតិភូមិកភិក្ខុទាំងឡាយ ជាសព្រហ្មចារីដែលនៅក្នុងជាតិភូមិ ភិក្ខុណាហ្ន៎ ដែលមានគេសរសើរយ៉ាងនេះថា ជាអ្នកមិនមានសេចក្ដីប្រាថ្នាដោយខ្លួនឯងផង សំដែងអំពីការមិនមានសេចក្ដីប្រាថ្នា ដល់ពួកភិក្ខុផង ជាអ្នកសន្ដោសដោយខ្លួនឯងផង សំដែងអំពីការ

សន្តោស ដល់ពួកភិក្ខុផង ជាអ្នកស្ងប់ស្ងាត់ដោយខ្លួនឯងផង សំដែងអំពីការស្ងប់ស្ងាត់ ដល់ពួកភិក្ខុផង ជាអ្នកមិនច្រឡូកច្រឡំ ដោយខ្លួនឯងផង សំដែងអំពីការមិនច្រឡូកច្រឡំ ដល់ពួកភិក្ខុផង ជាអ្នកប្រារព្ធសេចក្ដីព្យាយាម ដោយខ្លួនឯងផង សំដែងអំពីការប្រារព្ធព្យាយាម ដល់ពួកភិក្ខុផង ជាអ្នកបរិបូណ៌ដោយសីល ចំពោះខ្លួនឯងផង សំដែងអំពីការបរិបូណ៌ដោយសីល ដល់ពួកភិក្ខុផង ជាអ្នកបរិបូណ៌ដោយសមាធិចំពោះខ្លួនឯងផង សំដែងអំពីការបរិបូណ៌ដោយសមាធិ ដល់ពួកភិក្ខុផង ជាអ្នកបរិបូណ៌ដោយបញ្ញាចំពោះខ្លួនឯងផង សំដែងអំពីការបរិបូណ៌ដោយបញ្ញា ដល់ពួកភិក្ខុផង ជាអ្នកបរិបូណ៌ដោយវិមុត្តិ គឺអរិយផល ចំពោះខ្លួនឯងផង សំដែងអំពីការបរិបូណ៌ដោយវិមុត្តិ គឺអរិយផល ដល់ពួកភិក្ខុផង ជាអ្នកបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈដោយខ្លួនឯងផង សំដែងអំពីការបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈ ដល់ពួកភិក្ខុផង ជាអ្នកឱ្យឱវាទ បំភ្លឺឱ្យដឹងច្បាស់ ពន្យល់ បបួល ធ្វើឱ្យក្លាហាន ធ្វើឱ្យរីករាយ ដល់ពួកសព្រហ្មចារីផង ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន បណ្ដាជាតិភូមិកភិក្ខុទាំងឡាយជាសព្រហ្មចារី ដែលនៅក្នុងជាតិភូមិ មានតែបុណ្ណត្ថេរមានអាយុជាមន្តាណីបុត្ត (កូននៃ ព្រាហ្មណីឈ្មោះមន្តាណី )ទេ ទើបគេ



តែងសរសើរគុណ យ៉ាងនេះថា ជាអ្នកមិនប្រាថ្នា ដោយខ្លួនឯងផង សំដែងអំពីការមិនមានសេចក្ដីប្រាថ្នាដល់ពួកភិក្ខុផង ជាអ្នកសន្តោសដោយខ្លួនឯងផង ។បេ។ ជាអ្នកស្ងប់ស្ងាត់ ដោយខ្លួនឯងផង ... ជាអ្នកមិនច្រឡូកច្រឡំដោយខ្លួនឯងផង ... ជាអ្នកមានសេចក្ដីព្យាយាមដោយខ្លួនឯងផង... ជាអ្នកបរិបូណ៌ដោយសីលចំពោះខ្លួនឯងផង ... ជាអ្នកបរិបូណ៌ដោយសមាធិចំពោះខ្លួនឯងផង ... ជាអ្នកបរិបូណ៌ដោយបញ្ញាចំពោះខ្លួនឯងផង ... ជាអ្នកបរិបូណ៌ដោយវិមុត្តិចំពោះខ្លួនឯងផង ... ជាអ្នកបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈដោយខ្លួនឯងផង សំដែងអំពីការបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈ ដល់ពួកភិក្ខុផង ជាអ្នកឱ្យឱវាទ បំភ្លឺឱ្យដឹងច្បាស់ ពន្យល់ បបួល ធ្វើឱ្យក្លាហាន ធ្វើឱ្យរីករាយដល់ពួកសព្រហ្មចារីផង ។

សម័យនោះឯង ព្រះសារីបុត្តមានអាយុ អង្គុយក្បែរព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះសារីបុត្តមានអាយុ មានសេចក្ដីត្រិះរិះដូច្នេះថា បុណ្ណមន្តាណីបុត្តមានអាយុហៅពេញជាមានលាភទាំងអត្តភាពជាមនុស្ស ក៏បុណ្ណមន្តាណីបុត្តបានហើយដោយប្រពៃ (ព្រោះ ) ពួកសព្រហ្មចារីភិក្ខុដែលជាអ្នកប្រាជ្ញពិចារណារឿយៗ ហើយតែងពោលសរសើរក្នុងទីចំពោះព្រះភក្ត្រនៃព្រះសាស្ដា ព្រះ

សាស្តាក៏ទ្រង់អនុមោទនាចំពោះបុណ្ណមន្តាណីបុត្តនោះ ធ្វើដូចម្តេច ទើបយើងនឹងបានទៅកាន់ទីប្រជុំជាមួយនឹងព្រះបុណ្ណមន្តា-ណីបុត្តមានអាយុម្តងហ្ន៎ ធ្វើដូចម្តេចទើបនឹងបាននិយាយចរចាបន្តិចបន្តួចផងហ្ន៎ ។

គ្រានោះឯង ព្រះភគវន្តមុនី ទ្រង់គង់ក្នុងក្រុងរាជគ្រឹះ តាមគួរដល់អធ្យាស្រ័យហើយ ទ្រង់ស្តេចទៅកាន់ចារិកឰដ៏ក្រុងសាវត្ថីលុះស្តេចទៅកាន់ចារិកតាមហូរហែ ក៏បានទៅដល់ក្រុងសាវត្ថីនោះ ។ ព្រះមានព្រះភាគគង់ក្នុងវត្តជេតពន ជារបស់អនាថ-បិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថីនោះ ។ ព្រះបុណ្ណមន្តាណីបុត្ត មានអាយុ បានឮដំណឹងដូច្នេះថា ព្រះមានព្រះភាគ យាងមកដល់ក្រុងសាវត្ថីហើយ ទ្រង់គង់ក្នុងវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋីជិតក្រុងសាវត្ថី ។ លំដាប់នោះឯង ព្រះបុណ្ណមន្តាណីបុត្តមានអាយុរៀបចំសេនាសនៈហើយប្រដាប់បាត្រចីវរ ទៅកាន់ចារិកក្នុងក្រុងសាវត្ថីនោះដែរ លុះត្រាច់ទៅកាន់ចារិកតាមហូរហែ ក៏បានចូលទៅគាល់ព្រះមានព្រះភាគ ដែលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋីជិតក្រុងសាវត្ថីនោះ លុះចូលទៅដល់ហើយទើបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះបុណ្ណមន្តាណីបុត្តមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមាន



ព្រះភាគទ្រង់ពន្យល់ណែនាំ ឱ្យក្លាហាន ឱ្យរីករាយ ដោយធម្មីកថា។ គ្រានោះ បុណ្ណមន្តាណីបុត្តមានអាយុ កាលបើព្រះមានព្រះភាគទ្រង់ពន្យល់ ណែនាំ ឱ្យក្លាហាន ឱ្យរីករាយ ដោយធម្មីកថាហើយ ក៏ត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកអំពីអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគធ្វើប្រទក្សិណហើយចូលទៅឯអន្ធវ័ន ដើម្បីនៅសម្រាកក្នុងវេលាថ្ងៃ ។

គ្រានោះឯង មានភិក្ខុ ១ រូប ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ បានពោលពាក្យដូច្នេះនឹងព្រះសារីបុត្តមានអាយុថា អាវុសោសារីបុត្ត អ្នកសំដែងសេចក្តីសរសើររឿយៗ នូវភិក្ខុបុណ្ណមន្តាណីបុត្ត ឯភិក្ខុបុណ្ណមន្តាណីបុត្តនោះដែលព្រះមានព្រះភាគ ទ្រង់ពន្យល់ណែនាំឱ្យក្លាហាន ឱ្យរីករាយដោយធម្មីកថា ហើយក៏ត្រេកអររីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកអំពីអាសនៈថ្វាយបង្គំលាព្រះមានព្រះភាគធ្វើប្រទក្សិណរួចហើយចេញទៅកាន់អន្ធវ័ននោះដើម្បីសម្រាកក្នុងវេលាថ្ងៃ ។ លំដាប់នោះឯង ព្រះសារីបុត្តមានអាយុ មានសភាពរួសរាន់កាន់និសីទនៈ ដើរតាមក្រោយៗ នៃភិក្ខុបុណ្ណមន្តាណីបុត្តមានអាយុ រមិលមើលនូវសីសៈនៃបុណ្ណមន្តាណីបុត្ត ។ គ្រានោះ

ឯង បុណ្ណមន្តាណីបុត្តមានអាយុ ដើរចូលទៅកាន់អន្ធវ័នហើយ អង្គុយសម្រាកក្នុងវេលាថ្ងៃ ទៀបម្លប់ឈើមួយ ចំណែកខាងព្រះសារីបុត្តមានអាយុ ក៏ចូលទៅកាន់អន្ធវ័នហើយអង្គុយសម្រាកក្នុងវេលាថ្ងៃ ទៀបម្លប់ឈើមួយដែរ ។

គ្រានោះឯង ព្រះសារីបុត្តមានអាយុ ចេញអំពីពួនក្នុងសាយណ្ហសម័យ ហើយចូលទៅរកបុណ្ណមន្តាណីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាលមួយអន្លើដោយបុណ្ណមន្តាណីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ។ លុះព្រះសារីបុត្តមានអាយុអង្គុយក្នុងទីសមគួរហើយ បានពោលពាក្យដូច្នេះនឹងបុណ្ណមន្តាណីបុត្តមានអាយុថា ម្នាលអាវុសោ លោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគរបស់យើងដែរឬ ។ បុណ្ណមន្តាណីបុត្តមានអាយុតបថា ម្នាលអាវុសោ យ៉ាងហ្នឹងហើយ ។ ម្នាលអាវុសោ លោកមានអាយុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគដើម្បីបរិសុទ្ធិនៃសីលឬ ។ ម្នាលអាវុសោ ការប្រព្រឹត្តនេះ មិនមែនត្រឹមប៉ុណ្ណោះទេ ។ ម្នាលអាវុសោ ចុះលោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃចិត្តឬ ។ ម្នាល





អាវុសោ មិនមែនត្រឹមតែប៉ុណ្ណោះទេ ។ ម្នាលអាវុសោ ចុះលោកមានអាយុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះមានព្រះភាគដើម្បីបរិសុទ្ធិនៃទិដ្ឋិឬ ។ ម្នាលអាវុសោ មិនមែនត្រឹមតែប៉ុណ្ណោះទេ ។ ម្នាលអាវុសោ ចុះលោកមានអាយុប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃកង្ខាវិតរណៈឬ ។ ម្នាលអាវុសោ មិនមែនត្រឹមតែប៉ុណ្ណោះទេ ។ ម្នាលអាវុសោ ចុះលោកមានអាយុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃមគ្គាមគ្គញ្ញាណទស្សនៈឬ ។ ម្នាលអាវុសោ មិនមែនត្រឹមតែប៉ុណ្ណោះទេ ។ ម្នាលអាវុសោ ចុះលោកមានអាយុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគដើម្បីបរិសុទ្ធិនៃបដិបទាញាណទស្សនៈឬ ។ ម្នាលអាវុសោ មិនមែនត្រឹមតែប៉ុណ្ណោះទេ ។ ម្នាលអាវុសោ លោកមានអាយុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃញាណទស្សនៈឬ ។ ម្នាលអាវុសោ មិនមែនត្រឹមតែប៉ុណ្ណោះទេ ។ ព្រះសារីបុត្តមានអាយុ មានថេរវាចាថា កាលបើខ្ញុំសួរថាម្នាលអាវុសោ លោកមានអាយុប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃសីលឬ លោកនិយាយថា ម្នាលអាវុសោ មិនមែនត្រឹមតែប៉ុណ្ណោះទេ កាលបើខ្ញុំសួរថា ម្នាល

អាវុសោ លោកមានអាយុប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃចិត្តឬ លោកនិយាយថា ម្នាលអាវុសោ មិនមែនត្រឹមតែប៉ុណ្ណោះទេ កាលបើខ្ញុំសួរថា ម្នាលអាវុសោ លោកមានអាយុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃទិដ្ឋិឬ លោកនិយាយថា ម្នាលអាវុសោ មិនមែនត្រឹមតែប៉ុណ្ណោះទេ ម្នាលអាវុសោ ដើម្បីបរិសុទ្ធិនៃកង្ខាវិតរណៈឬ ... ម្នាលអាវុសោដើម្បីបរិសុទ្ធិនៃមគ្គាមគ្គញ្ញាណទស្សនៈឬ ... ម្នាលអាវុសោដើម្បីបរិសុទ្ធិនៃបដិបទាញាណទស្សនៈឬ ... កាលបើខ្ញុំសួរថា លោកមានអាយុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធនៃញាណទស្សនៈឬ លោកនិយាយថា ម្នាលអាវុសោ មិនមែនត្រឹមតែប៉ុណ្ណោះទេ ម្នាលអាវុសោ (បើយ៉ាងនេះ ) ចុះលោកមានអាយុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះមានព្រះភាគ ដើម្បីអ្វី ។ បុណ្ណមន្តាណីបុត្តតបថា ម្នាលអាវុសោ ព្រហ្មចរិយធម៌ដែលខ្ញុំប្រព្រឹត្តក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីអនុបាទាបរិនិព្វានទេតើ ។ ម្នាលអាវុសោ សីលវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ ចុះចិត្តវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។



ម្នាលអាវុសោ ទិដ្ឋិវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ ចុះកង្ខាវិតរណវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ ចុះបដិបទាញាណទស្សនវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ ញាណទស្សនវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ ចុះអនុបាទាបរិនិព្វានក្រៅអំពីធម៌ទាំងនេះឬ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ព្រះសារីបុត្តសួរថា កាលខ្ញុំសួរថា ម្នាលអាវុសោ សីលវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ លោកឆ្លើយថា អាវុសោ នេះមិនមែនទេ កាលខ្ញុំសួរថា ម្នាលអាវុសោ ចុះចិត្តវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ លោកឆ្លើយថា ម្នាលអាវុសោ នេះមិនមែនទេ ម្នាលអាវុសោ ទិដ្ឋិវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។បេ។ ម្នាលអាវុសោ ចុះកង្ខាវិតរណវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ... ម្នាលអាវុសោ ចុះមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិឬ ... ម្នាលអាវុសោ ចុះបដិបទាញាណទស្សនវិសុទ្ធិឬ ... កាលបើខ្ញុំសួរថា ម្នាលអាវុសោ ញាណទស្សនវិសុទ្ធិឬ លោកឆ្លើយថា ម្នាលអាវុសោ

នេះមិនមែនទេ កាលខ្ញុំសួរថា ម្នាលអាវុសោ ចុះអនុបាទាបរិនិព្វាន ក្រៅអំពីធម៌ទាំងនេះឬ លោកឆ្លើយថា ម្នាលអាវុសោ នេះមិនមែនទេ ម្នាលអាវុសោ (កាលបើយ៉ាងនេះ )ចុះសេចក្តីនៃភាសិតនេះ គប្បីយល់យ៉ាងណា ។

បុណ្ណមន្តាណីបុត្តតបថា ម្នាលអាវុសោ បើព្រះមានព្រះភាគ បញ្ញត្តនូវសីលវិសុទ្ធិ ថាជាអនុបាទាបរិនិព្វានហើយ ឈ្មោះថា បញ្ញត្តនូវសឧបាទាន ថាជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើព្រះមានព្រះភាគបញ្ញត្តនូវចិត្តវិសុទ្ធិ ថាជាអនុបាទា-បរិនិព្វានហើយ ឈ្មោះថាបញ្ញត្តនូវសឧបាទាន ថាជាអនុបាទា-បរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើព្រះមានព្រះភាគ បញ្ញត្តនូវទិដ្ឋិវិសុទ្ធិ ថាជាអនុបាទាបរិនិព្វានហើយ ឈ្មោះថាបញ្ញត្តនូវសឧបាទាន ថាជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើព្រះមានព្រះភាគបញ្ញត្តនូវកង្ខាវិតរណវិសុទ្ធិ ថាជាអនុបាទា-បរិនិព្វានហើយ ឈ្មោះថាបញ្ញត្តនូវសឧបាទាន ថាជាអនុបាទា-បរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើព្រះមានព្រះភាគបញ្ញត្តនូវមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ថាជាអនុបាទាបរិនិព្វានហើយ ឈ្មោះថា បញ្ញត្តនូវសឧបាទាន ថាជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើព្រះមានព្រះភាគបញ្ញត្តនូវបដិបទាញាណទស្សនវិសុទ្ធិ





ថាជាអនុបាទាបរិនិព្វានហើយ ឈ្មោះថាបញ្ញត្តនូវសឧបាទាន ថាជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើព្រះមានព្រះភាគបញ្ញត្តនូវញាណទស្សនវិសុទ្ធិ ថាជាអនុបាទាបរិនិព្វានហើយ ឈ្មោះថា បញ្ញត្តនូវសឧបាទាន ថាជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើអនុបាទាបរិនិព្វាន ក្រៅអំពីធម៌ទាំងនេះហើយ បុថុជ្ជនក៏គង់បរិនិព្វានបាន ម្នាលអាវុសោ ព្រោះបុថុជ្ជន ក្រៅអំពីធម៌ទាំងនេះឯង ។ ម្នាលអាវុសោ បើដូច្នេះ ខ្ញុំនឹងធ្វើសេចក្តីឧបមាដល់លោក បុរសជាអ្នកប្រាជ្ញពួកខ្លះ ក្នុងលោកនេះ គង់ដឹងច្បាស់នូវសេចក្តីនៃភាសិត ដោយសេចក្តីឧបមាបាន ។

ម្នាលអាវុសោ ដូចជាព្រះបាទបសេនទិកោសល ទ្រង់នៅគ្រប់គ្រងក្រុងសាវត្ថី មានកិច្ចនីមួយដែលត្រូវធ្វើជាប្រញាប់ប្រ-ញាល់កើតឡើងក្នុងក្រុងសាកេត ជនទាំងឡាយដែលនៅចន្លោះក្រុងសាវត្ថី នឹងក្រុងសាកេត គប្បីរៀបចំនូវរថព្រះទីនាំងទាំង ៧ ថ្វាយព្រះបាទបសេនទិកោសលនោះរួចហើយ ម្នាលអាវុសោទើបព្រះបាទបសេនទិកោសល ទ្រង់ស្តេចចេញអំពីក្រុងសាវត្ថី ឡើងព្រះទីនាំងទី ១ ទៀបទ្វារព្រះរាជវាំងខាងក្នុង ទ្រង់ស្តេចដោយរថព្រះទីនាំងទី ១ ក៏បានដល់ទៅរថព្រះទីនាំងទី ២ ហើយលះបង់រថព្រះទីនាំងទី ១ ឡើងគង់រថព្រះទីនាំងទី ២ ទ្រង់ស្តេច

ដោយរថព្រះទីនាំងទី ២ ក៏បានដល់រថព្រះទីនាំងទី ៣ ទ្រង់លះបង់រថព្រះទីនាំងទី ២ រួចឡើងគង់រថព្រះទីនាំងទី ៣ ទ្រង់ស្តេចដោយរថព្រះទីនាំងទី ៣ ក៏បានដល់រថព្រះទីនាំងទី ៤ ទ្រង់លះ-បង់រថព្រះទីនាំងទី ៣ ក៏ឡើងគង់រថព្រះទីនាំងទី ៤ ទ្រង់ស្តេចដោយរថព្រះទីនាំងទី ៤ ក៏ឡើងដល់រថព្រះទីនាំងទី ៥ ទ្រង់លះ-បង់រថព្រះទីនាំងទី ៤ រួចឡើងគង់រថព្រះទីនាំងទី ៥ ទ្រង់ស្តេចដោយរថព្រះទីនាំងទី ៥ ក៏បានដល់រថព្រះទីនាំងទី ៦ ទ្រង់លះបង់រថព្រះទីនាំងទី ៥ រួចឡើងគង់រថព្រះទីនាំងទី ៦ ទ្រង់ស្តេចដោយរថព្រះទីនាំងទី ៦ ក៏បានដល់រថព្រះទីនាំងទី ៧ ទ្រង់លះ-បង់រថព្រះទីនាំងទី ៦ រួចឡើងគង់រថព្រះទីនាំងទី ៧ ទ្រង់ស្តេចដោយរថព្រះទីនាំងទី ៧ ក៏បានដល់ទៅក្រុងសាកេត ទ្រង់ប្រថាប់នៅត្រង់ទ្វារខាងក្នុងព្រះរាជវាំង ពួកមិត្រអាមាត្យជាញាតិសា-លោហិត នាំគ្នាក្រាបបង្គំទូលសួរព្រះអង្គ ក្នុងកាលដែលស្តេចដល់ទ្វារខាងក្នុងព្រះរាជវាំងនោះ យ៉ាងនេះថា បពិត្រមហារាជ ព្រះអង្គស្តេចចេញពីក្រុងសាវត្ថី ដោយរថព្រះទីនាំងតែមួយនេះ ដល់មកទ្វារខាងក្នុងព្រះរាជវាំងនៃក្រុងសាកេតតែម្តងឬ ម្នាលអាវុសោ (បើគេសួរយ៉ាងនេះ )ព្រះបាទបសេនទិកោសលទ្រង់ដោះស្រាយដូចម្តេច ទើបឈ្មោះថាដោះស្រាយដោយប្រពៃ ។ ម្នាលអាវុសោ



ព្រះបាទបសេនទិកោសល កាលដោះស្រាយយ៉ាងនេះ ឈ្មោះថាដោះស្រាយដោយប្រពៃថា យើងនៅអាស្រ័យឯក្រុងសាវត្ថី (ឯណោះទេ ) តែមានកិច្ចនីមួយយ៉ាងរួសរាន់កើតឡើងក្នុងក្រុងសាកេតនេះ ក៏បណ្តាជនក្នុងចន្លោះក្រុងសាវត្ថីនឹងក្រុងសាកេតបានរៀបចំរថ ៧ ឱ្យយើង ទើបយើងចេញមកពីក្រុងសាវត្ថីបានឡើងជិះរថទី ១ ត្រង់ទ្វារខាងក្នុងព្រះរាជវាំង មកដោយរថទី ១ ក៏បានដល់រថទី ២ ក៏លះបង់រថទី ១ ហើយឡើងជិះរថទី ២ មកដោយរថទី ២ ក៏បានដល់រថទី ៣ លះបង់រថទី ២ ហើយឡើងជិះរថទី ៣ មកដោយរថទី ៣ ក៏បានដល់រថទី ៤ លះបង់រថទី ៣ ហើយឡើងជិះរថទី ៤ មកដោយរថទី ៤ ក៏បានដល់រថទី ៥ លះបង់រថទី ៤ ហើយឡើងជិះរថទី ៥ មកដោយរថទី ៥ ក៏បានដល់រថទី ៦ លះបង់រថទី ៥ ឡើងជិះរថទី ៦ មកដោយរថទី ៦ ក៏បានដល់រថទី ៧ លះបង់រថទី ៦ ឡើងជិះរថទី ៧ មកដោយរថទី ៧ ទើបបានដល់មកក្រុងសាកេតត្រង់ទ្វារខាងក្នុងព្រះរាជវាំងនេះ ម្នាលអាវុសោ ព្រះបាទបសេន-ទិកោសល កាលបើដោះស្រាយយ៉ាងនេះ ទើបឈ្មោះថាដោះស្រាយដោយប្រពៃ មានឧបមាដូចម្តេចមិញ ម្នាលអាវុសោ ឯសីលវិសុទ្ធិ មានប្រយោជន៍ត្រឹមតែចិត្តវិសុទ្ធិ ចិត្តវិសុទ្ធិមាន

ប្រយោជន៍ត្រឹមតែទិដ្ឋិវិសុទ្ធិ ទិដ្ឋិវិសុទ្ធិមានប្រយោជន៍ត្រឹមតែកង្ខាវិតរណវិសុទ្ធិ កង្ខាវិតរណវិសុទ្ធិមានប្រយោជន៍ត្រឹមតែមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិមានប្រយោជន៍ត្រឹមតែបដិបទាញាណទស្សនវិសុទ្ធិ បដិបទាញាណ-ទស្សនវិសុទ្ធិមានប្រយោជន៍ត្រឹមតែញាណទស្សនវិសុទ្ធិ ញាណ-ទស្សនវិសុទ្ធិមានប្រយោជន៍ត្រឹមតែអនុបាទាបរិនិព្វាន ម្នាលអាវុ-សោ ព្រហ្មចរិយធម៌ដែលខ្ញុំប្រព្រឹត្ត ក្នុងសំណាក់ព្រះមានព្រះភាគ (នេះ) ដើម្បីអនុបាទាបរិនិព្វានតែម្យ៉ាងប៉ុណ្ណោះ សេចក្តីនេះ ក៏មានឧបមេយ្យដូច្នោះឯង ។

កាលបើបុណ្ណមន្តាណីបុត្តមានអាយុ ពោលយ៉ាងនេះហើយ ព្រះសារីបុត្តមានអាយុ បានសួរបុណ្ណមន្តាណីបុត្តមានអាយុយ៉ាងនេះថា លោកមានអាយុឈ្មោះអ្វី ពួកសព្រហ្មចារីស្គាល់ឈ្មោះលោកមានអាយុថាដូចម្តេច ។ ព្រះបុណ្ណមន្តាណីបុត្តតបថា ម្នាលអាវុសោ ខ្ញុំឈ្មោះបុណ្ណៈ តែពួកសព្រហ្មចារីស្គាល់ឈ្មោះខ្ញុំថាមន្តាណីបុត្ត ។ ព្រះសារីបុត្ត មានថេរវាចាតបវិញថា ម្នាលអាវុសោ អស្ចារ្យណាស់ ម្នាលអាវុសោ ចម្លែកណាស់ ត្រង់ការណ៍ដែលសាវ័ក ជាអ្នកចេះដឹង យល់នូវពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាដោយប្រពៃ ដូចជាព្រះបុណ្ណមន្តាណីបុត្ត មានអាយុ



ពិចារណារឿយៗ (នូវកថាវត្ថុទាំង ១០) ហើយដោះស្រាយប្រស្នាដ៏ជ្រៅៗ យ៉ាងនោះ ឈ្មោះថាជាលាភ របស់ពួកសព្រហ្មចារីទាំងជាតិមនុស្សក៏ឈ្មោះថា ពួកសព្រហ្មចារីបានល្អហើយ ត្រង់ដែលពួកសព្រហ្មចារីបុគ្គល បានឃើញបានចូលទៅអង្គុយជិតនូវព្រះបុណ្ណមន្តាណីបុត្តមានអាយុ ទោះបីពួកសព្រហ្មចារី ថែរក្សាដោយធ្វើរង្វេលសំពត់លើក្បាល ហើយឱ្យព្រះបុណ្ណមន្តាណីបុត្តមានអាយុ អង្គុយលើនោះ គប្បីបានឃើញ បានចូលទៅអង្គុយជិតនូវព្រះបុណ្ណមន្តាណីបុត្តមានអាយុ ឈ្មោះថាជាលាភរបស់ពួកសព្រហ្មចារីទាំងនោះផង ជាតិជាមនុស្សក៏ឈ្មោះថាពួកសព្រហ្ម-ចារីទាំងនោះ បានល្អហើយផង ឈ្មោះថាជាលាភរបស់យើងផង ជាតិជាមនុស្ស ក៏ឈ្មោះថាយើងបានដោយល្អផង ត្រង់ដែលពួកយើងបានឃើញ បានចូលមកអង្គុយជិត នូវព្រះបុណ្ណមន្តាណីបុត្តមានអាយុ ។

កាលបើព្រះសារីបុត្តពោលយ៉ាងនេះហើយ ព្រះបុណ្ណ-មន្តាណីបុត្តមានអាយុ បានសួរព្រះសារីបុត្តមានអាយុយ៉ាងនេះថា ចុះលោកមានអាយុ ឈ្មោះអ្វី ពួកសព្រហ្មចារី ស្គាល់ឈ្មោះលោកមានអាយុថាដូចម្តេច ។ ព្រះសារីបុត្តឆ្លើយថា ម្នាលអាវុសោ ខ្ញុំឈ្មោះឧបតិស្សៈ តែពួកសព្រហ្មចារី ស្គាល់ឈ្មោះខ្ញុំថា សារីបុត្ត ។

ព្រះបុណ្ណមន្តាណីបុត្ត មានថេរវាចាថា ឱពុទ្ធោអើយ ! យើងបានប្រឹក្សាជាមួយនឹងសាវ័ក ដែលទុកស្មើនឹងព្រះសាស្តាផងតើ តែឥតដឹងថាលោកមានអាយុ ឈ្មោះសារីបុត្តសោះ ប្រសិនបើយើងដឹងថា លោកមានអាយុឈ្មោះសារីបុត្តពិតហើយ ពាក្យឆ្លើយឆ្លងមានប្រមាណប៉ុណ្ណេះ ប្រហែលជាយើងឆ្លើយមិនច្បាស់លាស់ទេ ម្នាលអាវុសោ អស្ចារ្យណាស់ ម្នាលអាវុសោ ចម្លែកណាស់ ត្រង់ការណ៍ដែលសាវ័កជាអ្នកចេះដឹង យល់នូវពាក្យប្រៀនប្រដៅរបស់ ព្រះសាស្តាដោយប្រពៃ ដូចជាព្រះសារីបុត្តមានអាយុ បានពិចារណារឿយៗ ហើយសាកសួរប្រស្នា ដ៏ជ្រៅៗ យ៉ាងនោះឈ្មោះថាជាលាភរបស់ពួកសព្រហ្មចារី ជាតិជាមនុស្សក៏ឈ្មោះថាពួកសព្រហ្មចារីបានល្អហើយ ត្រង់ដែលពួកសព្រហ្មចារីបានឃើញបានចូលទៅអង្គុយជិត នូវព្រះសារីបុត្តមានអាយុ ទោះបីពួកសព្រហ្មចារី ថែរក្សាដោយធ្វើរង្វេលសំពត់លើក្បាល ហើយឱ្យព្រះសារីបុត្តមានអាយុ អង្គុយលើនោះ គប្បីបានឃើញ បានចូលទៅអង្គុយជិតនូវព្រះសារីបុត្តមានអាយុ ឈ្មោះថាជាលាភរបស់ពួកសព្រហ្មចារីទាំងនោះផង ជាតិជាមនុស្សក៏ឈ្មោះថា ពួកសព្រហ្មចារីទាំងនោះបានល្អហើយផង ឈ្មោះថា ជាលាភរបស់



យើងផង ជាតិជាមនុស្ស ក៏ឈ្មោះថា យើងបានល្អហើយផង ត្រង់ដែលយើងបានឃើញ បានចូលមកអង្គុយជិតនូវព្រះសារីបុត្តមានអាយុ ។ ព្រះមហានាគទាំងពីរអង្គនោះ បានអនុមោទនាត្រេកអរនឹងភាសិតនៃគ្នានឹងគ្នា ដូចបានរៀបរាប់មកនេះឯង ។

« បិដកលេខ ៥១ ទំព័រ២២៨ »

ម្នាលភិក្ខុទាំងឡាយ វិរាគៈមានវិមុត្តិញ្ញាណទស្សនៈជាអត្ថ មានវិមុត្តិញ្ញាណទស្សនៈជាអានិសង្ស និព្វិទាមានវិរាគៈជាអត្ថ មានវិរាគៈជាអានិសង្ស យថាភូតញ្ញាណទស្សនៈមាននិព្វិទាជា អត្ថ មាននិព្វិទាជាអានិសង្ស សមាធិមានយថាភូតញ្ញាណទស្សនៈជាអត្ថ មានយថាភូតញ្ញាណទស្សនៈជាអានិសង្ស សុខមានសមាធិជាអត្ថ មានសមាធិជាអានិសង្ស បស្សទ្ធិមានសុខជាអត្ថ មានសុខជាអានិសង្ស បីតិមានបស្សទ្ធិជាអត្ថ មានបស្សទ្ធិជាអានិសង្ស បាមុជ្ជៈមានបីតិជាអត្ថ មានបីតិជាអានិសង្ស អវិប្បដិសារៈមានបាមុជ្ជៈជាអត្ថ មានបាមុជ្ជៈជាអានិសង្ស សីលទាំងឡាយជាកុសល មានអវិប្បដិសារៈជាអត្ថ មានអវិប្បដិសារៈជាអានិសង្ស ដោយប្រការដូច្នេះឯង ។

ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ តែងញ៉ាំងធម៌ទាំងឡាយ ឱ្យប្រព្រឹត្តទៅ ធម៌ទាំងឡាយតែងញ៉ាំងធម៌ទាំងឡាយ ឱ្យបរិបូណ៌ ដើម្បីចេញអំពីទីមិនមែនជាត្រើយ ទៅកាន់ត្រើយគឺព្រះនិព្វាន ដោយប្រការដូច្នេះ ។

« បិដកលេខ ៣៦ ទំព័រ ១២៦ »

ម្នាលអាវុសោសារីបុត្ត អ្វីហ្ន៎ដែលបុគ្គលធ្វើបានដោយកម្រ ក្នុងធម្មវិន័យនេះ ? ម្នាលអាវុសោ បព្វជ្ជាដែលបុគ្គលធ្វើបានដោយកម្រក្នុងធម្មវិន័យនេះ ។

ចុះអ្វីដែលភិក្ខុធ្វើបានដោយកម្រ ? ម្នាលអាវុសោ សេចក្តីត្រេកអរ (មិនអផ្សុកក្នុងបព្វជ្ជានេះឯង ) ដែលបព្វជិតធ្វើបានដោយកម្រ ។

ចុះអ្វីដែលបព្វជិតមានសេចក្តីត្រេកអរហើយធ្វើបានដោយកម្រ ? ម្នាលអាវុសោ ធម្មានុធម្មប្បដិបត្តិដែលបព្វជិតមានសេចក្តីត្រេកអរហើយ ធ្វើបានដោយកម្រ ។

តើភិក្ខុដែលមាននូវធម្មានុធម្មប្បដិបត្តិហើយ យូរប៉ុន្មានទៅទើបសម្រេចជាព្រះអរហន្តបាន ? ម្នាលអាវុសោ មិនជាយូរប៉ុន្មានឡើយ ។





« បិដកលេខ ៥៨ ទំព័រ ២១ »

**(អារាមទូសកជាតក )**

**ន វេ អនត្ថកុសលេន អត្ថចរិយា សុខាវហា**
**ហាបេតិ អត្ថំ ទុម្មេធោ កបិ អារាមិកោ យថាតិ ។**

(បណ្ឌិតបុរសពោធិសត្វ ពោលថា ) ការប្រព្រឹត្តនូវអត្ថគឺប្រយោជន៍ នៃបុគ្គលដែលមិនឈ្លាសក្នុងអត្ថ រមែងមិននាំមកនូវសេចក្តីសុខឡើយ បុគ្គលឥតប្រាជ្ញា (ល្ងង់ខ្លៅ ) តែងញ៉ាំងអត្ថ គឺប្រយោជន៍ឱ្យសាបសូន្យ ដូចជាស្វារក្សាសួន (បានធ្វើប្រយោជន៍ឱ្យវិនាស ) ដូច្នោះឯង ។

ស្វារក្សាសួនក្នុងកាលនោះ គឺគេដកកូនដំណាំយកមកមើលឫសសិន បើឃើញឫសវែង ទើបគេស្រោចទឹកច្រើន បើឃើញឫសខ្លី គេស្រោចទឹកតិច ។

ការបដិបត្តិធម៌ បើមិនកំណត់នូវប្រយោជន៍ជាទិសដៅទេនោះ គឺមិនមែនជាធម្មានុធម្មប្បដិបត្តិឡើយ ហើយវាអាចជ្រោមជ្រែងអកុសលធម៌ផ្សេងៗទៀតផង ។ បើបដិបត្តិសីលខ្វះគោលដៅក៏អាចក្លាយជាសីលព្វតបរាមាស ជួយជ្រោមជ្រែងដល់អត្តកិលមថានុយោគ ។ បើបដិបត្តិសមាធិដោយមិនពិចារណាដល់អត្ថ ក៏អាចទាក់ចិត្តជាប់នឹងឥទ្ធិបាដិហារ្យជួយជ្រោមជ្រែងដល់

មិច្ឆាទិដ្ឋិផ្សេងៗ ឬអាចជាការជួយជ្រោមជ្រែងដល់តិរច្ឆានវិជ្ជាប្រភេទផ្សេងៗក៏មានដែរ ។ បើចម្រើនបញ្ញាមិនប្រព្រឹត្តទៅដើម្បីវិមុត្តិទេ ក៏ជាការឃ្លៀងឃ្លាតអំពីអរិយមគ្គដែលជាមជ្ឈិមប្បដិបទាមិនបានទៅកាន់ទិសដៅនៃព្រះពុទ្ធសាសនាឡើយ ។

តាមពិត សីលសមាធិបញ្ញា គឺគ្រាន់តែជាយាននាំទៅរកទិសដៅប៉ុណ្ណោះ ដូច្នេះទើបអ្វីៗ ក៏មិនគួរប្រកាន់ មិនគួរជាប់ជំពាក់នៅឡើយ ឯការរំលត់ឧបាទាន រំលត់ទុក្ខ ទើបជាទិសដៅ ។

ពាក្យថា **អត្ថ** ដែលជាប្រយោជន៍ ឬដែលជាទិសដៅ មានដូចដែលបានសម្ដែងហើយ ។ មានពាក្យថា **អត្ថ** ក្នុងព្រះធម៌ខ្លះសំដៅយកសេចក្ដី ឬអត្ថន័យរបស់ធម៌ ។

☆☆☆



## ៦-វិធីគិតពិចារណាតាមបែបការឃើញគុណទោស និងការរលាស់ចោល

វិធីគិតពិចារណាទី ៦ នេះ ជាការសម្លឹងពិនិត្យមើលរបស់ទាំងឡាយទៅតាមសេចក្ដីពិត ទាំងផ្នែកល្អ ទាំងផ្នែកមិនល្អ ។ ជាវិធីគិតពិចារណា ទាក់ទងនឹងការបដិបត្តិ ដើម្បីកម្ចាត់កិលេសដោះស្រាយបញ្ហា ។ មុននឹងធ្វើការដោះស្រាយនូវបញ្ហា គឺត្រូវយល់ពីបញ្ហាឱ្យច្បាស់ និងត្រូវដឹងអំពីទីដែលត្រូវទៅឱ្យប្រាកដជាមុនសិន ពោលគឺមុននឹងចាកអំពីរបស់មួយ ទៅរករបស់មួយ ត្រូវដឹងរបស់ទាំងពីរ ដែលល្មមនឹងឱ្យឃើញថា ការលះបង់ និងការទៅរកនោះ ជាការធ្វើដោយត្រឹមត្រូវ ល្អពិតប្រាកដ ។

**អស្សាទៈ** ប្រែថា ល្អ ឆ្ងាញ់ ផ្អែមត្រជាក់ អានិសង្ស គុណគុណតម្លៃបានដល់អ្វីៗដែលមានសភាពរីករាយពេញចិត្ត ។

**អាទីនវៈ** ប្រែថា ទោស ជាចំណែកមិនល្អ មិនគួរឱ្យជាប់ចិត្តបានដល់អ្វីៗដែលមិនទៀងជាទុក្ខ និងប្រែប្រួលជានិច្ច ។

**និស្សរណៈ** ប្រែថា រលាស់ចោល រលាស់ចេញ រួចផុតប្រាសចាកនូវបញ្ហា ផុតទុក្ខផុតកង្វល់ ផុតពីអស្សាទៈនិងអាទីនវៈ។

« បិដកលេខ ៤១ ទំព័រ ៣៩០ »

ម្នាលភិក្ខុទាំងឡាយ កាលមុននឹងត្រាស់ដឹង តថាគតនៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ មានសេចក្ដីត្រិះរិះដូច្នេះថា អានិសង្សដូចម្ដេច ទោសដូចម្ដេច ការរលាស់ខ្លួនចេញដូចម្ដេចក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្ដីត្រិះរិះដូច្នេះថា សភាវៈណាកើតឡើង ព្រោះអាស្រ័យសេចក្ដីសុខ សោ-មនស្សក្នុងលោក សភាវៈនោះឈ្មោះថាជាអានិសង្សក្នុងលោក សភាវៈណាមិនទៀងជាទុក្ខ មានសេចក្ដីប្រែប្រួលទៅ ជាធម្មតា សភាវៈនោះឈ្មោះថាជាទោសក្នុងលោក សភាវៈណាជាគ្រឿងបន្ទោបង់នូវឆន្ទរាគៈជាគ្រឿងលះបង់នូវឆន្ទរាគៈក្នុងលោក សភាវៈនោះឈ្មោះថា ជាការរលាស់ខ្លួនចេញ ក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ តថាគត នៅមិនទាន់ត្រាស់ដឹងតាមពិតនូវ អានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោក ថាជាការរលាស់ខ្លួនចេញផង យ៉ាងនេះ ត្រឹមណា ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនប្ដេជ្ញាថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសត្រឹមណោះ ។ ម្នាលភិក្ខុទាំងឡាយ លុះតែតថាគតបានត្រាស់ដឹងតាមពិតនូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោកថាជាការរលាស់ខ្លួនចេញផង យ៉ាងនេះ ក្នុងកាលណា ម្នាលភិក្ខុទាំងឡាយ ទើបតថាគតប្ដេជ្ញាថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ក្នុងកាលណោះ ។ ទាំងការដឹងនិងការឃើញ ក៏កើតឡើងដល់តថាគតថា ការរួចស្រឡះរបស់តថាគត មិនកម្រើកទេ ជាតិនេះជាទីបំផុត ឥឡូវនេះភពថ្មីទៀតមិនមានឡើយ ។



ម្នាលភិក្ខុទាំងឡាយ តថាគតត្រាច់ស្វែងរកអានិសង្សរបស់លោក សភាវៈណាជាអានិសង្សក្នុងលោក តថាគតក៏បានជួបប្រទះនូវសភាវៈនោះ អានិសង្សទាំងអម្បាលមាណក្នុងលោក អានិសង្សនោះ តថាគតឃើញច្បាស់ហើយដោយប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ តថាគតត្រាច់ ស្វែងរកទោសរបស់លោក សភាវៈឯណាជាទោសក្នុងលោក តថាគតក៏បានជួបប្រទះនូវសភាវៈនោះ ទោសទាំងអម្បាលមាណ ក្នុងលោក ទោសនោះ តថាគតឃើញច្បាស់ហើយដោយប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ តថាគតត្រាច់

ស្វែងរកនូវការរលាស់ខ្លួនចេញចាកលោក ធម្មជាតិណាជាការរលាស់ខ្លួនចេញក្នុងលោក តថាគតក៏បានជួបប្រទះធម្មជាតិនោះ ការរលាស់ខ្លួនចេញទាំងអម្បាលមាណ ក្នុងលោក ការរលាស់ខ្លួនចេញនោះ តថាគតក៏បានឃើញច្បាស់ហើយដោយប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ តថាគតនៅមិនទាន់ត្រាស់ដឹងតាមពិតនូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោក ថាជាការរលាស់ខ្លួនចេញផង ដរាបណា ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនប្តេជ្ញាថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ លុះតែតថាគតបានត្រាស់ដឹងតាមពិតនូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោកថាជាការរលាស់ខ្លួនចេញផង ក្នុងកាលណា ម្នាលភិក្ខុទាំងឡាយ ទើបតថាគតប្តេជ្ញាថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ក្នុងកាលនោះ ។ ទាំង



ការដឹងនិងការឃើញ ក៏កើតឡើងដល់តថាគត ការរួចស្រឡះរបស់តថាគត មិនកម្រើកទេ ជាតិនេះ ជាទីបំផុត ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ ។

ម្នាលភិក្ខុទាំងឡាយ បើអានិសង្សនុ៎ះ មិនមានក្នុងលោក ពពួកសត្វ ក៏មិនគប្បីត្រេកត្រអាលនឹងអានិសង្សនេះ ក្នុងលោកដែរ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែអានិសង្សមាននៅក្នុងលោក ពពួកសត្វទើបត្រេកត្រអាលក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បើទោសក្នុងលោកមិនមានទេ ពពួកសត្វក៏មិនគប្បី នឿយណាយនឹងទោសនេះក្នុងលោកដែរ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទោសមាននៅក្នុងលោក ទើបពពួកសត្វនឿយណាយក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បើការរលាស់ខ្លួនចេញនុ៎ះ មិនមានក្នុងលោកទេ ពពួកសត្វក៏មិនគប្បីរលាស់ខ្លួននេះចេញចាកលោកបានដែរ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែការរលាស់ខ្លួនចេញមានក្នុងលោក ទើបពពួកសត្វរលាស់ខ្លួនចេញចាកលោកបាន។ ម្នាលភិក្ខុទាំងឡាយ ពពួកសត្វមិនទាន់ដឹងច្បាស់តាមពិតនូវអានិសង្ស ថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោក ថាជាការរលាស់ខ្លួនចេញផង ដរាបណា ម្នាលភិក្ខុទាំងឡាយ សត្វមិនទាន់ប្រាសចេញ មិនទាន់គេចចេញ មិនទាន់រួចផុតស្រឡះ

ចាកលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ចាកពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស មានចិត្តមិនទាន់ប្រាសចាកព្រំដែនដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ លុះតែពួកសត្វ ដឹងតាមពិតនូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោក ថាជាការរលាស់ខ្លួនចេញផង ក្នុងកាលណា ម្នាលភិក្ខុទាំងឡាយ ពួកសត្វទើបប្រាសចេញ គេចចេញ រួចផុតស្រឡះចាកលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ចាកពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស មានចិត្តប្រាសចាកព្រំដែនក្នុងកាលនោះ ។

ម្នាលភិក្ខុទាំងឡាយ ពួកសមណៈព្រាហ្មណ៍ណាមួយ មិនដឹងច្បាស់តាមពិតនូវអានិសង្សថា ជាអានិសង្សផង នូវទោសថាជាទោសផងនូវការរលាស់ខ្លួនចេញចាកលោកថា ជាការរលាស់ខ្លួនចេញផង ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ទាំងនោះ តថាគតមិនសន្មតថាជាសមណៈ ក្នុងពួកសមណៈ មិនសន្មតថាជាព្រាហ្មណ៍ ក្នុងពួកព្រាហ្មណ៍ទេ ដ្បិតថា អ្នកដ៏មានអាយុទាំងនោះ មិនទាន់ធ្វើឱ្យជាក់ច្បាស់នូវប្រយោជន៍ ជារបស់





សមណៈផង នូវប្រយោជន៍ជារបស់ព្រាហ្មណ៍ផង ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ។ ម្នាលភិក្ខុទាំងឡាយ លុះតែពួកសមណៈ ឬ ព្រាហ្មណ៍ណាមួយដឹងច្បាស់តាមពិត នូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោកថាជាការរលាស់ខ្លួនចេញផង ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ ឬព្រាហ្មណ៍ទាំងនោះ តថាគតសន្មតថាជាសមណៈ ក្នុងពួកសមណៈ សន្មតថាជាព្រាហ្មណ៍ ក្នុងពួកព្រាហ្មណ៍ ដ្បិតថា អ្នកដ៏មានអាយុទាំងនោះ ធ្វើឱ្យជាក់ច្បាស់នូវប្រយោជន៍ជារបស់សមណៈផង នូវប្រយោជន៍ជារបស់ព្រាហ្មណ៍ផង ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ។

« បិដកលេខ ៣៣ ទំព័រ ៦២ »

ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលតថាគតនៅជាពោធិសត្វ មិនទាន់ត្រាស់ដឹង មុនអំពីសម្ពោធិញ្ញាណនៅឡើយ មានសេចក្តីត្រិះរិះដូច្នេះថា អ្វីហ្ន៎ជាអានិសង្ស អ្វីជាទោស អ្វីជាការរលាស់ចេញ នៃរូប ។ អ្វីជាអានិសង្ស អ្វីជាទោស អ្វីជាការរលាស់ចេញ នៃវេទនា ។ អ្វីជាអានិសង្ស អ្វីជាទោស អ្វីជាការរលាស់ចេញ នៃសញ្ញា ។

អ្វីជាអានិសង្ស អ្វីជាទោស អ្វីជាការរលាស់ចេញ នៃសង្ខារ ។ អ្វីជាអានិសង្ស អ្វីជាទោស អ្វីជាការរលាស់ចេញ នៃវិញ្ញាណ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីសុខ សោមនស្សណា កើតឡើងព្រោះអាស្រ័យរូប នេះជាអានិសង្សរបស់រូប រូបណាមិនទៀង ជាទុក្ខ មានកិរិយាប្រែប្រួលជាធម្មតា នេះជាទោសរបស់រូប ការបន្ទោបង់នូវឆន្ទរាគៈ ការលះបង់នូវឆន្ទរាគៈណា ក្នុងរូប នេះជាការរលាស់ចេញ នូវរូប ។ សេចក្តី សុខ សោមនស្សណា កើតឡើងព្រោះអាស្រ័យវេទនា នេះជា អានិសង្សរបស់វេទនា វេទនាណា មិនទៀង ជាទុក្ខ មានកិរិយាប្រែប្រួលជាធម្មតា នេះជាទោសរបស់វេទនា ការបន្ទោបង់នូវឆន្ទរាគៈ ការលះបង់នូវឆន្ទរាគៈណា ក្នុងវេទនា នេះជាការរលាស់ចេញ នូវវេទនា ។ សេចក្តីសុខ សោមនស្សណា កើតឡើងព្រោះអាស្រ័យសញ្ញា នេះជាអានិសង្សរបស់សញ្ញា សញ្ញាណា មិនទៀង ជាទុក្ខ មានកិរិយាប្រែប្រួលជាធម្មតា នេះជាទោសរបស់សញ្ញា ការបន្ទោបង់នូវឆន្ទរាគៈ ការលះបង់នូវឆន្ទរាគៈណា ក្នុងសញ្ញា នេះជាការរលាស់ចេញ នូវសញ្ញា ។ សេចក្តីសុខ សោមនស្សណា កើតឡើងព្រោះអាស្រ័យសង្ខារ នេះជាអានិសង្សរបស់សង្ខារ សង្ខារណាមិនទៀង ជាទុក្ខ មានកិរិយាប្រែប្រួល



ជាធម្មតា នេះជាទោសរបស់សង្ខារ ការបន្ទោបង់នូវឆន្ទរាគៈ ការលះបង់នូវឆន្ទរាគៈណា ក្នុងសង្ខារ នេះជាការរលាស់ចេញ នូវសង្ខារ ។ សេចក្តីសុខ សោមនស្សណា កើតឡើងព្រោះអាស្រ័យវិញ្ញាណ នេះជាអានិសង្សរបស់វិញ្ញាណ វិញ្ញាណណា មិនទៀង ជាទុក្ខ មានកិរិយាប្រែប្រួលជាធម្មតា នេះជាទោសរបស់វិញ្ញាណ ការបន្ទោបង់នូវឆន្ទរាគៈ ការលះបង់នូវឆន្ទរាគៈណា ក្នុងវិញ្ញាណ នេះជាការរលាស់ចេញ នូវវិញ្ញាណ ។

ម្នាលភិក្ខុទាំងឡាយ តថាគតមិនទាន់ដឹងតាមពិតនូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ចេញថាជាការរលាស់ចេញផង របស់ឧបាទានក្ខន្ធទាំង ៥ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនប្តេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ជាគុណជាតដ៏ប្រសើរ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស អស់កាលត្រឹមនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ លុះតថាគតបានដឹងច្បាស់តាមពិត នូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ចេញថាជាការរលាស់ចេញផង របស់ឧបាទានក្ខន្ធទាំង ៥ នេះ ក្នុង

កាលណា ម្នាលភិក្ខុទាំងឡាយ តថាគតទើបប្ដេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ជាគុណជាតិដ៏ប្រសើរក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ក្នុងកាលនោះឯង ។ ការដឹងច្បាស់ ឃើញច្បាស់ ក៏កើតឡើងហើយដល់តថាគតដូច្នេះថា សេចក្ដីរួចស្រឡះ (ចាកអាសវៈ) របស់តថាគតមិនកម្រើកបានឡើយ ជាតិនេះ ជាទីបំផុតត្រឹមនេះហើយ ឥឡូវនេះ ភពថ្មី គឺការត្រឡប់កើតទៅទៀត មិនមានឡើយ ។

មាននៅក្នុងបិដកលេខ ២០ មហាទុក្ខក្ខន្ធសូត្រ ព្រះអង្គទ្រង់សម្ដែងអំពីអស្សាទៈ អាទីនវៈ និងនិស្សរណៈក្នុងកាមទាំង-ឡាយ ។

មាននៅក្នុងបិដកលេខ ២៤ មាគណ្ឌិយសូត្រ ព្រះអង្គទ្រង់សម្ដែងអំពីការកើតឡើងផង សេចក្ដីវិនាសទៅវិញផង អស្សាទៈផង អាទីនវៈផង និងនិស្សរណៈផង ។

មាននៅក្នុងបិដកលេខ ៧០ បដិសម្ភិទាមគ្គ ទំព័រ ២០៨ មានសម្ដែងអំពីអស្សាទៈរបស់ឥន្ទ្រិយទាំង ៥ ដោយអាការ ២៥ យ៉ាង ។ ទំព័រ ២១១ មានសម្ដែងអំពីទោសរបស់ឥន្ទ្រិយទាំង ៥



ដោយអាការ ២៥ យ៉ាងដែរ ។ ទំព័រ ២១៣ មានសម្ដែងអំពីនិស្សរណៈ គឺការរលាស់ចេញរបស់ឥន្ទ្រិយទាំង ៥ ដោយអាការ ១៨០ ។

បិដកលេខ ៣៨ ទំព័រ ១៦៣ ព្រះអង្គសម្ដែងអំពីសមុទយ អត្ថង្គម អស្សាទៈ អាទីនវៈ និងនិស្សរណៈក្នុងឥន្ទ្រិយទាំង ៦ មានចក្ខុន្ទ្រិយជាដើម ។

បិដកលេខ ៣២ ទំព័រ ៦២ ព្រះអង្គសម្ដែងអំពី អស្សាទៈ អាទីនវៈ និងនិស្សរណៈនៃធាតុ ៤ មានបឋវីធាតុជាដើម ។

បិដកលេខ ៣៥ ទំព័រ ១៣ ព្រះអង្គសម្ដែងអំពីអស្សាទៈ អាទីនវៈ និងនិស្សរណៈនៃអាយតនៈក្នុង ៦ ក្រៅ ៦ ។

បិដកលេខ ១៩ ទំព័រ ១៨៦ និស្សារណីយធាតុ (ធាតុដែលគួររលាស់ចេញ) មាន ៥ យ៉ាង មានក្នុងសង្គីតិសូត្រ និងទសុត្តរសូត្រពួកធម៌ ៥ ។

បិដកលេខ ៤៥ ទំព័រ ២៣៣ ព្រះអង្គ សម្ដែងអំពីធាតុទាំងឡាយដែលគួររលាស់ចេញដូចក្នុងសង្គីតិសូត្រដែរ ។

បិដកលេខ ៥៣ ទំព័រ ៨២ ព្រះអង្គទ្រង់ត្រាស់សម្ដែងអំពីធាតុជាគ្រឿងរលាស់ចេញមាន ៣ គឺ នេក្ខម្មៈ រលាស់ចេញចាកកាមទាំងឡាយ ១ អរូបជ្ឈានរលាស់ចេញចាករូបធម៌ទាំងឡាយ ១

ព្រះនិព្វាន ជាគ្រឿងរលាស់ចេញនូវធម្មជាតិណាមួយដែលកើតហើយ ដែលបច្ច័យតាក់តែងហើយ ដែលកើតឡើងព្រោះអាស្រ័យហេតុ ១ ។

នេះជាតួយ៉ាង ដែលអាចបញ្ជាក់ឱ្យឃើញ ដល់ការគិតពិចារណាក្នុងបែបទី ៦ នេះ ។

វិធីគិតពិចារណាបែបនេះ អាចគិតពិចារណានៅក្នុងធម៌ជាទូទៅ សូម្បីតែក្នុងកុសលធម៌ ដូចជានៅក្នុងបដិសម្ភិទាមគ្គ ពោលដល់អស្សាទៈ និងអាទីនវៈនៃឥន្ទ្រិយ ៥ ជាដើម ។

« បិដកលេខ ៧០ ទំព័រ ២០៩ »

ការមិនប្រាកដនៃឧទ្ធច្ចៈ ១ ការមិនប្រាកដនៃសេចក្តីក្តៅក្រហាយព្រោះឧទ្ធច្ចៈ ១ សេចក្តីក្លៀវក្លានៃការប្រព្រឹត្តមិនរាយមាយ ១ ការស្ងប់រម្ងាប់និងការបាននូវវិហារធម៌ ១ សុខនិងសោមនស្សដែលកើតឡើងអាស្រ័យសមាធិន្ទ្រិយ ១ (ទាំង ៥ នេះ) ជាអស្សាទៈនៃសមាធិន្ទ្រិយ ។

ការប្រាកដនៃឧទ្ធច្ចៈ ១ ការប្រាកដនៃសេចក្តីក្តៅក្រហាយព្រោះឧទ្ធច្ចៈ ១ ដោយសេចក្តីមិនទៀងនៃសមាធិន្ទ្រិយ ១ ដោយ



សេចក្តីជាទុក្ខនៃសមាធិន្ទ្រិយ ១ ដោយសេចក្តីជាអនត្តានៃសមាធិន្ទ្រិយ ១ (ទាំង ៥ នេះ) ជាអាទីនវៈនៃសមាធិន្ទ្រិយ ។

ក្នុងការទូន្មានដោយ **អនុបុព្វីកថា** ព្រះអង្គក៏ទ្រង់ត្រាស់សម្តែងអំពីដំណើរចេញចាកទុក្ខទៅតាមលំដាប់ គឺព្រះអង្គសម្តែងអំពីការរស់នៅដោយល្អ គ្រប់គ្រងជីវិតដោយ **ទាន** ដោយ **សីល** រួចហើយព្រះអង្គសម្តែងអំពីផលនៃការគ្រប់គ្រងជីវិតប្រកបដោយធម៌ល្អ បានដល់ **សគ្គ** គឺស្ថានសួគ៌ បន្ទាប់មកទៀត ព្រះអង្គទ្រង់ត្រាស់នូវ **កាមាទីនវៈ** បញ្ជាក់ពីទោសរបស់កាម និងជាចុងក្រោយនៃអនុបុព្វីកថា ព្រះអង្គទ្រង់ត្រាស់សម្តែងអំពី **នេក្ខម្មានិសង្ស** គឺជាផ្លូវចេញពីទុក្ខពីទោសព្រមដោយផលល្អផ្សេងៗនៃដំណើរការចេញចាកពីកាមនោះឯង ។

កាលបើអ្នកស្តាប់ សម្លឹងឃើញផលល្អនៃដំណើរការចេញចាកកាមនោះហើយ ទើបព្រះអង្គទ្រង់ត្រាស់សម្តែងនូវអរិយសច្ច ៤ ជាបញ្ចប់ ។

☆ ☆ ☆

## ៧_វិធីគិតពិចារណាតាមបែបការដឹងនូវ
## របស់ពិត និងរបស់ក្លែងក្លាយ

វិធីគិតបែបទី ៧ នេះ ជាវិធីគិតពិចារណាទប់ស្កាត់នូវតណ្ហា ក្នុងការបរិភោគប្រើប្រាស់នូវបច្ច័យ ៤ និងវត្ថុ ឧបករណ៍ផ្សេងៗ ។

មនុស្សយើងបានចូលខ្លួនទៅទាក់ទងជាមួយនឹងវត្ថុផ្សេងៗ ព្រោះយើងមានសេចក្តីត្រូវការ និងមានការឃើញថា របស់នោះៗនឹងតបស្នងនូវសេចក្តីត្រូវការរបស់យើងបាន ។

របស់ដែលយើងចូលខ្លួនទៅរកយកមកប្រើប្រាស់បរិភោគមាន ២ ប្រភេទ :

**១-របស់ពិត** គឺរបស់មានតម្លៃពិតៗ ឬមានប្រយោជន៍ក្នុងការប្រើប្រាស់សម្រាប់ជីវិតដោយត្រង់ ដែលមនុស្សនាំយកមកប្រើដោះស្រាយបញ្ហារបស់ខ្លួន ដើម្បីជីវិតរស់នៅ ។

របស់ដែលមានតម្លៃសម្រាប់ជីវិត និងមាននូវប្រយោជន៍ទាំងសម្រាប់ខ្លួនឯង ទាំងសម្រាប់អ្នកដទៃនោះ គឺអាស្រ័យនៅលើបញ្ញា ដែលជាសភាវៈសម្រាប់កំណត់តម្លៃ និងអាស្រ័យបញ្ញាសម្រាប់កំណត់នូវប្រយោជន៍ពិតប្រាកដ ។





**២-របស់ក្លែងក្លាយ** គឺជារបស់ដែលតណ្ហាកំណត់តម្លៃបរិភោគ ឬប្រើប្រាស់អ្វីៗ ដើម្បីតបស្នងនូវតណ្ហា មិនមែនជាការបរិភោគប្រើប្រាស់តាមសេចក្តីត្រូវការនៃជីវិតឡើយ ។

ដែលថា **របស់ក្លែងក្លាយ** ក្នុងទីនេះ មិនមែនជារបស់ក្លែងក្លាយតាមដូចដែលមនុស្សទូទៅយល់ដឹងនោះទេ តាមអត្ថន័យ គឺបានដល់របស់ដែលមនុស្សប្រើប្រាស់ ឬបរិភោគបំពេញចំណង់តណ្ហា ដូច្នេះ របស់ទាំងអស់នោះវាក៏ក្លាយទៅជារបស់មានពិសដែលនាំមកនូវទុក្ខទោសឱ្យដល់ជីវិតទៅវិញ ។

ការគិតពិចារណាបែបនេះ ក្រៅអំពីការយល់ដឹងព្រមទាំងការបាននូវរបស់ដែលមានតម្លៃពិត សម្រាប់បរិភោគប្រើប្រាស់ហើយនោះ នៅមានការចម្រើនទៅដោយកុសលធម៌ទាំងឡាយមានសតិជាដើមទៀតផង ។

ការគិតពិចារណាក្នុងការបរិភោគប្រើប្រាស់នូវបច្ច័យ ៤ គឺជាការរៀបចំជីវិតឱ្យមានដំណើរល្អប្រពៃ គេចចេញអំពីលោភៈ សេចក្តីស្រវឹង ការច្រណែន ទិដ្ឋិ មានះ ការលើកខ្លួនប្រៀបនឹងអ្នកដទៃ ។ល។

សីលរបស់ភិក្ខុមានជាងពាក់កណ្តាលដែលប្រព្រឹត្តទៅដើម្បីបរិភោគប្រើប្រាស់នូវបច្ច័យ ៤ ឱ្យជារបស់ពិតមិនក្លែងក្លាយ ។

« បិដកលេខ ២០ ទំព័រ ៣១ »

ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយដូចម្តេចដែលបុគ្គលត្រូវលះបង់ដោយការសេព ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយហើយ អាស្រ័យសេព គឺប្រើប្រាស់នូវសំពត់ចីវរគ្រាន់តែដើម្បីការពារនូវត្រជាក់ ដើម្បីការពារនូវកម្តៅ ដើម្បីការពារនូវសម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ គ្រាន់តែដើម្បីបិទបាំងនូវអវយវៈដែលធ្វើនូវសេចក្តីខ្មាសឱ្យកម្រើក។ ពិចារណាដោយឧបាយហើយ អាស្រ័យសេព គឺបរិភោគនូវចង្ហាន់បិណ្ឌបាតដើម្បីលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីឱ្យកើតបុរិសមានះស្រវឹងដូចអ្នកប្រដាល់ក៏ទេ ដើម្បីប្រដាប់តាក់តែងរាងកាយដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីធ្វើឱ្យផូរផង់ពណ៌សម្បុរដូចអ្នករបាំក៏ទេ បរិភោគគ្រាន់តែដើម្បីឱ្យតាំងនៅនៃកាយនេះ ដើម្បីញុំាងជីវិតិន្ទ្រិយឱ្យប្រព្រឹត្តទៅ ដើម្បីបំបាត់បង់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចរិយធម៌ អាត្មាអញនឹងកំចាត់បង់នូវវេទនាចាស់ គឺសេចក្តីស្រេកឃ្លានដែលមានហើយផង នឹងញុំាងវេទនាថ្មី គឺការឆ្អែតហួសប្រមាណ មិនឱ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោស មានមិនច្រអូសកាយ មិនច្រអូសចិត្តជាដើមក្តី កិរិយានៅ





សប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អាត្មាអញ ដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ ។ ពិចារណាដោយឧបាយហើយ អាស្រ័យសេព គឺប្រើប្រាស់នូវទីសេនាសនៈ គ្រាន់តែដើម្បីការពារនូវត្រជាក់ ដើម្បីការពារនូវកម្តៅ ដើម្បីការពារនូវសម្ផស្សរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ គ្រាន់តែដើម្បីបន្ទោបង់នូវគ្រវល់គ្រវាយ ដែលកើតអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងព្រះកម្មដ្ឋាន។ ពិចារណាដោយឧបាយហើយ អាស្រ័យសេពគឺបរិភោគនូវគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ គ្រាន់តែដើម្បីការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះអាស្រ័យសេពនូវបច្ច័យណាមួយមិនដោយឧបាយ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ក្តៅក្រហាយណាគប្បីកើតឡើងបាន អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ក្តៅក្រហាយនោះ រមែងមិនមានឡើយ កាលណាបើភិក្ខុនោះអាស្រ័យសេពនូវបច្ច័យណាមួយដោយឧបាយយ៉ាងនេះវិញ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងនេះឯង ដែលតថាគតពោលថាត្រូវលះបង់ដោយការសេព ។

ត្រូវសិក្សាប្រកបផ្សំដោយព្រះធម៌ក្នុងបិដកលេខ ១៨ ទំព័រ

២៦៤ , បិដកលេខ ២២  ទំព័រ ២០៣ (ដឹងប្រមាណក្នុងភោជន ) បិដកលេខ ២៦  ទំព័រ ១៥៧  , បិដកលេខ ៣៥  ទំព័រ២៣៧ (ភិក្ខុនោះឯង  ជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ  ដឹងប្រមាណក្នុងភោជន ប្រកបនូវសេចក្តីភ្ញាក់រលឹក  នឹងបន្តនូវព្រហ្មចរិយធម៌ដ៏បរិបូណ៌ បរិសុទ្ធ  ដរាបដល់អស់ជីវិត  ពាក្យដូច្នេះនោះ  ទើបសមហេតុ  ) បិដកលេខ  ៣៥  ទំព័រ  ៤០២  (រថសូត្រអសីវិសវគ្គ  )  បិដកលេខ ៤២  ទំព័រ  ៩៥  (ម្នាលភិក្ខុទាំងឡាយ  ភិក្ខុដែលប្រកបដោយធម៌  ៤ យ៉ាង  មិនគួរសាបសូន្យឡើយ  រមែងនៅក្នុងទីជិតនៃព្រះនិព្វាន  ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ  ជាអ្នកមានសីលបរិបូណ៌  ១  ជាអ្នកមានទ្វារគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ  ១  ជាអ្នកដឹងប្រមាណក្នុងភោជន ១  ជាអ្នកប្រកបរឿយៗនូវការភ្ញាក់រលឹក ១ ) បិដកលេខ ៤៨ ទំព័រ ៣២ ,  បិដកលេខ ៦៥  ទំព័រ ១១២ ,  បិដកលេខ ៦៦ ទំព័រ ៣១៥ , បិដកលេខ ៤៦  ទំព័រ ២១៨  ។

☆ ☆ ☆



## ៨. វិធីគិតពិចារណាតាមបែបការញ៉ាំងនូវគុណធម៌ឱ្យចម្រើន

យោនិសោមនសិការ  រមែងជាបទដ្ឋាន  គឺហេតុជិតនៃកុសលធម៌  ដូច្នេះ ក្នុងការចម្រើននូវកុសលធម៌ ឬគុណធម៌ត្រូវតែហ្វឹកហាត់នូវការគិតពិចារណា ប្រព្រឹត្តទៅក្នុងអារម្មណ៍ ក្នុងរឿងដែលបានជួបប្រសព្វ ។

បុគ្គលដែលបានជួបប្រសព្វ  ឬទទួលដឹងនូវអារម្មណ៍  នូវរឿងតែម្យ៉ាងដូចគ្នា  អាចយល់ឃើញ  និងនឹកគិតតាក់តែងទៅផ្សេងៗរៀងៗខ្លួន  វាជាឧបនិស្ស័យរបស់ចិត្ត  ដែលធ្លាប់សន្សំការនឹកគិតមកដូច្នោះៗ ។

របស់តែម្យ៉ាងជាមួយគ្នា ម្នាក់មើលឃើញហើយ គិតតាក់-តែងទៅក្នុងផ្លូវដែលល្អ  ជាប្រយោជន៍  ជាកុសល  តែម្នាក់ទៀតឃើញហើយគិតតាក់តែងទៅក្នុងផ្លូវមិនល្អ ជាទោស ជាអកុសល។ ក្នុងសេចក្តីនេះ សូម្បីតែបុគ្គលម្នាក់ឯង មើលរបស់តែម្យ៉ាង ឬជួបប្រសព្វនូវអារម្មណ៍តែមួយ  ដោយគ្រាន់តែផ្សេងខណៈគ្នា  ផ្សេងពេលគ្នាប៉ុណ្ណោះ ក៏អាចគិតឃើញនិងមានគំនិតតាក់តែងទៅផ្សេងដោយឡែកពីគ្នា ពេលមួយគិតអាក្រក់ ពេលមួយទៀតគិតល្អ ។

ការតាំងចិត្តដើម្បីនឹងគិតពិចារណា ឱ្យប្រព្រឹត្តទៅក្នុងផ្លូវដែលល្អ និងជាប្រយោជន៍ នេះគឺជាវិធីគិតពិចារណា ដើម្បីញ៉ាំងនូវគុណធម៌ឱ្យចម្រើន ។

ការគិតពិចារណា ដែលជាយោនិសោមនសិការបែបទី ៨ នេះ មានសេចក្តីសំខាន់ទាំងក្នុងផ្នែកដែលធ្វើឱ្យមានការគិត និងការធ្វើល្អ ជាប្រយោជន៍ក្នុងខណៈនោះៗផង ទាំងក្នុងផ្នែកជួយកែប្រែឧបនិស្ស័យ គឺទម្លាប់អ្វីៗ ដែលអាក្រក់ផង ព្រមជាមួយគ្នានោះផងដែរ ក៏ជាការសាងឧបនិស្ស័យដែលជាផ្នែកល្អថ្មីៗ ឱ្យដល់ចិត្តរបស់ខ្លួនតទៅ ។ ផ្ទុយមកវិញ បើប្រាសចាកឧបាយកែខៃបែបនេះ ការគិត និងការធ្វើរបស់បុគ្គលនោះៗ រមែងត្រូវអូសទាញដោយអំណាចឧបនិស្ស័យចាស់ ឱ្យប្រព្រឹត្តទៅដូចមុន ដែលជាឧបនិស្ស័យអាក្រក់ និងជួយជ្រោមជ្រែងឱ្យដល់ឧបនិស្ស័យ ឬទម្លាប់អាក្រក់នោះ ឱ្យមានកម្លាំងរឹងរឹតតែខ្លាំងឡើងទៀតផង ។

តួយ៉ាងងាយៗ ដូចជាគិតដល់សេចក្តីស្លាប់ បើគិតដោយអយោនិសោមនសិការ អកុសលធម៌ក៏កើតឡើង ភ័យខ្លាចតក់ស្លុតសោកសៅជាដើមអីចឹងទៅ ឬក៏ត្រេកអរនឹងបុគ្គលដែលខ្លួនស្អប់ត្រូវស្លាប់ទៅនោះឯង ប៉ុន្តែបើមាននូវយោនិសោមនសិការវិញ កុសលរមែងកើតឡើង មានការភ្ញាក់ខ្លួន ដាស់តឿនខ្លួនឯងមិនឱ្យ





ប្រមាទ ប្រឹងប្រែងបដិបត្តិនូវមុខនាទី ធ្វើការងារជាប្រយោជន៍ និងបដិបត្តិធម៌ រហូតដឹងនូវការពិតដែលជាគតិធម្មតារបស់សង្ខារ មានសតិ មានសម្បជញ្ញៈ និងមាននូវសង្វេគធម៌ប្រកបដោយញាណ ។

នៅក្នុងបិដកលេខ ៤៨ ទំព័រ ៣៣៩ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រារព្ធហេតុ ឬរឿងរ៉ាវក្នុងករណីតែម្យ៉ាង ប៉ុន្តែគិតទៅមួយផ្នែកធ្វើឱ្យខ្ជិល គិតទៅមួយផ្នែកផ្សេងទៀតនាំឱ្យព្យាយាម សូមសិក្សាពិចារណាដូចតទៅ :

ម្នាលភិក្ខុទាំងឡាយ កុសីតវត្ថុនេះ មាន ៨ យ៉ាង ។ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អំពើ គឺការលៃលកវាស់កាត់ចីវរជាដើម ដែលភិក្ខុក្នុងសាសនានេះ គួរធ្វើក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អំពើដែលអាត្មាអញ គួរធ្វើគង់នឹងមាន តែបើអាត្មាអញធ្វើអំពើ (នោះហើយ ) កាយក៏នឹងលំបាក បើដូច្នេះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្តងព្យាយាម ដើម្បីឱ្យដល់នូវគុណគឺឈាន វិបស្សនា មគ្គ ផលដែលខ្លួនមិនទាន់ដល់ ដើម្បីដឹងនូវគុណដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឱ្យច្បាស់លាស់ នូវគុណដែលខ្លួនមិនទាន់បានធ្វើឱ្យច្បាស់លាស់ទេ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ១ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀតអំពើដែលភិក្ខុធ្វើរួចហើយក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ បានធ្វើអំពើ (នោះ) រួចហើយ តែកាលដែលអាត្មាអញ ធ្វើអំពើនោះ រាងកាយលំបាកហើយ បើដូច្នោះអាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្គងព្យាយាម ដើម្បីឱ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ដើម្បីឱ្យដឹងនូវគុណដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឱ្យច្បាស់លាស់ នូវគុណដែលខ្លួនមិនទាន់បានធ្វើឱ្យច្បាស់លាស់ទេ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ២ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀតផ្លូវដែលភិក្ខុគួរដើរទៅក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ផ្លូវដែលអាត្មាអញគួរដើរទៅ គង់នឹងមាន តែថាកាលបើអាត្មាអញ ដើរទៅកាន់ ផ្លូវ (នោះហើយ) រាងកាយនឹងលំបាក បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្គងព្យាយាម ដើម្បីឱ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ដើម្បីឱ្យដឹងនូវគុណ ដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឱ្យច្បាស់លាស់នូវគុណ ដែលខ្លួនមិនទាន់បានធ្វើឱ្យច្បាស់-លាស់ទេ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ៣ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ផ្លូវដែលភិក្ខុដើរទៅហើយក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ បាន



ដើរទៅកាន់ផ្លូវ (នោះ) រួចហើយ តែថាកាលអាត្មាអញ ដើរទៅកាន់ផ្លូវ រាងកាយលំបាក បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្គងព្យាយាម ដើម្បីឱ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ដើម្បីឱ្យដឹងនូវគុណ ដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឱ្យច្បាស់លាស់នូវគុណ ដែលខ្លួនមិនទាន់បានធ្វើឱ្យច្បាស់លាស់ទេ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ៤ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏មិនបាននូវភោជនថោកទាប ឬ ថ្លៃថ្លា គ្រាន់តែ ១ ចម្អែតឡើយ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលអាត្មាអញត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏មិនបានភោជនថោកទាប ឬ ថ្លៃថ្លា គ្រាន់តែ ១ ចម្អែតសោះ អាត្មាអញនោះមានរាងកាយលំបាកហើយ មិនគួរដល់សមណកម្ម បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្គងព្យាយាមឡើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ៥ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏បាននូវភោជនថោកទាប ឬ ថ្លៃថ្លា ល្មម ១ ចម្អែត ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលអាត្មាអញត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ហើយបាន

ភោជនថោកទាប ឬ ថ្លៃថ្លា ល្មម ១ ចម្អែតដែរ អាត្មាអញនោះមានរាងកាយធ្ងន់ ដូចសណ្តែករាជមាសទទឹក មិនគួរដល់សមណ-កម្ម បើដូច្នោះអាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្តងព្យាយាមឡើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ៦ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមានអាពាធតិចតួចកើតឡើង ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញមានអាពាធតិចតួចនេះកើតឡើង ហើយគួរតែដេកសិន បើដូច្នោះអាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្តងព្យាយាមឡើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ៧ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុចេញចាកជំងឺ ទើបតែស្បើយជំងឺថ្មីៗ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញចេញចាកជំងឺ ទើបតែស្បើយជំងឺថ្មីៗ អាត្មាអញនោះ មានរាងកាយថមថយកម្លាំង មិនគួរដល់សមណកម្ម បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្តងព្យាយាម ដើម្បីឱ្យដល់នូវគុណដែលខ្លួនមិនទាន់បានដល់ ដើម្បីឱ្យដឹងនូវគុណ ដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឱ្យច្បាស់លាស់នូវគុណ ដែលខ្លួនមិនទាន់បានធ្វើឱ្យច្បាស់លាស់ទេ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ៨ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងកុសីតវត្ថុ ៨ យ៉ាង ។



ម្នាលភិក្ខុទាំងឡាយ អារព្ភវត្ថុនេះ មាន ៨ យ៉ាង ។ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អំពើដែលភិក្ខុក្នុងសាសនានេះ គួរធ្វើក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អំពើដែលអាត្មាអញគួរធ្វើគង់នឹងមាន តែថា កាលអាត្មាអញធ្វើអំពើ (នោះហើយ ) មិនងាយនឹងធ្វើពុទ្ធសាសនាឱ្យតាំងនៅក្នុងចិត្តបានឡើយ បើដូច្នោះអាត្មាអញ ផ្តងព្យាយាមមុនសិន ដើម្បីឱ្យដល់នូវគុណគឺឈាន វិបស្សនាមគ្គ ផលដែលអាត្មាអញមិនទាន់បានដល់ ដើម្បីឱ្យដឹងនូវគុណ ដែលអាត្មាអញមិនទាន់បានដឹង ដើម្បីធ្វើឱ្យច្បាស់លាស់នូវគុណ ដែលអាត្មាអញមិនទាន់បានធ្វើឱ្យច្បាស់លាស់ ភិក្ខុនោះក៏ផ្តងព្យាយាម ដើម្បីឱ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ដើម្បីឱ្យដឹងនូវគុណ ដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឱ្យច្បាស់លាស់នូវគុណ ដែលខ្លួវមិនទាន់បានធ្វើឱ្យច្បាស់-លាស់ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ១ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត អំពើដែលភិក្ខុធ្វើរួចហើយក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ បានធ្វើអំពើរួចហើយ តែថា កាលអាត្មាអញ ធ្វើអំពើ (នោះ ) មិនអាចនឹងធ្វើពុទ្ធសាសនាឱ្យតាំងនៅក្នុងចិត្តបានឡើយ បើដូច្នោះអាត្មា-អញផ្តងព្យាយាម ដើម្បីឱ្យដល់នូវគុណដែលអាត្មាអញមិនទាន់

បានដល់ ដើម្បីឱ្យដឹងនូវគុណ ដែលអាត្មាអញមិនទាន់បានដឹង ដើម្បីធ្វើឱ្យច្បាស់លាស់នូវគុណ ដែលអាត្មាអញមិនទាន់បានធ្វើឱ្យច្បាស់លាស់ ភិក្ខុនោះក៏ផ្តួងព្យាយាម ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ២ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ផ្លូវដែលភិក្ខុគួរដើរទៅក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ផ្លូវដែលអាត្មាអញគួរដើរទៅគង់នឹងមាន តែថាអាត្មាអញដើរទៅកាន់ផ្លូវ (នោះ) មិនងាយនឹងធ្វើពុទ្ធសាសនាឱ្យតាំងនៅក្នុងចិត្តបានឡើយ បើដូច្នោះអាត្មាអញផ្តួងព្យាយាម ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៣ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ផ្លូវដែលភិក្ខុដើរទៅហើយក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ បានដើរទៅកាន់ផ្លូវហើយ តែថាកាលណាអាត្មាអញដើរទៅកាន់ផ្លូវ មិនអាចធ្វើពុទ្ធសាសនាឱ្យតាំងនៅក្នុងចិត្តបានឡើយ បើដូច្នោះ អាត្មាអញផ្តួងព្យាយាម ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៤ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏មិនបាននូវភោជនថោកទាប ឬ



ថ្ងៃថ្លា ល្មម ១ ចម្អែតទេ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលអាត្មាអញត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏មិនបានភោជនថោកទាប ឬ ថ្ងៃថ្លា ល្មម ១ ចម្អែតឡើយ អាត្មាអញនោះមានរាងកាយស្រាលគួរដល់សមណកម្ម បើដូច្នោះ អាត្មាអញផ្តួងព្យាយាម ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៥ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏បាននូវភោជនថោកទាប ឬ ថ្ងៃថ្លា ល្មម ១ ចម្អែត ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលអាត្មាអញត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏បានភោជនថោកទាប ឬ ថ្ងៃថ្លា ល្មម ១ ចម្អែតហើយ អាត្មាអញនោះមានរាងកាយស្រាលគួរដល់សមណកម្ម បើដូច្នោះ អាត្មាអញផ្តួងព្យាយាម ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៦ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមានអាពាធតិចតួចកើតឡើង ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញកើតអាពាធតិចតួចនេះហើយ អាពាធចម្រើនដល់អាត្មាអញ ដោយហេតុណា ហេតុនុ៎ះ ជាហេតុតែងមានជាធម្មតាទេ បើដូច្នោះ អាត្មាអញ ផ្តួងព្យាយាមឱ្យបានមុនសិន ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជា អារព្ភវត្ថុទី ៧ ។

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុចេញចាកជំងឺ ទើបតែស្បើយជំងឺថ្មីៗ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញចេញចាកជំងឺ ទើបតែស្បើយជំងឺថ្មីៗ អាពាធរបស់អាត្មាអញ វិរឡើងវិញ ដោយហេតុណា ហេតុនុ៎ះ ជាហេតុតែងមាន ជាធម្មតាទេ បើដូច្នោះ អាត្មាអញផ្គងព្យាយាមឱ្យបានមុន ដើម្បីឱ្យដល់នូវគុណ ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីឱ្យដឹងនូវគុណ ដែលអាត្មាអញមិនទាន់បានដឹង ដើម្បីធ្វើឱ្យច្បាស់លាស់នូវគុណ ដែលអាត្មាអញមិនទាន់បានធ្វើឱ្យច្បាស់លាស់សិន ភិក្ខុនោះក៏ផ្គងព្យាយាម ដើម្បីឱ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ដើម្បីឱ្យដឹងនូវគុណដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឱ្យច្បាស់លាស់នូវគុណដែលខ្លួនមិនទាន់បានធ្វើឱ្យច្បាស់លាស់ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៨ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងអារព្ភវត្ថុ ៨ យ៉ាង ។

បិដកលេខ ១៩ សង្គីតិសូត្រ និងទសុត្តរសូត្រ ធម៌ពួក ៨ ក៏មានដូចគ្នា ។

ក្នុងករណីដែលមានអកុសលវិតក្កៈកើតឡើង ព្រះអង្គទ្រង់ណែនាំឱ្យកែខៃ ឬ កម្ចាត់បង់ដូចមានក្នុងបិដកលេខ ២០ ទំព័រ ៤៤២ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖





## វិតក្កសណ្ឋានសូត្រ

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។

ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបរឿយៗ នូវអធិចិត្ត គឺសមាបត្តិ ៨ ហើយគប្បីធ្វើទុកក្នុងចិត្តនូវហេតុទាំង ៥ ប្រការសព្វៗកាល ។ ហេតុទាំង ៥ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ អាស្រ័យនូវហេតុណា ធ្វើទុកក្នុងចិត្តនូវហេតុណា អកុសលវិតក្កៈដ៏លាមកទាំងឡាយ ដែលប្រកបដោយឆន្ទៈគឺលោភៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីចេញចាកហេតុនោះ ហើយធ្វើទុកក្នុងចិត្តនូវហេតុដទៃដែលប្រកបដោយកុសលវិតក្កៈវិញ កាលបើភិក្ខុនោះចេញចាកហេតុនោះ ហើយធ្វើទុកក្នុងចិត្តនូវហេតុដទៃដែលប្រកបដោយកុសលវិតក្កៈ អកុសលវិតក្កៈដ៏លាមកទាំងឡាយណាដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ

អកុសលវិតក្កៈទាំងនោះនឹងសាបសូន្យទៅ នឹងដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាជាងឈើឬកូនសិស្សជាងឈើដែលប្រសប់ គប្បីវាយបញ្ជូន នាំចេញ ដកចេញ នូវកន្លាស់ធំ ដោយកន្លាស់តូចដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យហេតុណា ធ្វើទុកក្នុងចិត្តនូវហេតុណា អកុសលវិតក្កៈដ៏លាមកទាំងឡាយ ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីចេញចាកហេតុនោះហើយ ធ្វើទុកក្នុងចិត្តនូវហេតុដទៃដែលប្រកបដោយកុសលវិតក្កៈវិញ កាលភិក្ខុនោះចេញចាកហេតុនោះហើយ ធ្វើទុកក្នុងចិត្តនូវហេតុដទៃដែលប្រកបដោយកុសលវិតក្កៈ អកុសលវិតក្កៈដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ទោសៈខ្លះ មោហៈខ្លះ អកុសលវិតក្កៈទាំងនោះ នឹងសាបសូន្យទៅ នឹងដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅ



ក្នុងអារម្មណ៍ដូច្នោះឯង ។

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះចេញចាក ហេតុនោះ ហើយធ្វើទុកក្នុងចិត្តនូវហេតុដទៃដែលប្រកបដោយ កុសលវិតក្កៈវិញ អកុសលវិតក្កៈដ៏លាមកទាំងឡាយដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ លុះភិក្ខុនោះកំណត់នូវទោសនៃវិតក្កៈទាំងនោះថា វិតក្កៈទាំងនេះ ជាអកុសល វិតក្កៈទាំងនេះប្រកបដោយទោស វិតក្កៈទាំងនេះឱ្យផលជាទុក្ខ ។ កាលភិក្ខុនោះកំណត់នូវទោសនៃវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយណាដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះនឹងសាបសូន្យទៅ នឹងដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះចេញបានហើយ ទើបចិត្តខាងក្នុង ក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្ត្រី ឬបុរសកំលោះ ឬក្រមុំ ប្រកបដោយជាតិជាអ្នកប្រដាប់តាក់តែងកាយ គប្បីនឿយណាយធុញទ្រាន់ ខ្ពើមរអើមសាកសពពស់ សាកសពឆ្កែ សាកសពមនុស្ស ដែលជាប់នៅត្រង់ក យ៉ាងណាមិញ ម្នាលភិក្ខុ

ទាំងឡាយ កាលបើភិក្ខុនោះចេញចាកហេតុនោះ ហើយធ្វើទុកក្នុងចិត្តនូវហេតុដទៃដែលប្រកបដោយកុសលវិតក្កៈវិញ អកុសលវិតក្កៈដ៏លាមកទាំងឡាយដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីកំណត់នូវទោសនៃវិតក្កៈទាំងនោះថា វិតក្កៈទាំងនេះជាអកុសល វិតក្កៈទាំងនេះប្រកបដោយទោស វិតក្កៈទាំងនេះឱ្យផលជាទុក្ខ ។ កាលភិក្ខុនោះកំណត់នូវទោសនៃវិតក្កៈទាំងនោះ អកុសលវិតក្កៈដ៏លាមកទាំងឡាយណាដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះនឹងសាបសូន្យទៅ នឹងដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះចេញបាន ទើបចិត្តខាងក្នុងតាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។

ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះកំណត់នូវទោសនៃវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយ ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមិនគប្បីរលឹក មិនគប្បីធ្វើទុកក្នុងចិត្តចំពោះវិតក្កៈទាំងនោះឡើយ



កាលភិក្ខុនោះមិនរលឹក មិនធ្វើទុកក្នុងចិត្តចំពោះវិតក្កៈទាំងនោះទេ អកុសលវិតក្កៈដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះនឹងសាបសូន្យទៅ នឹងដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះចេញបានហើយ ទើបចិត្តខាងក្នុងតាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសដែលមានចក្ខុមិនចង់ឃើញរូបទាំងឡាយដែលមកប្រាកដដល់ចក្ខុ បុរសនោះគប្បីធ្មេចភ្នែក ឬមិនគប្បីក្រឡេកមើលដោយហេតុដទៃយ៉ាងណា ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះកំណត់នូវទោសនៃវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយដែលប្រកបដោយឆន្ទៈតែងកើតឡើង ។បេ។ ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។

ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះមិនរលឹក មិនធ្វើទុកក្នុងចិត្តចំពោះវិតក្កៈទាំងនោះទេ អកុសលវិតក្កៈដ៏លាមកទាំងឡាយដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីធ្វើទុកក្នុងចិត្តវិតក្កសង្ខារសណ្ឋាន គឺហេតុជាទីតាំងនៃ

វិតក្កៈទាំងនោះ កាលភិក្ខុនោះធ្វើទុកក្នុងចិត្តនូវវិតក្កសង្ខារ-សណ្ឋាននៃវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈដ៏លាមកទាំង-ឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះនឹងសាបសូន្យទៅ នឹងដល់នូវសេចក្តីវិនាសបាត់បង់ទៅ ព្រោះលះបង់នូវអកុសលវិតក្កៈនោះចេញបានហើយ ទើបចិត្តខាងក្នុងតាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ដូចបុរសដើរលឿន បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ហេតុអ្វីហ្ន៎ក៏អាត្មាអញដើរលឿនម្ល៉េះ បើដូច្នោះមានតែអាត្មាអញដើរទៅសន្សឹមៗ (លុះគិតដូច្នេះហើយ) បុរសនោះក៏ដើរទៅសន្សឹមៗ ។ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ហេតុអ្វីហ្ន៎ក៏អាត្មាអញដើរសន្សឹមៗម្ល៉េះ បើដូច្នោះមានតែអាត្មាអញឈរ ហើយបុរសនោះក៏ឈរ ។ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ហេតុអ្វីហ្ន៎ក៏អាត្មាអញឈរ បើដូច្នោះមានតែអាត្មាអញអង្គុយ ហើយបុរសនោះក៏អង្គុយ ។ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ហេតុអ្វីហ្ន៎ក៏អាត្មាអញអង្គុយ បើដូច្នោះមានតែអាត្មាអញដេក ហើយបុរសនោះក៏ដេក ។

ម្នាលភិក្ខុទាំងឡាយ បុរសនោះលះបង់ឥរិយាបថដ៏គ្រោត-



គ្រាតៗ យ៉ាងនេះហើយ គប្បីសម្រេចឥរិយាបថដ៏ល្អិតសុខុមវិញ សេចក្តីនេះយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះធ្វើទុកក្នុងចិត្ត នូវវិតក្កសង្ខារសណ្ឋាននៃវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយប្រកបដោយឆន្ទៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ។បេ។ ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ សេចក្តីនេះដូច្នោះឯង។

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវវិតក្កសង្ខារសណ្ឋាននៃវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយ ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ នៅតែកើតឡើងទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវសង្កត់ធ្មេញខាងលើនឹងធ្មេញខាងក្រោម យកអណ្តាតទល់ពិតាន សង្កត់សង្កិន គាប កម្តៅនូវអកុសលចិត្តដោយកុសលចិត្ត កាលភិក្ខុកំពុងសង្កត់ធ្មេញខាងលើនឹងធ្មេញខាងក្រោម យកអណ្តាតទល់ពិតាន សង្កត់សង្កិន គាប កម្តៅនូវអកុសលចិត្តដោយកុសលចិត្ត អកុសលវិតក្កៈដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះក៏សាបសូន្យទៅ ដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កៈ

ទាំងនោះបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នៅនឹងក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសដែលមានកម្លាំង ចាប់បុរសដែលមានកម្លាំងថយជាង ត្រង់ក្បាលក្តី ត្រង់កក្តី ត្រង់ខ្លួនក្តី ហើយសង្កត់សង្កិនគាបកម្តៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវវិតក្កសង្ខារសណ្ឋាននៃវិតក្កៈទាំងឡាយហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយ ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ នៅតែកើតឡើងទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវសង្កត់ធ្មេញខាងលើនឹងធ្មេញខាងក្រោម យកអណ្តាតទល់ពិតានសង្កត់សង្កិន គាប កម្តៅនូវអកុសលចិត្តដោយកុសលចិត្ត កាលភិក្ខុកំពុងសង្កត់ធ្មេញខាងលើនឹងធ្មេញខាងក្រោម យកអណ្តាតទល់ពិតាន សង្កត់ គាបកម្តៅនូវអកុសលចិត្តដោយកុសលចិត្តហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះ ក៏សាបសូន្យទៅ ដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះចេញបាន ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នៅនឹងក្នុងអារម្មណ៍ ។





ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុអាស្រ័យហេតុណា ធ្វើទុកក្នុងចិត្តនូវហេតុណាហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ រមែងកើតឡើង ភិក្ខុនោះចេញចាកហេតុនោះ ហើយធ្វើទុកក្នុងចិត្តនូវហេតុដទៃ ដែលប្រកបដោយកុសលវិញ អកុសលវិតក្កៈដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះ ក៏សាបសូន្យទៅ ដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះចេញបាន ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នៅនឹងក្នុងអារម្មណ៍ ។ កាលភិក្ខុកំណត់នូវទោសនៃវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះ ក៏សាបសូន្យទៅ ដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះចេញបាន ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នៅនឹងក្នុងអារម្មណ៍ ។ កាលភិក្ខុមិនបាននឹកនា មិនបានយកចិត្តទុកដាក់ចំពោះវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយ

ណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះ ក៏សាបសូន្យទៅ ដល់នូវសេចក្ដីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះចេញបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នៅនឹងក្នុងអារម្មណ៍ ។ កាលភិក្ខុធ្វើទុកក្នុងចិត្ត នូវវិតក្កសង្ខារសណ្ឋាននៃវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះក៏សាបសូន្យទៅ ដល់នូវសេចក្ដីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះចេញបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នៅនឹងក្នុងអារម្មណ៍ ។ (កាលភិក្ខុនោះ ) កំពុងសង្កត់ធ្មេញខាងលើនឹងធ្មេញខាងក្រោម អណ្ដាតទល់ពិតានសង្កត់ គាប កម្ដៅនូវអកុសលចិត្តដោយកុសលចិត្តហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះ ក៏សាបសូន្យទៅ ដល់នូវសេចក្ដីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់អកុសលវិតក្កៈទាំង-នោះចេញបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន





មានអារម្មណ៍តែមួយ នៅនឹងក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ តថាគតហៅថា ជាអ្នកស្ទាត់ក្នុងគន្លងនៃវិតក្កបរិយាយទាំងឡាយ ភិក្ខុនោះ (បើ ) ប្រាថ្នានូវវិតក្កៈណា នឹងត្រិះរិះនូវវិតក្កៈនោះ (បើ ) មិនប្រាថ្នានូវវិតក្កៈណា នឹងមិនត្រិះរិះនូវវិតក្កៈនោះ ហើយផ្ដាច់បង់នូវតណ្ហា លះបង់នូវសំយោជនធម៌ ធ្វើនូវព្រះ-និព្វានជាទីបំផុតនៃទុក្ខ ព្រោះបានត្រាស់ដឹងដោយចិត្តដ៏ប្រពៃ ។ លុះព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុនោះក៏មានសេចក្ដីពេញចិត្ត ត្រេកអរចំពោះភាសិតរបស់ព្រះ-មានព្រះភាគ ។

ព្រះសារីបុត្តបានណែនាំវិធីកម្ចាត់បង់នូវអាឃាត ៥ យ៉ាង ក្នុងបិដកលេខ ៤៥ ទំព័រ ១១៥ មានដូចតទៅ :

ព្រះសារីបុត្តដ៏មានអាយុ ហៅពួកភិក្ខុក្នុងទីនោះថា នែអាវុសោភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ក៏ទទួលស្ដាប់ពាក្យព្រះសារីបុត្តដ៏មានអាយុថា អាវុសោ ដូច្នេះ ។ ព្រះសារីបុត្តដ៏មានអាយុក៏មានថេរវាចាយ៉ាងនេះថា នែអាវុសោទាំងឡាយ គំនុំកើតឡើងដល់ភិក្ខុ ភិក្ខុត្រូវកម្ចាត់បង់ដោយសព្វគ្រប់ ព្រោះអាឃាតប្បដិវិន័យណា អាឃាតប្បដិវិន័យនោះមាន ៥ យ៉ាង ។ ៥ យ៉ាង តើដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ក្នុងលោកនេះ មាន

បុគ្គលខ្លះ ជាអ្នកមានការប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ មានការប្រព្រឹត្ត ដោយវាចាដ៏បរិសុទ្ធ ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលមានសភាពយ៉ាងនេះចេញ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ក្នុងលោកនេះ មានបុគ្គលខ្លះ ជាអ្នកមានការប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធ តែមានការប្រព្រឹត្ត ដោយកាយដ៏បរិសុទ្ធ ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលមានសភាពយ៉ាងនេះចេញ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ក្នុងលោកនេះ មានបុគ្គលខ្លះ មានការប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ មានការប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធ តែបានឱកាសស្ងប់នៃចិត្តផង ក្នុងកាលម្តងៗដែរ ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវកម្ចាត់បង់ គំនុំពីបុគ្គលមានសភាពយ៉ាងនេះចេញ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ក្នុងលោកនេះ មានបុគ្គលខ្លះ មានការប្រព្រឹត្តដោយកាយមិនបរិសុទ្ធ មានការប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធ ទាំងមិនបានឱកាសស្ងប់នៃចិត្តផង សេចក្តីជ្រះថ្លានៃចិត្តផង ក្នុងកាលម្តងៗទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលមានសភាពយ៉ាងនេះចេញ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ក្នុងលោកនេះ មានបុគ្គលខ្លះ មានការប្រព្រឹត្តដោយកាយដ៏បរិសុទ្ធ



មានការប្រព្រឹត្ត ដោយវាចាដ៏បរិសុទ្ធ ទាំងបានឱកាសស្ងប់នៃចិត្តផង សេចក្តីជ្រះថ្លានៃចិត្តផង ក្នុងកាលម្តងៗ ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលមានសភាពយ៉ាងនេះចេញ ១ ។ ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំងនោះ បុគ្គលណា មានការប្រព្រឹត្តដោយកាយមិនបរិសុទ្ធ តែមានការប្រព្រឹត្ត ដោយវាចាដ៏បរិសុទ្ធ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ដូចជាភិក្ខុអ្នកទ្រទ្រង់សំពត់បង្សុកូល បានឃើញផែនសំពត់នៅនាច្រកផ្លូវ ហើយជាន់នឹងជើងឆ្វេងលាត្រដាងមើលដោយជើងស្តាំ ហើយហែកសំពត់យកតែត្រង់កន្លែងដែលមានសាច់ជាប់ រួចកាន់យកដើរចៀសចេញទៅ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលណាមានការប្រព្រឹត្តដោយកាយមិនបរិសុទ្ធ តែមានការប្រព្រឹត្ត ដោយវាចាដ៏បរិសុទ្ធ ភិក្ខុមិនត្រូវធ្វើទុកក្នុងចិត្តនូវសេចក្តីប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះឡើយ ត្រូវធ្វើទុកក្នុងចិត្ត តែត្រង់សេចក្តីប្រព្រឹត្ត ដោយវាចាដ៏បរិសុទ្ធ របស់បុគ្គលនោះ ក្នុងសម័យនោះប៉ុណ្ណោះ ក៏យ៉ាងនោះដែរ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំងនោះ បុគ្គលណា មាន

ការប្រព្រឹត្តដោយវាចាមិនបរិសុទ្ធ តែមានការប្រព្រឹត្ត ដោយកាយដ៏បរិសុទ្ធ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ស្រះបោក្ខរណី ពាសពេញដោយសារាយនិងចក មានបុរសក្តៅខ្លាំងដោយកម្តៅថ្ងៃ ត្រូវកម្តៅថ្ងៃគ្របសង្កត់ នឿយហត់ អន្ទះអន្ទែង ស្រេក ដើរមកដល់ បុរសនោះ ក៏ចុះទៅរកស្រះបោក្ខរណីនោះ ហើយវែកសារាយនិងចកដោយដៃទាំងពីរ រួចក្បង់ទឹកផឹកដោយកម្បង់ដៃ ទើបដើរចេញទៅយ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលណាមានការប្រព្រឹត្តដោយវាចាមិនបរិសុទ្ធ តែមានការប្រព្រឹត្ត ដោយកាយដ៏បរិសុទ្ធ ភិក្ខុមិនត្រូវធ្វើទុកក្នុងចិត្តនូវសេចក្តីប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះឡើយ ត្រូវធ្វើទុកក្នុងចិត្តតែត្រង់សេចក្តីប្រព្រឹត្ត ដោយកាយដ៏បរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះប៉ុណ្ណោះវិញ ក៏យ៉ាងនោះដែរ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះ ដោយប្រការយ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំងនោះ បុគ្គលណា មានសេចក្តីប្រព្រឹត្តដោយកាយមិនបរិសុទ្ធ មានការប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធ តែបានឱកាសស្ងប់នៃចិត្តនិងជ្រះថ្លានៃចិត្ត ក្នុងកាលម្តងៗ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការដូច



ម្តេច ។ ម្នាលអាវុសោទាំងឡាយ ដូចទឹកដ៏តិចដក់ក្នុងដានជើងគោ មានបុរសក្តៅខ្លាំងដោយកម្តៅថ្ងៃ ត្រូវកម្តៅថ្ងៃគ្របសង្កត់ នឿយហត់ អន្ទះអន្ទែង ស្រេក ដើរមកដល់ បុរសអ្នកស្រេកទឹកនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ទឹកក្នុងដានជើងគោនេះមានតិច បើអាត្មាអញដងផឹកដោយកម្បង់ដៃ ឬដោយភាជនៈ ក៏ឈ្មោះថាអាត្មាអញធ្វើទឹកនោះឱ្យកក្រើកផង ឱ្យល្អក់ផង ទាំងធ្វើទឹកនោះឱ្យជាទឹកផឹកមិនបានផង បើដូច្នោះ មានតែអាត្មាអញច្រត់ដៃលុតជង្គង់ឱនផឹកដូចជាគោ ហើយដើរចេញទៅចុះ ដូច្នេះបុរសនោះ ក៏ច្រត់ដៃលុតជង្គង់ឱនផឹកដូចជាគោរួចចៀសចេញទៅ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលណាមានសេចក្តីប្រព្រឹត្តដោយកាយមិនបរិសុទ្ធ មានសេចក្តីប្រព្រឹត្តដោយវាចាក៏មិនបរិសុទ្ធ តែបានឱកាសស្ងប់នៃចិត្តផង សេចក្តីជ្រះថ្លានៃចិត្តផង ក្នុងកាលម្តងៗ ភិក្ខុមិនត្រូវធ្វើទុកក្នុងចិត្តនូវសេចក្តីប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះឡើយ មិនត្រូវធ្វើទុកក្នុងចិត្តនូវសេចក្តីប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះឡើយ (ព្រោះ) បុគ្គលនោះ បានឱកាសស្ងប់នៃចិត្តផង សេចក្តីជ្រះថ្លានៃចិត្តផង ក្នុងកាលម្តងៗឯណា ភិក្ខុត្រូវធ្វើទុកក្នុងចិត្តតែត្រង់ការបានឱកាសស្ងប់នៃចិត្តផង សេចក្តីជ្រះថ្លានៃចិត្ត

ផង ក្នុងកាលម្តងៗនោះ របស់បុគ្គលនោះ ក្នុងសម័យនោះ ប៉ុណ្ណោះ ក៏យ៉ាងនោះដែរ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះ ដោយប្រការយ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំងនោះ បុគ្គលណាមានសេចក្តីប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ មានសេចក្តីប្រព្រឹត្ត ដោយវាចាក៏មិនបរិសុទ្ធ ទាំងមិនបានឱកាសស្ងប់នៃចិត្តផង សេចក្តីជ្រះថ្លានៃចិត្តផង ក្នុងកាលម្តងៗទេ តើភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ដូចបុរសមានអាពាធដល់នូវសេចក្តីទុក្ខ ឈឺធ្ងន់ ដើរទៅកាន់ផ្លូវឆ្ងាយ ស្រុកបុរសនោះ ក៏នៅឆ្ងាយទៅមុខផង ស្រុកបុរសនោះ ក៏នៅឆ្ងាយទៅក្រោយផង បុរសនោះ មិនបាននូវភោជនទាំងឡាយជាទីសប្បាយ មិនបានភេសជ្ជៈទាំងឡាយជាទីសប្បាយ មិនបានអ្នកទំនុកបម្រុងដ៏សមគួរ មិនបានជនអ្នកនាំទៅរកស្រុកសោះ ស្រាប់តែមានបុរសម្នាក់ទៀត ដើរទៅកាន់ផ្លូវឆ្ងាយដែរ ក៏ឃើញបុរសនោះ គាត់ក៏តាំងទុកនូវសេចក្តីករុណាក្នុងបុរស (មានអាពាធ )នោះ តាំងទុកនូវសេចក្តីអាណិត តាំងទុកនូវសេចក្តីអនុគ្រោះ (ដោយបំណងថា ) ធ្វើដូចម្តេច ឱ្យបុរសនេះ បាននូវភោជនទាំងឡាយជាទីសប្បាយ បានភេសជ្ជៈទាំងឡាយជាទីសប្បាយ បាននូវអ្នកទំនុកបម្រុងដ៏សមគួរ បាននូវ





ជនអ្នកនាំទៅរកស្រុកផងទៅហ្ន៎ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថាបុរសនេះកុំដល់នូវសេចក្តីវិនាស ត្រង់កន្លែងនេះឡើយ មានឧបមាយ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលណាមានសេចក្តីប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ មានសេចក្តីប្រព្រឹត្ត ដោយវាចាក៏មិនបរិសុទ្ធ ទាំងមិនបានឱកាសស្ងប់នៃចិត្ត និងសេចក្តីជ្រះថ្លានៃចិត្តក្នុងកាលម្តងៗទេ ម្នាលអាវុសោទាំង-ឡាយ ភិក្ខុត្រូវតាំងទុកនូវសេចក្តីករុណា ត្រូវតាំងទុកនូវសេចក្តីអាណិត ត្រូវតាំងទុកនូវសេចក្តីអនុគ្រោះ ចំពោះបុគ្គលមានសភាពយ៉ាងនេះ (ដោយបំណងថា ) ធ្វើដូចម្តេច អ្នកនេះគប្បីលះកាយទុច្ចរិត ហើយចម្រើនកាយសុចរិត លះវចីទុច្ចរិត ហើយចម្រើនវចីសុចរិត លះមនោទុច្ចរិត ហើយចម្រើនមនោសុចរិតនឹងគេទៅហ្ន៎។ ដំណើរនេះ ព្រោះហេតុអ្វី ។ ព្រោះថាកុំឱ្យអ្នកនេះ បែកធ្លាយរាងកាយស្លាប់ទៅកើតក្នុងកំណើតតិរច្ឆាន បិត្តិវិស័យ អសុរកាយ និងនរកបានឡើយក៏មានឧបមេយ្យយ៉ាងនោះដែរ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំងនោះ បុគ្គលណា មានសេចក្តីប្រព្រឹត្ត ដោយកាយបរិសុទ្ធ មានសេចក្តីប្រព្រឹត្ត ដោយវាចាក៏បរិសុទ្ធ ទាំងបានឱកាសស្ងប់នៃចិត្តនិងសេចក្តីជ្រះថ្លានៃចិត្ត ក្នុងកាលម្តងៗ

តើភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះ ដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ស្រះបោក្ខរណី មានទឹកថ្លា ឆ្ងាញ់ ត្រជាក់ ស មានកំពង់រាបល្អ គួររីករាយ ដេរដាសដោយដើមឈើផ្សេងៗ ហើយមានបុរសក្ដៅខ្លាំងដោយកម្ដៅថ្ងៃ ត្រូវកម្ដៅថ្ងៃគ្របសង្កត់ នឿយហត់ អន្ទះអន្ទែង ស្រេក ដើរមកដល់ បុរសនោះ ក៏ចុះក្នុងស្រះបោក្ខរណីនោះ ងូតផង ផឹកផង ហើយត្រឡប់ឡើងមក អង្គុយ ឬដេកក្រោមម្លប់ឈើ ប្របស្រះបោក្ខរណីនោះឯង មានឧបមាយ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលណាមានសេចក្ដីប្រព្រឹត្ត ដោយកាយដ៏បរិសុទ្ធ មានសេចក្ដីប្រព្រឹត្ត ដោយវាចាក៏បរិសុទ្ធ ទាំងបានឱកាសស្ងប់នៃចិត្ត និងសេចក្ដីជ្រះថ្លានៃចិត្តក្នុងកាលម្ដងៗ ភិក្ខុត្រូវធ្វើទុកក្នុងចិត្តនូវសេចក្ដីប្រព្រឹត្ត ដោយកាយដ៏បរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះផង ត្រូវធ្វើទុកក្នុងចិត្តនូវសេចក្ដីប្រព្រឹត្ត ដោយវាចាដ៏បរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះផង (ព្រោះ) បុគ្គលនោះ បានឱកាសស្ងប់នៃចិត្ត ក្នុងកាលម្ដងៗឯណា ភិក្ខុត្រូវធ្វើទុកក្នុងចិត្តនូវការបាននូវឱកាសស្ងប់នៃចិត្ត និងសេចក្ដីជ្រះថ្លានៃចិត្ត ក្នុងកាលម្ដងៗនោះរបស់បុគ្គលនោះ ក្នុងសម័យនោះឯង ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ។





ម្នាលអាវុសោទាំងឡាយ ចិត្តជ្រះថ្លាព្រោះមកគប់ប្រសព្វនឹងបុគ្គលដែលមានគុណគួរឱ្យជ្រះថ្លាបំផុត ។ ម្នាលអាវុសោទាំងឡាយ គំនុំកើតឡើងដល់ភិក្ខុ ភិក្ខុត្រូវកម្ចាត់បង់សព្វគ្រប់ ដោយអាឃាតប្បដិវិន័យណា អាឃាតប្បដិវិន័យនោះមាន ៥ យ៉ាងដូច្នេះឯង ។

បិដកលេខ ៤៩ ទំព័រ ១០៩ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់អំពីការគិតហើយកើតនូវសេចក្ដីគុំគួន ៩ យ៉ាង មានដូចតទៅ :

ម្នាលភិក្ខុទាំងឡាយ អាឃាតវត្ថុ (ហេតុជាទីតាំងនៃសេចក្ដីគុំគួន) នេះមាន ៩ យ៉ាង ។ អាឃាតវត្ថុ ៩ យ៉ាង តើដូចម្ដេចខ្លះ ។ គឺបុគ្គលចងគំនុំដោយគិតថា ជនឯណោះបានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះកំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះនឹងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះ បានប្រព្រឹត្តហើយនូវអំពើមិនជាប្រយោជន៍ ដល់សត្វនិងសង្ខារជាទីស្រឡាញ់ជាទីគាប់ចិត្តរបស់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះកំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់សត្វនិងសង្ខារជាទីស្រឡាញ់ជាទីគាប់ចិត្តរបស់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់សត្វនិង

សង្ខារជាទីស្រឡាញ់ជាទីគាប់ចិត្តរបស់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះបានប្រព្រឹត្តនូវអំពើជាប្រយោជន៍ ដល់សត្វនិងសង្ខារមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់សត្វនិងសង្ខារមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះនឹងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់សត្វនិងសង្ខារ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ១ ។ ម្នាលភិក្ខុទាំងឡាយ អាឃាតវត្ថុ ៩ យ៉ាងនេះឯង។

បិដកលេខ ៤៩ ទំព័រ ១១១ ព្រះអង្គទ្រង់សម្តែងអំពីការកម្ចាត់បង់នូវសេចក្តីគុំគួន ដោយការគិតពិចារណាត្រូវ ៩ យ៉ាង :

ម្នាលភិក្ខុទាំងឡាយ អាឃាតវត្ថុ (ហេតុជាទីតាំងនៃសេចក្តីគុំគួន )នេះមាន ៩ យ៉ាង ។ អាឃាតប្បដិវិន័យ (ការកម្ចាត់បង់នូវសេចក្តីគុំគួន ) នេះមាន ៩ យ៉ាង ។ អាឃាតប្បដិវិន័យទាំង ៩ យ៉ាង តើដូចម្តេច ។ គឺបុគ្គលកម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញហើយ ព្រោះហេតុនោះ អាត្មាអញ គប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា





ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញ គប្បីបាននូវអំពើ មិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញគប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះបានប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់សត្វ និងសង្ខារជាទីស្រឡាញ់ជាទីគាប់ចិត្តរបស់អាត្មាអញហើយ ព្រោះហេតុនោះ អាត្មាអញ គប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់សត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះអាត្មាអញគប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់សត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញ គប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ បានប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់

សត្វនិងសង្ខារ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ហើយព្រោះហេតុនោះ អាត្មាអញ គប្បីបាននូវអំពើជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះអំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់សត្វនិងសង្ខារមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញគប្បីបាននូវអំពើជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់សត្វនិងសង្ខារ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញគប្បីបាននូវអំពើជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ ។ ម្នាលភិក្ខុទាំងឡាយ អាឃាតប្បដិវិន័យ ៩ យ៉ាងនេះឯង ។

គប្បីសិក្សាប្រកបផ្សំដោយព្រះធម៌ក្នុងបិដកលេខ ៥០ ទំព័រ ៣២៦, បិដកលេខ ១៣ ទំព័រ ២០៦ (វិន័យធរលុះនៅក្នុងទោសាគតិដោយវត្ថុ ១៨ ប្រការ) , បិដកលេខ ៨២ ទំព័រ ២៥៦ (ខុទ្ទកវត្ថុវិភង្គ) ទំព័រ ២៦០ ក៏មានដែរ ។ ក្នុងគម្ពីរវិសុទ្ធិមគ្គ បានពន្យល់អំពីវិធីគិតពិចារណាដើម្បីរម្ងាប់សេចក្ដីក្រោធ (មើលក្នុងសៀវភៅវិធីរម្ងាប់សេចក្ដីក្រោធ) ។

ព្រះធម៌ដែលបានលើកមកបញ្ជាក់ប៉ុណ្ណេះ គ្រាន់តែជាតួ



យ៉ាង សម្ដែងឱ្យឃើញក្បួនវិធីពិចារណា ដែលចាត់នៅក្នុងពួកយោនិសោមនសិការ ក្នុងការញ៉ាំងកុសលធម៌ឬគុណធម៌ឱ្យចម្រើន ។

មានអង្គប្រកបដ៏សំខាន់ ដែលសម្រាប់ជួយឱ្យការគិតពិចារណាប្រព្រឹត្តទៅជាយោនិសោមនសិការ បានដល់ **សតិ** ។ សតិជាគុណធម៌មានឧបការគុណដ៏ក្រៃលែង បានជួយបញ្ឈប់នូវការគិតអណ្ដែតអណ្ដូង រវើរវាយជាអយោនិសោមនសិការ ហើយជួយទាញបង្វែរ ឱ្យត្រឡប់មកចាប់ផ្ដើមក្នុងផ្លូវនៃយោនិសោមនសិការជាថ្មីវិញ ដូច្នេះសតិទើបជាអង្គធម៌ដែលអ្នកមាននូវយោនិសោមនសិការ មានការអប់រំជានិច្ច ។

ដើម្បីថែរក្សា និងអប់រំចម្រើននូវសតិដែលជាគុណធម៌មានប្រយោជន៍ដ៏ក្រៃលែងនោះ ត្រូវជៀសវាង ឬវៀរចាកនូវអបាយមុខ និងកាមគុណផ្សេងៗ ហើយព្យាយាមស្ដាប់ធម៌ រៀនធម៌រម្ងាប់អកុសលនីវរណៈ និងព្យាយាមបំពេញនូវបុណ្យកុសលផ្សេងៗឱ្យសម្បូណ៌ក្នុងជីវិតប្រចាំថ្ងៃ ។

☆ ☆ ☆

## ៩_វិធីគិតពិចារណាតាមបែបការរស់នៅជាមួយនឹងបច្ចុប្បន្ន

វិធីគិតពិចារណាទី ៩ នេះ គ្រាន់តែជាការបំបែកអំពីការគិតពិចារណាក្នុងពួកយោនិសោមនសិការមុនៗប៉ុណ្ណោះ ពីព្រោះមានផ្នែកដែលគួរធ្វើការយល់ចូលចិត្តពិសេស និងមានសេចក្តីសំខាន់ក្នុងផ្នែកដោយឡែកមួយនេះផ្ទាល់ទៀតផង ។

វិធីគិតពិចារណាតាមបែបរស់នៅជាមួយនឹងបច្ចុប្បន្ននេះ មានសេចក្តីរួមចូលក្នុង **សតិប្បដ្ឋាន** ៤ ។ សតិប្បដ្ឋានបដិបត្តិគឺសតិរលឹកដឹង មានស្មារតី មានការភ្ញាក់រលឹកចំពោះសភាវៈដែលកំពុងប្រាកដ កំពុងមាន កំពុងតែប្រព្រឹត្តទៅនៅក្នុងបច្ចុប្បន្ន ។ ឯយោនិសោមនសិការ គឺគិតពិចារណាចំពោះសភាវៈ តាមតែសតិបានរលឹកដឹងនោះឯង ។

ចំណុចដែលត្រូវយល់ជាពិសេស ទាក់ទងនឹងវិធីគិតពិចារ-ណាបែបនេះ គឺនៅត្រង់ការដែលមានអ្នកយល់ខុសក្នុងរឿងរស់នៅក្នុងបច្ចុប្បន្ន ឬមានបច្ចុប្បន្នធម៌ជាអារម្មណ៍ ។ ដោយគេគិតយល់ថា ព្រះពុទ្ធសាសនាប្រដៅឱ្យគិតចំពោះតែអ្វីៗ ដែលមានចំពោះមុខ កំពុងប្រព្រឹត្តទៅក្នុងបច្ចុប្បន្នប៉ុណ្ណោះ មិនឱ្យគិត





ពិចារណាដល់អតីត ឬអនាគត រហូតដល់មិនឱ្យគិតត្រៀមរៀបចំផែនការអ្វីៗ សម្រាប់កាលខាងមុខទៀតផង ។

កាលបើយល់ខុសហើយ ក៏បដិបត្តិខុសអំពីគោលធម៌ព្រះពុទ្ធសាសនា ពោលគឺគិតខុស និយាយខុស ។ល។ គឺជាការធ្លាក់ចុះក្នុងផ្លូវខុសហ្នឹងឯង ។

លក្ខណៈដែលមិននៅក្នុងបច្ចុប្បន្ននោះ តាមពិតគឺជាគំនិតដែលប្រកបដោយតណ្ហា នឹកអាល័យអតីត ឬនឹកប្រាថ្នាអនាគត មានលក្ខណៈជាការបោះបង់ចោលនូវបច្ចុប្បន្ន ។ បើជាការគិតដោយសតិសម្បជញ្ញៈ គិតដោយអំណាចនៃបញ្ញាវិញនោះ ទោះជាការគិតនោះ គិតក្នុងខណៈបច្ចុប្បន្នក្តី គិតដល់អតីតក្តី គិតដល់អនាគតក្តី ក៏គឺជាការរស់នៅក្នុងបច្ចុប្បន្នតែប៉ុណ្ណោះ ។ ការគិតពិចារណាដោយបញ្ញា ទាក់ទងទៅនឹងរឿងអតីត បច្ចុប្បន្ន និងអនាគត គឺជាការគិតពិចារណាដ៏ត្រឹមត្រូវ និងសំខាន់ទៅតាមគោលធម៌ព្រះពុទ្ធសាសនា គ្រប់លំដាប់នៃធម៌ តាំងពីទាបដល់ខ្ពស់ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ទូន្មានឱ្យសិក្សាចាកអតីតក្នុងរឿងផ្សេងៗ សេចក្តីមិនប្រមាទគឺត្រូវប្រយ័ត្នចំពោះភ័យក្នុងអនាគត និងកាលទាំង ៣ ក្នុងបដិច្ចសមុប្បាទធម៌ជាដើម ។

« បិដកលេខ ២៨   ទំព័រ ២ »

## **ភទ្ទេករត្តសុត្ត**

**ភគវា ឯតទវោច** ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា :

**អតីតំ នាន្វាគមេយ្យ    នប្បដិកង្ខេ អនាគតំ**
**យទតីតម្បហីនន្តំ    អប្បត្តញ្ច អនាគតំ ។**

បុគ្គលមិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ដែលកន្លងទៅហើយ មិនគប្បីប្រាថ្នាបញ្ចក្ខន្ធ ដែលមិនទាន់មកដល់ឡើយ ព្រោះបញ្ចក្ខន្ធណា ជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណា ជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ ។

**បច្ចុប្បន្នញ្ច យោ ធម្មំ    តត្ថ តត្ថ វិបស្សតិ**
**អសំហីរំ អសង្កុប្បំ    តំ វិទ្វា មនុព្រូហយេ ។**

បុគ្គលណា ឃើញច្បាស់នូវធម៌ជាបច្ចុប្បន្នក្នុងទីនោះៗ (បុគ្គលនោះរមែងដឹងច្បាស់នូវព្រះនិព្វាន ) លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម មិនកម្រើកញាប់ញ័រដោយពួកកិលេសហើយ គប្បីចម្រើនឱ្យរឿយៗនូវផលសមាបត្តិ ដែលមានព្រះនិព្វាននោះជាអារម្មណ៍ ។





**អជ្ជេវ កិច្ចមាតប្បំ    កោ ជញ្ញា មរណំ សុវេ**
**ន ហិ នោ សង្គរន្តេន    មហាសេនេន មច្ចុនា ។**

ឯការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា ទាល់តែថ្ងៃស្អែកបានស្លាប់ ព្រោះថាការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ ។

**ឯវំ វិហារិមាតាបឹ    អហោរត្តមតន្ទិតំ**
**តំ វេ ភទ្ទេករត្តោតិ    សន្តោ អាចិក្ខតេ មុនីតិ ។**

អ្នកប្រាជ្ញដែលស្ងប់ទុក្ខហើយ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ គឺជាអ្នកមានព្យាយាមដុតកិលេស ជាអ្នកមិនខ្ជិលច្រអូស អស់យប់និងថ្ងៃនោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

គប្បីមើលក្នុងបិដកលេខ ២៨ តាំងពីទំព័រ ១ ដល់ទំព័រ ៥៣ ជាការបញ្ជាក់ក្នុង **ភទ្ទេករត្តសុត្ត** ។

« បិដកលេខ ២៩   ទំព័រ ១០ »

## **អរញ្ញសុត្ត**

លុះទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ទើបពោល

គាថាសួរព្រះដ៏មានព្រះថា :

**អរញ្ញេ វិហរន្តានំ សន្តានំ ព្រហ្មចារិនំ**
**ឯកភត្តំ ភុញ្ជមានានំ កេន វណ្ណោ បសីទតីតិ ។**

ពួកភិក្ខុជាព្រហ្មចារី នៅក្នុងព្រៃ មានចិត្តស្ងប់រម្ងាប់ ឆាន់អាហារតែម្តង ហេតុអ្វីបានជា ពណ៌សម្បុរកាយ នៅតែផូរផង់បាន ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា :

**អតីតំ នានុសោចន្តិ នប្បជប្បន្តិ នាគតំ**
**បច្ចុប្បន្នេន យាបេន្តិ តេន វណ្ណោ បសីទតិ ។**

ពួកភិក្ខុនោះមិនសោកស្តាយនូវរបស់ដែលកន្លងទៅហើយ ទាំងមិនប្រាថ្នារបស់ដែលមិនទាន់មកដល់ គ្រាន់តែចិញ្ចឹមជីវិតដោយរបស់ជាបច្ចុប្បន្ន ហេតុនោះបានជាពណ៌សម្បុរកាយនៅតែផូរផង់បាន ។

**អនាគតប្បជប្បាយ អតីតស្សានុសោចនា**
**ឯតេន ពាលា សុស្សន្តិ នឡោវ ហរិតោ លុតោតិ។**

ពួកជនពាលតែងស្រពាប់ស្រពោន ដោយហេតុទាំងពីរនោះ គឺព្រោះសេចក្តីប្រាថ្នានូវរបស់ដែលមិនទាន់មកដល់ ១ និងសេចក្តីអាឡោះអាល័យ ចំពោះរបស់ដែលកន្លងទៅហើយ ១





ដូចដើមបបុសខៀវស្រស់ ដែលត្រូវគេច្រូត ( ដាក់លើថ្មក្តៅ ) ដូច្នោះឯង ។

គប្បីសង្កេតចំពោះការចេះដឹងដែលទាក់ទងនឹងពេលវេលាក្នុងផ្នែកដែលមិនប្រព្រឹត្តទៅតាមអំណាចនៃតណ្ហា ដូចព្រះគាថាជាខាងដើម រួចហើយគប្បីផ្ទៀងផ្ទាត់នឹងការបដិបត្តិចំពោះកាលមានអតីតកាលជាដើមជាបន្តទៀត ។ នៅក្នុង **ចូឡរាហុលោវាទសូត្រ** បិដកលេខ ២៣ ទំព័រ ២១៨ ព្រះអង្គទ្រង់ត្រាស់ទូន្មានដល់ព្រះរាហុល ឱ្យគិតពិចារណាមើលនូវកាយកម្ម វចីកម្ម និងមនោកម្ម ដែលបានធ្វើរួចហើយ ។

ក្នុងបិដកលេខ ៤៤ ទំព័រ ២០៩ ដល់ ២៣០ ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីភ័យដែលរមែងមានក្នុងអនាគត ហើយភិក្ខុត្រូវពិចារណាឱ្យឃើញ ដើម្បីជាអ្នកមិនប្រមាទ មានព្យាយាមដុតនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។

ដែលថា «រស់នៅជាមួយនឹងបច្ចុប្បន្ន» គឺជាឈ្មោះនៃការមានសតិក្នុងជីវិតដែលកំពុងរស់នៅ ព្រោះថា បើមិនមានសតិឈ្មោះថាស្លាប់ហើយ ។ គប្បីសិក្សានូវព្រះគាថាធម្មបទព្រមទាំងអដ្ឋកថា ប្រកបផ្សំក្នុងវិធីគិតពិចារណាទី ៩ នេះ និងដើម្បីបានយល់អំពីផ្លូវនៃការមិនស្លាប់ផង ដូចតទៅ :

## ព្រះគាថាធម្មបទ អប្បមាទវគ្គ

បិដកលេខ ៥២ ទំព័រ ២៥

**អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ**

**អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា ។**

សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយ ដែលមិនប្រមាទហើយ ឈ្មោះថាមិនស្លាប់ ជនទាំងឡាយ ដែលប្រមាទហើយ ទុកដូចជាបុគ្គលដែលស្លាប់ទៅហើយ ។

**ឯតំ វិសេសតោ ញត្វា អប្បមាទម្ហិ បណ្ឌិតា**

**អប្បមាទេ បមោទន្តិ អរិយានំ គោចរេ រតា ។**

ពួកបណ្ឌិត បានជ្រាបនូវដំណើរនេះ ដោយវិសេសហើយ (ទើបឋិតនៅ ) ក្នុងសេចក្តីមិនប្រមាទ រីករាយក្នុងសេចក្តីមិនប្រមាទ ត្រេកអរក្នុងធម៌ជាទីគោចរនៃព្រះអរិយបុគ្គលទាំងឡាយ។

**តេ ឈាយិនោ សាតតិកា និច្ចំ ទឡ្ហបរក្កមា**

**ផុសន្តិ ធីរា និព្វានំ យោគក្ខេមំ អនុត្តរំ ។**

បណ្ឌិតអ្នកមិនប្រមាទទាំងនោះ មានការសម្លឹងពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួន





ជានិច្ច ជាអ្នកមានប្រាជ្ញា តែងពាល់ត្រូវនូវព្រះនិព្វានដ៏ប្រសើរបំផុត ជាទីក្សេមចាកយោគធម៌ទាំងពួង ។

### អដ្ឋកថា

បណ្តាបទទាំងអស់នោះ បទថា **អប្បមាទោ** រមែងសម្តែងសេចក្តីទូលំទូលាយ គឺមានន័យច្រើន ។

ពិតណាស់ ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកទាំងអស់ រមែងរួមចុះចូលក្នុងសេចក្តីមិនប្រមាទហ្នឹងឯង ។ ក្នុងសំយុត្តនិកាយ មហាវារវគ្គ (បិដកលេខ ៣៧ ទំព័រ ១១៦ ) ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា :

ម្នាលភិក្ខុទាំងឡាយ ស្នាមជើងឯណានីមួយនៃសត្វដែលត្រាច់លើផែនដី ស្នាមជើងទាំងអស់នោះ តែងដល់នូវការប្រចុះក្នុងស្នាមជើងនៃដំរី ស្នាមជើងនៃដំរីប្រាកដជាប្រសើរជាងស្នាមជើងនៃពួកសត្វទាំងនោះ ព្រោះហេតុថាស្នាមជើងនោះ ជាស្នាមជើងធំ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កុសលធម៌ទាំងឡាយឯណានីមួយ កុសលធម៌ទាំងអស់នោះ មានអប្បមាទធម៌ជាមូលមានអប្បមាទធម៌ជាទីប្រជុំចុះ អប្បមាទធម៌ប្រាកដជាប្រសើរជាងកុសលធម៌ទាំងនោះ ក៏យ៉ាងនោះដែរ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យថាប្រសើរនោះ ជាទីសង្ឃឹមរបស់ភិក្ខុដែលមិនប្រមាទ ភិក្ខុអ្នកមិនប្រមាទ នឹងចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឱ្យក្រាស់ក្រែលនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន ។

សេចក្តីមិនប្រមាទនេះ ដោយអត្ថ ឈ្មោះថា ការមិននៅប្រាសចាកសតិ ព្រោះពាក្យថា សេចក្តីមិនប្រមាទ ជាឈ្មោះរបស់សតិដែលតាំងមាំជានិច្ច ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អមតំ បទំ** ព្រះនិព្វាន ព្រះដ៏មានព្រះភាគត្រាស់ហៅថា **អមតះ** ព្រោះព្រះនិព្វាននោះមិនចាស់ មិនស្លាប់ ព្រោះជាធម្មជាតិមិនកើត ហេតុនោះ ព្រះអង្គទើបត្រាស់ហៅព្រះនិព្វានថា អមតៈ ។ សត្វទាំងឡាយរមែងដល់អធិប្បាយថា រមែងសម្រេចនូវអមតៈដោយសេចក្តីមិនប្រមាទនេះ ហេតុនោះសេចក្តីមិនប្រមាទនេះទើបឈ្មោះថា ជាគ្រឿងដល់ ។ សេចក្តីមិនប្រមាទ លោកអធិប្បាយទុកថា « ជាឧបាយនាំឱ្យបានសម្រេចដល់អមតៈ » ទើបឈ្មោះថា **អមតំ បទំ** ។

ភាវៈគឺសេចក្តីស្រវឹង ឈ្មោះថាសេចក្តីប្រមាទ ។ ពាក្យថា សេចក្តីប្រមាទនេះ ជាឈ្មោះនៃការបាត់បង់សតិ ពោលគឺការវង្វេងភ្លេចសតិហ្នឹងឯង ។





បទថា **មច្ចុនោ** ប្រែថា សេចក្តីស្លាប់ ។ បទថា **បទំ** គឺជាឧបាយបានដល់ផ្លូវ ។ ពិតណាស់ បុគ្គលដែលប្រមាទហើយ រមែងមិនប្រព្រឹត្តកន្លងនូវជាតិបានឡើយ កាលកើតហើយ ក៏រមែងចាស់រមែងស្លាប់ ហេតុនោះសេចក្តីប្រមាទ ទើបឈ្មោះថា ជាផ្លូវនៃមច្ចុ គឺរមែងនាំចូលទៅរកសេចក្តីស្លាប់ ។

បាទព្រះគាថាថា **អប្បមត្តា ន មីយន្តិ** ដោយសេចក្តីថា បុគ្គលប្រកបដោយសតិឈ្មោះថា អ្នកមិនប្រមាទហើយ ។ អ្នកណាៗ មិនគប្បីកំណត់ថា « អ្នកមិនប្រមាទហើយរមែងមិនស្លាប់ គឺជាអ្នកមិនចាស់និងមិនស្លាប់ »ដូច្នេះឡើយ ព្រោះថាសត្វណាៗ ឈ្មោះថាមិនចាស់ និងមិនស្លាប់ រមែងមិនមាន តែឈ្មោះថាវដ្តៈរបស់សត្វដែលជាអ្នកប្រមាទហើយ កំណត់មិនបានឡើយ ឯវដ្តៈរបស់អ្នកមិនប្រមាទរមែងកំណត់បាន ហេតុនោះ បុគ្គលអ្នកប្រមាទហើយ សូម្បីរស់នៅ ក៏ឈ្មោះថាស្លាប់ហើយដោយពិត ព្រោះភាពជាអ្នកមិនផុតចាកទុក្ខ មានជាតិទុក្ខជាដើម ។ ចំណែកបុគ្គលមិនប្រមាទ ចម្រើនអប្បមាទលក្ខណៈហើយ ធ្វើឱ្យច្បាស់នូវមគ្គនិងផលដោយឆាប់រហ័ស រមែងមិនកើត ក្នុងអត្តភាពទី ២ ឬទី ៣ ហេតុនោះ បុគ្គលអ្នកមិនប្រមាទទាំងនោះ រស់នៅក៏ដោយ ស្លាប់ហើយក៏ដោយ ឈ្មោះថារមែងមិនស្លាប់ដោយ ពិត ។

បាទព្រះគាថាថា **យេ បមត្តា យថា មតា** ដោយសេចក្ដីថា ពួកសត្វណាប្រមាទហើយ សត្វទាំងនោះ រមែងដូចជាសត្វដែលស្លាប់ហើយ ដោយការដាច់នូវជីវិតិន្ទ្រិយ មានវិញ្ញាណទៅប្រាសហើយ ដូចជាអង្កត់អុស ដូច្នោះឯង ព្រោះសេចក្ដីដែលខ្លួនស្លាប់ហើយ ដោយសេចក្ដីស្លាប់គឺការប្រមាទ ។ ពិតណាស់ សូម្បីចិត្តដួង ១ ថា « យើងនឹងថ្វាយទាន យើងនឹងរក្សាសីល យើងនឹងធ្វើឧបោសថកម្ម » ដូច្នេះ រមែងមិនកើតឡើង ដល់គេទាំង-ឡាយដែលជាគ្រហស្ថឡើយ ។ ចិត្តដួង ១ ថា « យើងនឹងបំពេញវត្តទាំងឡាយ មានអាចរិយវត្តនិងឧបជ្ឈាយវត្តជាដើម យើងនឹងសមាទានធុតង្គ យើងនឹងចម្រើនភាវនា » ដូច្នេះ រមែងមិនកើតឡើងដល់គេទាំងនោះ សូម្បីបុគ្គលដែលជាបព្វជិតហ្នឹងឯង ដូចចិត្តដួង ១ មិនកើតឡើងដល់សត្វដែលស្លាប់ហើយដូច្នោះ ។

សត្វដែលប្រមាទហើយ នឹងមានអ្វីជាគ្រឿងធ្វើឱ្យផ្សេងគ្នាពីសត្វដែលស្លាប់ហើយនោះ ព្រោះដូច្នោះ រមែងដូចមនុស្សដែលស្លាប់ហើយ ។

បាទព្រះគាថាថា **ឯតំ វិសេសតោ ញត្វា** ដោយសេចក្ដីថា ដឹងសេចក្ដីនោះដោយការប្លែកគ្នា គឺថា ការស្ទុះចេញចាកវដ្ដៈរបស់បុគ្គលប្រមាទហើយ រមែងមិនមាន ឯការស្ទុះចេញចាកវដ្ដៈ





របស់បុគ្គលមិនប្រមាទហើយទើបមាន ។

មានសំណួរថា -តើអ្នកណា រមែងដឹងនូវសេចក្ដីប្លែកគ្នានោះ ?

មានចម្លើយថា -បណ្ឌិតទាំងឡាយ ដែលតាំងនៅក្នុងសេចក្ដីមិនប្រមាទ រមែងដឹង ។

អធិប្បាយថា -បណ្ឌិតណា អ្នកមាននូវបញ្ញា តាំងនៅក្នុងសេចក្ដីមិនប្រមាទរបស់ខ្លួនហើយ ចម្រើននូវសេចក្ដីមិនប្រមាទ បណ្ឌិតនោះ រមែងដឹងហេតុដែលប្លែកគ្នានោះឯង ។

បាទព្រះគាថាថា **អប្បមាទេ បមោទន្តិ** ដោយសេចក្ដីថា បណ្ឌិតទាំងនោះ គ្រាកាលដឹងយ៉ាងនេះហើយ រមែងរីករាយ គឺជាអ្នកមានមុខញញឹមញញែម បានដល់ត្រេកអររីករាយក្នុងសេចក្ដីមិនប្រមាទរបស់ខ្លួននោះ ។

បាទព្រះគាថាថា **អរិយានំ គោចរេ រតា** ដោយសេចក្ដីថា បណ្ឌិតទាំងនោះ រីករាយក្នុងសេចក្ដីមិនប្រមាទយ៉ាងនេះ ចម្រើននូវអប្បមាទធម៌នោះហើយ រមែងជាអ្នកត្រេកអរគឺត្រេកអរដ៏ក្រៃ-លែងក្នុងពោធិបក្ខិយធម៌ ៣៧ ប្រការ មានសតិប្បដ្ឋាន ៤ ជាដើម និងក្នុងលោកុត្តរធម៌ ៩ ប្រការ ដែលរាប់ថាធម៌ជាគ្រឿងគោចររបស់ព្រះអរិយៈទាំងឡាយ គឺព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះបច្ចេក-

ពុទ្ធ និងព្រះសាវ័កទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធ ។

ពីរបទថា **តេ ឈាយិនោ** មានសេចក្ដីថា បណ្ឌិតអ្នកមិនប្រមាទទាំងនោះ ជាអ្នកសម្លឹងដោយឈានទាំង ២ យ៉ាងគឺ ដោយអារម្មណូបនិជ្ឈាន ពោលគឺសមាបត្តិ៨ និងដោយលក្ខណូបនិជ្ឈាន ពោលគឺ វិបស្សនាមគ្គ និងផល ។

បទថា **សាតតិកា** មានសេចក្ដីថា ជាអ្នកមានសេចក្ដីព្យាយាម ដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងតាមផ្លូវចិត្ត ប្រព្រឹត្តទៅដោយការជាប់តគ្នា ចាប់តាំងអំពីពេលដែលចេញបួសរហូតដល់ការបានសម្រេចដល់ព្រះអរហត្ត ។

បាទព្រះគាថាថា **និច្ចំ ទឡ្ហបរក្កមា** មានសេចក្ដីថា អ្នកដែលប្រកបដោយសេចក្ដីព្យាយាមមានសភាពបែបនេះគឺ « ផលនោះណា ដែលបុគ្គលគប្បីសម្រេចបានដោយកម្លាំងរបស់បុរស ដោយសេចក្ដីព្យាយាមរបស់បុរស ដោយការប្រឹងប្រែងរបស់បុរស នៅមិនទាន់បានសម្រេចផលនោះ ហើយបញ្ឈប់នូវសេចក្ដីព្យាយាម រមែងមិនមាន » ដូច្នេះ ឈ្មោះថា ប្រឹងប្រែងមាំ ។ ឈ្មោះថា ប្រព្រឹត្តទៅហើយជានិច្ច ដោយហេតុមិនរួញថយក្នុងរវាងនោះ ។

ក្នុងពាក្យថា **ផុសន្តិ** នេះគប្បីជ្រាបសេចក្ដីវិនិច្ឆ័យដូចតទៅ:



ការពាល់ត្រូវមាន ២ គឺ

**ញាណផុសនា** (ការពាល់ត្រូវដោយញាណ) ១ **វិបាកផុសនា** (ការពាល់ត្រូវដោយវិបាក) ១ ។ ក្នុងផុសនា ២ យ៉ាងនោះ មគ្គ ៤ ឈ្មោះថា ញាណផុសនា ឯផល ៤ ឈ្មោះថា វិបាកផុសនា ។ ក្នុងផុសនា ២ យ៉ាងនោះ វិបាកផុសនា ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សម្ដែងយកក្នុងបទថាផុសន្តិនេះ ។ បណ្ឌិតជាអ្នកប្រាជ្ញកាលធ្វើនូវព្រះនិព្វានឱ្យជាក់ច្បាស់ដោយអរិយផល ឈ្មោះថា រមែងធ្វើនូវព្រះនិព្វានឱ្យជាក់ច្បាស់ដោយវិបាកផុសនា ។

បាទព្រះគាថាថា **យោគក្ខេមំ អនុត្តរំ** ដោយសេចក្ដីថា ព្រះនិព្វានដែលជាដែនក្សេម គឺមិនមានភ័យអំពីយោគធម៌ ៤ យ៉ាង (ដែលយោគធម៌ ៤ យ៉ាងនេះគឺកាមយោគ ១ ភវយោគ ១ ទិដ្ឋិយោគ ១ អវិជ្ជាយោគ ១) ដែលតែងញាំងនូវមហាជនឱ្យលិចចុះក្នុងវដ្ដៈ ។ ឈ្មោះថា ប្រសើរខ្ពង់ខ្ពស់ ព្រោះជាធម៌ប្រសើរជាងលោកិយធម៌ និងលោកុត្តរធម៌ទាំងពួង ។

ដូចដែលបានលើកយកនូវព្រះពុទ្ធវចនៈ មកបញ្ជាក់ហើយនោះ ល្មមជួយឱ្យធ្វើការបែងចែកបាន រវាងការគិតដល់អតីត និងអនាគត តាមអំណាចតណ្ហា និងការគិតដល់អតីត និងអនាគតតាមអំណាចនៃបញ្ញា ។

តណ្ហាដែលនាំឱ្យគិតរវើរវាយឥតប្រយោជន៍ នាំឱ្យរីករាយជាប់ជំពាក់ និងនាំឱ្យសោកសៅអាឡោះអាល័យ ព្រមដោយកិលេសផ្សេងៗទៀត សុទ្ធតែជាគ្រឿងបំផ្លាញពេលវេលា និងបំផ្លាញគុណភាពរបស់ចិត្តឱ្យសាបសូន្យទៅ ។ ព្រោះហេតុនៃទោសរបស់តណ្ហាជាដើមដូច្នេះហើយ ទើបបានជាត្រូវមានយោនិសោមនសិការក្នុងជីវិត ដើម្បីរក្សានូវពេលវេលានៃជីវិតឱ្យឋិតនៅក្នុងប្រយោជន៍ ។ អតីតកាលនៃជីវិតបានកន្លងទៅហើយ អស់ទៅហើយ ហួសទៅហើយ ឯអនាគតនៃជីវិតវិញនោះមិនទាន់មកដល់ឡើយ ដូច្នេះហើយ បើបណ្ដាលឱ្យបច្ចុប្បន្នជារបស់តណ្ហាតាំងនៅក្នុងសេចក្ដីប្រមាទនោះ តើយើងត្រូវរស់នៅជាមួយនឹងអ្វីទៅ បើយើងមិនមានពេលវេលាសម្រាប់ខ្លួនឯងផងនោះ (ខ្លួនឯងក្នុង ទីនេះគឺសំដៅដល់កុសលធម៌) ។

ចំណែក ការរស់នៅដោយស្មារតី ដោយសេចក្ដីមិនប្រមាទ មានបញ្ញាជាគ្រឿងរក្សាខ្លួន រក្សាពេលវេលា រក្សាចិត្ត រក្សាជីវិត និងជួយឱ្យកើតប្រយោជន៍ក្នុងផ្លូវបដិបត្តិ ជួយឱ្យការបដិបត្តិក្នុងបច្ចុប្បន្នត្រឹមត្រូវបានផលល្អច្រើនឡើង ។

កាលបើបដិបត្តិបានត្រឹមត្រូវតាមបែបរស់នៅក្នុងបច្ចុប្បន្នជាមួយនឹងប្រាជ្ញាស្មារតីដូច្នេះ រមែងមានការទំនុកបម្រុង ឬមាន





ការត្រៀមរៀបចំ ដាក់ផែនការសម្រាប់អនាគត ដូចយ៉ាងកិច្ចការដ៏សំខាន់របស់សង្ឃ ក្នុងសង្គាយនាគ្រាទី ១ ជាដើម ។

យោនិសោមនសិការ ទោះបីមានអារម្មណ៍ជាអតីតក្ដី មានអារម្មណ៍ជាអនាគតក្ដី ឬមានបច្ចុប្បន្នជាអារម្មណ៍ក្ដី ក៏សុទ្ធតែឱ្យសម្រេចកិច្ចក្នុងបច្ចុប្បន្នបានទាំងអស់ ដូចជាការនឹកឃើញដល់ព្រះពុទ្ធសាសនាតទៅអនាគត សង្ឃបានធ្វើកិច្ចដ៏សំខាន់ក្រៃលែងក្នុងបច្ចុប្បន្នគឺសង្គាយនានូវព្រះធម៌និងព្រះវិន័យហ្នឹងឯង ។

ក្នុងបណ្ដាំចុងក្រោយរបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គរំលឹកអំពីសង្ខារធម៌ ថារមែងមានការសាបសូន្យទៅជាធម្មតា ជារបស់អនិច្ចំ មានការកើតឡើងហើយ រមែងមានសេចក្ដីវិនាសជាម្ចាស់ ដូច្នេះ ទើបត្រូវញ៉ាំងកិច្ចដែលជាប្រយោជន៍ ឱ្យបានសម្រេចដោយសេចក្ដីមិនប្រមាទ ។ ប្រយោជន៍ជាចុងក្រោយបង្អស់ គឺការមិនប្រកាន់ មិនហួងហែងនូវសង្ខារធម៌ហ្នឹងឯង ពោលគឺព្រះនិព្វាន ។

☆☆☆

## ១០.វិធីគិតពិចារណាតាមបែបការចែកធម៌ចែកបុគ្គល

វិធីទី ១០ ជាវិធីគិតពិចារណា វែកញែក ចែកសេចក្តីឱ្យត្រឹមត្រូវ ហើយទើបពោល សរសើរ ឬនិន្ទាជាដើម ។

ក្នុងមនុស្សម្នាក់ៗ យើងមិនត្រូវចេះតែសរសើរទាំងអស់នោះទេ ហើយក៏មិនត្រូវចេះតែនិន្ទាទៅទាំងអស់នោះដែរ គឺត្រូវចែកជាផ្នែកៗ តាមសភាវៈល្អ និងតាមសភាវៈអាក្រក់ឱ្យដាច់ពីគ្នា ក្នុងសេចក្តីនេះត្រូវតែគិតពិចារណាឱ្យល្អិតល្អន់ កុំឱ្យលំអៀងដោយអគតិផ្សេងៗ ព្រោះថាបើសរសើរ ឬនិន្ទាខុស វាមានទោសខ្លាំងណាស់ ធ្វើឱ្យអ្នកស្តាប់យល់ខុស និងប្រព្រឹត្តខុស តែបើសរសើរ ឬនិន្ទាត្រឹមត្រូវ រមែងសម្រេចបានជាគុណដ៏ធំធេង ត្រង់ដែលធ្វើឱ្យអ្នកដ៏ទៃយល់ត្រូវ និងប្រព្រឹត្តត្រូវ ។

« បិដកលេខ ៥០ ទំព័រ ៣៨៣ »

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះអនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់បានក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទី





ដ៏សមគួរ ។ លុះអនាថបិណ្ឌិកគហបតី បានអង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគហបតី អ្នកបរិភោគកាមនេះ មាន ១០ ពួក ក្នុងលោក ។ ១០ ពួក តើដូចម្តេចខ្លះ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះស្វះស្វែងរកនូវភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកនូវភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេបានមកហើយ មិនធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកនូវភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់-សង្កិនគេ លុះស្វះស្វែងរកនូវភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឱ្យបានសុខឱ្យឆ្អែត តែមិនចែក រលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកនូវភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកនូវភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត ទាំងចែករលែក ធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី

ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំង-ឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វែងរកភោគៈទាំងឡាយត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន បានមកហើយ មិនធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគៈទាំង-ឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន បានមកហើយ ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត តែទាស់មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់-





សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន បានមកហើយ ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត ចែករលែក ធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ មិនធ្វើខ្លួន ឱ្យបានសុខ ឱ្យឆ្អែត មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកនូវភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត តែទាស់មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំង-ឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត ចែករលែក ធ្វើបុណ្យទាំងឡាយ តែនៅជាប់ ជ្រប់ ឈ្លក់ចិត្តនឹងភោគៈទាំងនោះ មិនឃើញទោស មិនមានបញ្ញាជាគ្រឿងរើខ្លួន

ហើយចេះតែបរិភោគ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ ថែមទាំងមិនងប់ មិនជ្រប់ មិនឈ្លក់ចិត្តនឹងភោគៈ ទាំងនោះទេ ឃើញទោស មានបញ្ញាជាគ្រឿងរំខ្លួន ហើយបរិភោគ ១ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ បានមកហើយ មិនធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀល ដោយហេតុ ៣ ប្រការ គឺគេតិះដៀល ដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ២ នេះថា មិនធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត គួរគេតិះដៀលដោយហេតុទី ៣ នេះថា មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេ



តិះដៀល ដោយហេតុ ៣ ប្រការនេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឱ្យ បានសុខ ឱ្យឆ្អែតតែទាស់ មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀល ដោយហេតុ ២ ប្រការ គេសរសើរ ដោយហេតុ ១ ប្រការ គឺគេតិះដៀលដោយ ហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេសរសើរ ដោយហេតុ ១ ប្រការនេះថា ចេះធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត គេតិះដៀលដោយ ហេតុទី ២ នេះថា មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀល ដោយហេតុ ២ ប្រការនេះ គេសរសើរដោយហេតុ ១ ប្រការនេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត ចែក

រលែក ធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀលដោយហេតុ ១ ប្រការ គេសរសើរដោយ ហេតុ ២ ប្រការ គឺគេតិះដៀលដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេសរសើរ ដោយហេតុទី ១ នេះថា ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត គេសរសើរដោយហេតុទី ២ នេះថា ចេះចែករលែក ធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀលដោយហេតុ ១ ប្រការនេះ គេសរសើរដោយហេតុទាំង ២ ប្រការនេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគៈទាំង-ឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន បានមកហើយ មិនធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត មិនចេះចែករលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរ ដោយហេតុ ១ ប្រការ គេតិះដៀលដោយហេតុ ៣ ប្រការ គឺគេសរសើរដោយហេតុ ១ ប្រការនេះថា ស្វះស្វែង



រកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ២ នេះថា មិនធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត គេតិះដៀលដោយហេតុទី ៣ នេះថា មិនចេះចែករលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ១ ប្រការនេះ គេតិះដៀលដោយហេតុទាំង ៣ ប្រការ នេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគៈទាំង-ឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏ មានមិនកំហែងសង្កត់សង្កិនគេក៏មាន បានមកហើយ ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត តែទាស់មិនចេះចែករលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គេសរសើរ ដោយហេតុ ២ ប្រការ គេតិះដៀល ដោយហេតុ ២ ប្រការ គឺគេសរសើរដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេ

តិះដៀលដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ២ នេះថា ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត គួរគេតិះដៀលដោយហេតុទី ២ នេះថា មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គេសរសើរដោយហេតុទាំង ២ ប្រការនេះ គេតិះដៀលដោយ ហេតុទាំង ២ ប្រការនេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន បានមកហើយ ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត ចែករលែក ធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ៣ ប្រការ គេតិះដៀលដោយហេតុ ១ ប្រការ គឺគេសរសើរដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុ ១ ប្រការនេះថា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺ





កំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ២ នេះថា ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត គេសរសើរដោយហេតុទី ៣ នេះថា ចែករលែក ធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គេសរសើរដោយហេតុទាំង ៣ ប្រការនេះ គេតិះដៀលដោយហេតុ ១ ប្រការនេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ មិនធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ១ ប្រការ គេតិះដៀល ដោយហេតុ ២ ប្រការ គឺគេសរសើរដោយហេតុ ១ ប្រការនេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេតិះដៀលដោយហេតុទី ១ នេះថា មិនធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត គេតិះដៀលដោយហេតុទី ២ នេះថា មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ១ ប្រការនេះ គេតិះដៀលដោយហេតុទាំង ២ ប្រការនេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នក

បរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត តែមិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ២ ប្រការ គេតិះដៀលដោយហេតុ ១ ប្រការ គឺគេសរសើរដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ២ នេះថា ចេះធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត គេតិះដៀលដោយហេតុ ១ ប្រការនេះថា មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរ ដោយហេតុ ២ ប្រការនេះ គេតិះដៀលដោយហេតុ ១ ប្រការនេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត ចែករលែក ធ្វើបុណ្យទាំងឡាយ តែនៅងប់ ជ្រប់ ឈ្លក់ចិត្តនឹងភោគៈទាំងនោះ មិន



ឃើញទោស មិនមានបញ្ញាជាគ្រឿងរើខ្លួន ហើយចេះតែបរិភោគ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ៣ ប្រការ គេតិះដៀលដោយហេតុ ១ ប្រការ គឺគេសរសើរដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ២ នេះថា ចេះធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត គេសរសើរដោយហេតុទី ៣ នេះថា ចេះចែករលែក ធ្វើបុណ្យទាំងឡាយ គេតិះដៀលដោយហេតុ ១ ប្រការនេះថា ងប់ ជ្រប់ ឈ្លក់ចិត្តនឹងភោគៈទាំងនោះ មិនឃើញទោស មិនមានបញ្ញាជាគ្រឿងរើខ្លួន ហើយចេះតែបរិភោគ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរ ដោយហេតុ ៣ ប្រការនេះ គេតិះដៀលដោយ ហេតុ ១ ប្រការ នេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត ចែករលែក ធ្វើបុណ្យទាំងឡាយ ថែមទាំងមិនងប់មិនជ្រប់ មិនឈ្លក់ចិត្តនឹងភោគៈទាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយចេះបរិភោគ ម្នាលគហបតី អ្នកបរិភោគកាមនេះ

គួរគេសរសើរដោយហេតុ ៤ ប្រការ គឺគេសរសើរដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ២ នេះថា ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត គេសរសើរដោយហេតុទី ៣ នេះថា ចែករលែក ធ្វើបុណ្យទាំងឡាយ គេសរសើរដោយហេតុទី ៤ នេះថា មិនងប់ មិនជ្រប់ មិនឈ្លក់ចិត្តនឹងភោគៈទាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គេសរសើរដោយហេតុទាំង ៤ ប្រការនេះ។ ម្នាលគហបតី អ្នកបរិភោគកាមទាំង ១០ ពួកនេះ មានក្នុងលោក។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំង ១០ ពួកនេះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត ចែករលែក ធ្វើបុណ្យទាំងឡាយ ថែមទាំងមិនងប់ មិនជ្រប់ មិនឈ្លក់ចិត្តនឹងភោគៈទាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ បណ្តាអ្នកបរិភោគកាមទាំង ១០ ពួកនេះ អ្នកបរិភោគកាមនេះ ឈ្មោះថាជាកំពូលផង ប្រសើរផង ចម្បងផង ខ្ពង់ខ្ពស់ផង ថ្លៃថ្លាផង ។





ម្នាលគហបតី ដូចជាទឹកដោះស្រស់ កើតពីមេគោ ទឹកដោះជូរក្លាយពីទឹកដោះស្រស់ ទឹកដោះខាប់ក្លាយពីទឹកដោះជូរ ទឹកដោះរាវក្លាយពីទឹកដោះខាប់ ទឹកដោះថ្លាក្លាយពីទឹកដោះរាវ ទឹកដោះថ្លាប្រាកដជាប្រសើរជាងទឹកដោះទាំងនោះ យ៉ាងណាមិញ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំង ១០ ពួកនេះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត ចែករលែក ធ្វើបុណ្យទាំងឡាយ ថែមទាំងមិនងប់ មិនជ្រប់ មិនឈ្លក់ចិត្តនឹងភោគៈទាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ បណ្តាអ្នកបរិភោគកាមទាំង ១០ ពួកនេះ អ្នកបរិភោគកាមនេះ ឈ្មោះថាជាកំពូលផង ប្រសើរផង ចម្បងផង ខ្ពង់ខ្ពស់ផង ថ្លៃថ្លាផង យ៉ាងនោះឯង ។

ក្នុងបិដកលេខ ២៨ ទំព័រ ៧២ ក្នុងសេចក្តីខាងដើមនៃ **មហាកម្មវិភង្គសូត្រ** បញ្ជាក់អំពីការស្តាប់សំនួរឱ្យច្បាស់ ហើយត្រូវឆ្លើយដោយការចែកធម៌ មានដូចតទៅ :

## មហាកម្មវិភង្គសូត្រ

ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ

ទង់គង់នៅក្នុងវត្តវេឡុវ៉ន ជាកលន្ទកនិវាបស្ថានជិតក្រុងរាជគ្រឹះ។ សម័យនោះឯង ព្រះសមិទ្ធិមានអាយុ គង់នៅក្នុងកុដិដែលតាំងនៅក្នុងព្រៃ ។ គ្រានោះឯង បរិព្វាជក ឈ្មោះបោតលិបុត្ត ដើរចង្រ្កមត្រាច់ទៅមកដើម្បីសម្រួលស្មង ហើយចូលទៅរកព្រះសមិទ្ធិមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់នឹងព្រះសមិទ្ធិមានអាយុ លុះបញ្ចប់ពាក្យរាក់ទាក់និងពាក្យគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

លុះបោតលិបុត្តបរិព្វាជក អង្គុយក្នុងទីសមគួរហើយ ទើបពោលពាក្យនេះនឹងព្រះសមិទ្ធិមានអាយុថា ម្នាលអាវុសោសមិទ្ធិ ពាក្យនេះខ្ញុំបានស្តាប់មកក្នុងទីចំពោះព្រះភក្ត្រ បានទទួលមកក្នុងទីចំពោះព្រះភក្ត្រ នៃព្រះសមណគោតមថា កាយកម្មជាកម្មឥតអំពើ វចីកម្មជាកម្មឥតអំពើ មនោកម្មទើបជាកម្មពិត មួយទៀត បុគ្គលចូលកាន់សមាបត្តិណា ហើយមិនទទួលអារម្មណ៍អ្វីមួយ សមាបត្តិនោះក៏មានដែរ ។ ព្រះសមិទ្ធិពោលតបថា ម្នាលអាវុសោបោតលិបុត្ត អ្នកកុំពោលយ៉ាងនេះឡើយ អ្នកកុំពោលបង្កាច់ព្រះមានព្រះភាគ ព្រោះថា ការពោលបង្កាច់ព្រះមានព្រះភាគមិនល្អទេ ដ្បិតថា ព្រះមានព្រះភាគ មិនបានត្រាស់ថា កាយកម្មជាកម្មឥតអំពើ វចីកម្មជាកម្មឥតអំពើ មនោកម្មទើបជាកម្មពិត យ៉ាង



នេះទេ ម្នាលអាវុសោ តែចំណែកខាង បុគ្គលចូលកាន់សមាបត្តិណា មិនទទួលអារម្មណ៍អ្វីមួយ សមាបត្តិនោះ ក៏មានមែន ។ ម្នាលអាវុសោ សមិទ្ធិ លោកបួសបានយូរប៉ុន្មានវស្សាហើយ ។ ម្នាលអាវុសោ មិនយូរប៉ុន្មានទេ ទើបតែនឹងបាន ៣ វស្សា ។ ឥឡូវនេះយើងទាំងឡាយ ចាំនិយាយថ្វីចំពោះពួកភិក្ខុជាថេរៈក្នុងរឿងនេះ ព្រោះសូម្បីភិក្ខុថ្មី ក៏គង់សំគាល់នូវសាស្តាដែលខ្លួនគួរការពារយ៉ាងនេះបានដែរ ម្នាលអាវុសោសមិទ្ធិ បុគ្គលធ្វើកម្មប្រកបដោយចេតនា ដោយកាយវាចាចិត្តហើយ តើរងវេទនាដូចម្តេច ។ ម្នាលអាវុសោបោតលិបុត្ត បុគ្គលធ្វើកម្មប្រកបដោយចេតនា ដោយកាយវាចាចិត្តហើយ រមែងរងទុក្ខវេទនា ។ គ្រានោះ បោតលិបុត្តបរិព្វាជក មិនត្រេកអរ មិនហាមឃាត់ភាសិតរបស់ព្រះសមិទ្ធិមានអាយុ លុះមិនត្រេកអរ មិនហាមឃាត់ហើយ ក៏ក្រោកអំពីអាសនៈចៀសចេញទៅ ។

គ្រានោះឯង ព្រះសមិទ្ធិមានអាយុ កាលបោតលិបុត្តបរិព្វាជកចៀសចេញទៅ មិនយូរប៉ុន្មាន ក៏ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់នឹងព្រះអានន្ទមានអាយុ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់ និងពាក្យគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះសមិទ្ធិមានអាយុ អង្គុយ

ក្នុងទីសមគួរហើយ ទើបផ្ទៀងពាក្យចរចាទាំងអស់ ដែលខ្លួននិយាយនឹងបោតលិបុត្តបរិព្វាជកទាំងប៉ុន្មាន ដល់ព្រះអានន្ទមានអាយុ ។ កាលព្រះសមិទ្ធិមានអាយុ ពោលយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ពោលនឹងព្រះសមិទ្ធិមានអាយុ យ៉ាងនេះថា ម្នាលអាវុសោសមិទ្ធិ ពាក្យនេះ ជាពាក្យមានមូលហេតុហើយ ម្នាលអាវុសោសមិទ្ធិ គួរយើងនាំគ្នាមក ដើម្បីគាល់ព្រះមាន-ព្រះភាគ លុះចូលទៅដល់ហើយ គួរក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ព្រះមានព្រះភាគ នឹងព្យាករ ដល់យើងយ៉ាងណា យើងគប្បីចងចាំសេចក្ដីនោះ យ៉ាងនោះ ។ ព្រះសមិទ្ធិមានអាយុទទួលពាក្យព្រះអានន្ទមានអាយុថា ករុណា អាវុសោ ។ គ្រានោះ ព្រះសមិទ្ធិមានអាយុ និងព្រះអានន្ទមានអាយុ ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលពាក្យចរចាទាំងប៉ុន្មានរបស់ព្រះសមិទ្ធិមានអាយុ ជាមួយនឹងបោតលិបុត្ត-បរិព្វាជកទាំងអស់ ចំពោះព្រះមានព្រះភាគ ។

លុះព្រះអានន្ទក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមាន-ព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុ យ៉ាងនេះថា ម្នាល



អានន្ទ តថាគតមិនទាំងធ្លាប់ឃើញ នូវបោតលិបុត្តបរិព្វាជកសោះ តើនឹងមានការចរចាជាមួយបែបនេះ មកពីណា ម្នាលអានន្ទ ប្រស្នាដែលគួរចែក គួរដោះស្រាយ ដល់បោតលិបុត្តបរិព្វាជក សមិទ្ធិ ជាមោឃបុរសនេះឯង ដោះស្រាយហើយតែមួយចំណែក ។ កាលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះឧទាយិមានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្រែងសមិទ្ធិមានអាយុ ពោលដូច្នោះ ព្រោះអាងហេតុនេះថា វេទនាណានីមួយ វេទនានោះ សុទ្ធតែជាទុក្ខដូច្នេះទេដឹង ។

កាលព្រះឧទាយិ ក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ ចូរអ្នកមើលនូវសេចក្ដីល្ងង់របស់ឧទាយិ ជាមោឃបុរសនេះ ម្នាលអានន្ទ តថាគតបានដឹងច្បាស់ហើយថា ឥឡូវនេះ ឧទាយិនេះជាមោឃបុរស កាលងើបឡើង តែងងើបឡើងដោយឧបាយមិនមែនជាប្រាជ្ញា ម្នាលអានន្ទ បោតលិបុត្តបរិព្វាជកបានសួរវេទនា ៣ ខាងដើម ម្នាលអានន្ទ ប្រសិនបើសមិទ្ធិជាមោឃបុរសនេះ ត្រូវបោតលិបុត្តបរិព្វាជកសួរយ៉ាងនេះ គប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោបោតលិបុត្ត បុគ្គល ធ្វើអំពើប្រកបដោយចេតនា

ដោយ កាយ វាចាចិត្ត ជាហេតុនៃសុខវេទនា បុគ្គលនោះក៏រង សុខវេទនា ម្នាលអាវុសោបោតលិបុត្ត បុគ្គល ធ្វើកម្មប្រកបដោយ ចេតនា ដោយកាយវាចាចិត្ត ជាហេតុនៃទុក្ខវេទនា បុគ្គលនោះ ក៏រងទុក្ខវេទនា ម្នាលអាវុសោបោតលិបុត្ត បុគ្គល ធ្វើអំពើ ប្រកបដោយចេតនា ដោយកាយវាចាចិត្ត ជាហេតុនៃអទុក្ខមសុខ-វេទនា បុគ្គលនោះ ក៏រងអទុក្ខមសុខវេទនា ម្នាលអានន្ទ សមិទ្ធិ ជាមោឃបុរស កាលព្យាករយ៉ាងនេះ ឈ្មោះថា គួរព្យាករដោយ ប្រពៃដល់បោតលិបុត្តបរិព្វាជក ។

ជាបន្តនៃព្រះសូត្រ ព្រះអង្គទ្រង់ត្រាស់សម្តែងចែកនូវមហា កម្ម ក្នុងបុគ្គល ៤ ពួក ។

បិដកលេខ ៤៥ ទំព័រ ១៨៣ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ សម្តែងចែកភិក្ខុនៅក្នុងព្រៃជា ៥ ពួក ជាការសម្តែងឱ្យមនុស្ស យើងចេះគិតពិចារណា កុំវាយតម្លៃមនុស្សដោយត្រឹមតែឃើញ សំបកក្រៅ មានដូចតទៅ :

ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នកនៅក្នុងព្រៃ (ប្រព្រឹត្ត អរញ្ញិកង្គ ) នេះមាន ៥ ពួក ។ ភិក្ខុអ្នកនៅក្នុងព្រៃ ៥ ពួក តើ ដូចម្តេច ។ គឺភិក្ខុអ្នកនៅក្នុងព្រៃ ព្រោះមិនដឹង ព្រោះល្ងង់ខ្លៅ ១ នៅក្នុងព្រៃ ព្រោះប្រាថ្នាលាមក លុះក្នុងសេចក្តីប្រាថ្នា ១ នៅក្នុង



ព្រៃ ព្រោះឆ្កួតវាយមាយចិត្ត ១ នៅក្នុងព្រៃ ព្រោះគិតថា ការនៅ ក្នុងព្រៃ ព្រះពុទ្ធទាំងឡាយនិងពួកពុទ្ធសាវ័កសរសើរហើយ ១ នៅ ក្នុងព្រៃ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យសេចក្តីជុសខាត់ (កិលេស ) អាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីត្រូវការដើម្បីនឹងប្រតិបត្តិល្អ ១ ។ ម្នាលភិក្ខុ ទាំងឡាយ ភិក្ខុអ្នកនៅក្នុងព្រៃមាន ៥ ពួកនេះឯង ។ ម្នាលភិក្ខុ ទាំងឡាយ បណ្តាភិក្ខុអ្នកនៅក្នុងព្រៃទាំង ៥ ពួកនេះ ភិក្ខុណាអ្នក នៅក្នុងព្រៃ ដែលជាអ្នកនៅក្នុងព្រៃ ព្រោះអាស្រ័យសេចក្តីប្រាថ្នា តិច អាស្រ័យសេចក្តីសន្តោស អាស្រ័យសេចក្តីជុសខាត់ (កិលេស) អាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីត្រូវការដើម្បីនឹង ប្រតិបត្តិល្អ បណ្តាភិក្ខុអ្នកនៅក្នុងព្រៃទាំង ៥ ពួកនេះ ភិក្ខុអ្នកនៅ ក្នុងព្រៃបែបនេះ ឈ្មោះថាខ្ពង់ខ្ពស់ផង ប្រសើរផង ជាចម្បងផង ឧត្តមផង ថ្លៃថ្លាផង ។

បិដកលេខ ៤៦ ទំព័រ ២២៣ ព្រះអង្គទ្រង់ត្រាស់សម្តែង ចែកភិក្ខុ ៦ ពួកគឺ នៅក្នុងព្រៃ ១ ពួក នៅក្នុងសេនាសនៈជិតស្រុក ១ ពួក ប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ១ ពួក ប្រព្រឹត្តទទួលនិមន្ត ១ ពួក ប្រព្រឹត្តបំសុកុលិកធុតង្គ ១ ពួក ប្រព្រឹត្តទ្រទ្រង់គហបតិចីវរ ១ ពួក មានដូចតទៅ :

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទដែលធ្វើអំពីឥដ្ឋ ក្នុងនាទិកគ្រាម ។ គ្រានោះឯង គហបតីឈ្មោះទារុកម្មិកៈ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះទារុកម្មិកគហបតីអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរដូច្នេះថា ម្នាលគហបតី ចុះទានក្នុងត្រកូលអ្នកតែងឱ្យដែរឬ ។ ទារុកម្មិកគហបតី ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទានក្នុងត្រកូល ខ្ញុំព្រះអង្គតែងឱ្យ បពិត្រព្រះអង្គដ៏ចម្រើន តែថា ទាននោះ ខ្ញុំព្រះអង្គឱ្យចំពោះតែពួកភិក្ខុ ដែលជាអ្នកប្រព្រឹត្តអរញ្ញិកធុតង្គ ប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ប្រព្រឹត្តបំសុកុលិកធុតង្គ ជាព្រះអរហន្ត ឬភិក្ខុដែលដល់នូវអរហត្តមគ្គប៉ុណ្ណោះ ។ ម្នាលគហបតី ខ្លួនអ្នកជាគ្រហស្ថ ជាអ្នកបរិភោគកាម នៅគ្រប់គ្រងដំណេកដ៏ចង្អៀតដោយកូនប្រពន្ធ ប្រើប្រាស់នូវខ្លឹមចន្ទន៍ដ៏ល្អិត ទ្រទ្រង់នូវកម្រងផ្កា គ្រឿងក្រអូបនិងគ្រឿងលាប ត្រេកអរនូវមាសនិងប្រាក់ កម្រនឹងដឹងបានណាស់ថា ភិក្ខុទាំងនេះ ជាព្រះអរហន្ត ឬភិក្ខុទាំងនេះ បានដល់នូវអរហត្តមគ្គដូច្នេះ ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តអរញ្ញិកធុតង្គ ប៉ុន្តែមានចិត្តរាយមាយ ជាអ្នកលើកកម្ពស់ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង





មានសំដីផ្តេសផ្តាស ជាអ្នកភ្លេចស្មារតី មិនមានសម្បជញ្ញៈ មិនមានចិត្តតាំងមាំ មានចិត្តវិលវល់ មិនសង្រួមឥន្ទ្រិយ កាលបើយ៉ាងនេះ ភិក្ខុនោះគួរគេតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តអរញ្ញិកធុតង្គ ប៉ុន្តែជាអ្នកមានចិត្តមិនរាយមាយ ជាអ្នកមិនលើកកម្ពស់ មិនមានចិត្តឃ្លេងឃ្លោង មិនមានមាត់រឹង មិនមានវាចាផ្តេសផ្តាស មានស្មារតីខ្ជាប់ខ្ជួន មានសម្បជញ្ញៈ មានចិត្តតម្កល់មាំ មានចិត្តមូលតែ ១ ជាអ្នកសង្រួមឥន្ទ្រិយ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកនៅក្នុងសេនាសនៈជិតស្រុក ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកនៅក្នុងសេនាសនៈ ជិតស្រុក ប៉ុន្តែជាអ្នកមានចិត្តមិនរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើរដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ប៉ុន្តែជាអ្នកមានចិត្តមិនរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរ

សរសើរដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកទទួលនិមន្តគេ ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកទទួលនិមន្តគេ ប៉ុន្តែជាអ្នកមានចិត្តមិនរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើរដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តបំសុកុលិកធុតង្គ ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តបំសុកុលិកធុតង្គ ប៉ុន្តែជាអ្នកមានចិត្តមិនរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើរដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកទ្រទ្រង់នូវគហបតិចីវរ ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ជាអ្នកលើកកម្ពស់ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានសំដីផ្តេសផ្តាស ជាអ្នកភ្លេចភ្លាំងស្មារតី មិនមានសម្បជញ្ញៈ មានចិត្តមិនខ្ជាប់ខ្ជួន មានចិត្តវិលវល់ មិនសង្រួមឥន្ទ្រិយ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកទ្រទ្រង់នូវគហបតិចីវរ ប៉ុន្តែជាអ្នកមិនមានចិត្តរាយមាយ មិនលើកកម្ពស់ មិនមានចិត្តឃ្លេងឃ្លោង



មិនមានមាត់រឹង មិនមានសំដីផ្តេសផ្តាស មានស្មារតីខ្ជាប់ខ្ជួន មានសម្បជញ្ញៈ មានចិត្តតម្កល់មាំ មានចិត្តមូលតែមួយ ជាអ្នកសង្រួមឥន្ទ្រិយ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើរដោយហេតុនោះបាន ។ ម្នាលគហបតី អញ្ជើញអ្នកឱ្យទានចំពោះសង្ឃវិញ កាលបើអ្នកឱ្យទានចំពោះសង្ឃហើយ ចិត្តរមែងជ្រះថ្លា លុះអ្នកមានចិត្តជ្រះថ្លាហើយ គ្រាបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ទារុកម្មិកគហបតីក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមអំពីថ្ងៃនេះទៅ ខ្ញុំព្រះអង្គហ្នឹងឯង នឹងឱ្យទានចំពោះសង្ឃវិញ ។

បិដកលេខ ៣២ ទំព័រ ២៩៥ ព្រះអង្គទ្រង់ចែកអំពីការនៅម្នាក់ឯង មានដូចតទៅ :

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័នជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ ក៏ក្នុងសម័យនោះឯង មានភិក្ខុមួយរូបបាននាមជាថេរៈ គង់នៅតែម្នាក់ឯងផង ពោលសរសើរចំពោះកិរិយានៅតែម្នាក់ឯងផង ។ ភិក្ខុនោះចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតតែម្នាក់ឯង ត្រឡប់មកវិញតែម្នាក់ឯង អង្គុយក្នុងទីស្ងាត់តែម្នាក់ឯង អធិដ្ឋានចង្ក្រមតែម្នាក់ឯង ។ គ្រានោះឯងភិក្ខុច្រើនរូបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយ

បង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ភិក្ខុមួយរូប បាននាមជាថេរៈ នៅតែម្នាក់ឯងផង ពោលសរសើរចំពោះកិរិយានៅតែម្នាក់ឯងផង ។

គ្រានោះឯង ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុមួយរូបទៀតមកបង្គាប់ថា ម្នាលភិក្ខុ អ្នកចូរមក អ្នកចូរទៅហៅភិក្ខុជាថេរៈ តាមពាក្យតថាគតថា ម្នាលអាវុសោ ព្រះសាស្តាត្រាស់ហៅអ្នកជាថេរៈ ។ ភិក្ខុនោះទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយចូលទៅរកព្រះថេរៈមានអាយុ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងព្រះថេរៈមានអាយុថា ម្នាលអាវុសោ ព្រះសាស្តាត្រាស់ហៅអ្នកជាថេរៈ ។ ព្រះថេរៈមានអាយុ ទទួលពាក្យភិក្ខុនោះថា អើ អាវុសោ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។

លុះព្រះថេរៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគទ្រង់ត្រាស់សួរដូច្នេះថា ម្នាលថេរៈ ឮថា អ្នកនៅតែម្នាក់ឯងផង ពោលសរសើរចំពោះកិរិយានៅតែម្នាក់ឯងផង



ពិតឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលថេរៈ ចុះអ្នកនៅតែម្នាក់ឯងផង ពោលសរសើរចំពោះកិរិយានៅតែម្នាក់ឯងផង ដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនោះ ខ្ញុំព្រះអង្គតែម្នាក់ឯង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ត្រឡប់មកវិញតែម្នាក់ឯង អង្គុយក្នុងទីស្ងាត់តែម្នាក់ឯង អធិដ្ឋានចង្ក្រមតែម្នាក់ឯង បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនេះឯង ខ្ញុំព្រះអង្គ ឈ្មោះថានៅតែម្នាក់ឯងផង ពោលសរសើរចំពោះកិរិយានៅតែម្នាក់ឯងផង ។

ម្នាលថេរៈ កិរិយានៅតែម្នាក់ឯងនុ៎ះ មានហើយ តថាគតមិនពោលថាមិនមានទេ ម្នាលថេរៈ ប៉ុន្តែកិរិយានៅតែម្នាក់ឯងរបស់អ្នកនោះ ឈ្មោះថាបរិបូណ៌ដោយពិស្តារក្រៃពេក ដោយប្រការណា អ្នកចូរស្តាប់នូវប្រការនោះ ចូរធ្វើទុកក្នុងចិត្តឱ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ព្រះករុណា ព្រះអង្គ ។

ម្នាលថេរៈ ចុះកិរិយានៅតែម្នាក់ឯង ឈ្មោះថាបរិបូណ៌ដោយពិស្តារក្រៃពេក ដោយប្រការដូចម្តេច ម្នាលថេរៈ ក្នុងសាសនានេះ របស់ណាជាអតីត របស់នោះគេលះបង់ហើយ របស់ណាជាអនាគត របស់នោះក៏គេលះបង់ហើយ ឆន្ទរាគៈក្នុងការបានចំពោះនូវអត្តភាពជាបច្ចុប្បន្ន គេកម្ចាត់បង់ចេញល្អហើយ ម្នាលថេរៈ យ៉ាងនេះឯង ឈ្មោះថាកិរិយានៅម្នាក់ឯង បរិបូណ៌ដោយ

ពិស្តារក្រៃពេក ។

ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះ លុះព្រះសុគតជាសាស្តា ត្រាស់ព្រះពុទ្ធដីកានេះហើយ ទើបទ្រង់ត្រាស់ព្រះពុទ្ធដីកាតទៅទៀតថា :

**សព្វាភិភុំ សព្វវិទុំ សុមេធំ**

**សព្វេសុ ធម្មេសុ អនូបលិត្តំ**

**សព្វំ ជហំ តណ្ហក្ខយេ វិមុត្តំ**

**តមហំ នរំ ឯកវិហារីតិ ព្រូមីតិ** ។

ជនណា អ្នកគ្របសង្កត់ធម៌ទាំងអស់ ដឹងនូវធម៌ទាំងអស់ មានប្រាជ្ញាល្អ មិនជាប់ចំពាក់ក្នុងពួកធម៌ទាំងអស់ លះបង់នូវធម៌ទាំងអស់ មានចិត្តចុះស៊ប់ក្នុងព្រះនិព្វានជាទីអស់ទៅនៃតណ្ហា ទើបតថាគតហៅជននោះថា អ្នកនៅតែម្នាក់ឯង ។

**អដ្ឋកថា**

បទថា **សព្វាភិភុំ** ដោយសេចក្ដីថា គ្របសង្កត់នូវខន្ធ អាយតនៈ ធាតុ និងភព ៣ ទាំងអស់ ។ បទថា **សព្វវិទុំ** បានដល់ការដឹងច្បាស់នូវបញ្ចក្ខន្ធជាដើម ដែលមានប្រការដូចដែលបានពោលហើយទាំងអស់នោះ ។ បទថា **សព្វេសុ ធម្មេសុ** ដោយសេចក្ដីថា គ្រឿងលាបគឺតណ្ហានិងទិដ្ឋិ មិនបានចូលទៅលាប





ហើយក្នុងធម៌ទាំងពួងនោះ ។ បទថា **សព្វំ ជហំ** ដោយសេចក្ដីថា លះបញ្ចក្ខន្ធនោះឯង ។ បទថា **តណ្ហក្ខយេ វិមុត្តំ** បានដល់ ការបង្អោនទៅក្នុងព្រះនិព្វាន ដែលជាទីអស់ទៅនៃតណ្ហា ពោលគឺវិមុត្តិ ដែលមានព្រះនិព្វានជាអារម្មណ៍ ។

ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ត្រាស់ចែក បុគ្គល ចែកធម៌ ដើម្បីជាប្រយោជន៍ដល់ការជាក់ច្បាស់តាមសេចក្ដីពិត។ ដែលអាចចែកបុគ្គលទៅបាន ក៏ព្រោះអាស្រ័យមានសភាវធម៌ ដូច្នេះសភាវធម៌មិនមែនជាសត្វបុគ្គលឡើយ ហើយសត្វបុគ្គលក៏មិនមែនមាននៅក្រៅអំពីសភាវធម៌ទៀតដែរ នេះគឺជាបញ្ញត្តិអាស្រ័យបរមត្ថ ។

នៅក្នុងព្រះត្រៃបិដក យើងឃើញមានការចែកព្រះធម៌ជាពួក ជាក្រុម នេះជាលក្ខណៈមួយដ៏សំខាន់ក្នុងព្រះពុទ្ធសាសនា ។ ព្រះអង្គចែកជីវិតនេះជា ៥ ចំណែក មានចំណែករូបជាដើម សូម្បីរូបក៏ព្រះអង្គត្រាស់សម្ដែងចែកជាមហាភូតរូប ៤ និងឧបាទាយរូបជាច្រើនទៀត ដែលបញ្ជាក់ថា ជីវិតនេះជាការប្រជុំដោយបរមត្ថ-ធម៌ មិនមែនជាសត្វ បុគ្គលតួខ្លួនឡើយ ។

ក្នុងបិដកលេខ ២៣ ទំព័រ ១៤៩ អភយរាជកុមារ បានទូលសួរនូវសំណួរ ១ ចំពោះព្រះអង្គ គឺសួរថា បពិត្រព្រះអង្គដ៏

ចម្រើន វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ ព្រះតថាគតគប្បីពោលវាចានោះដែរឬទេ ?

ក្នុងសំណួរ ១ នេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់វិសជ្ជនាចែកជា ដល់ទៅ ៦ ចំណែក សឹងមានសេចក្តីទាំងស្រុងដូចតទៅ :

## អភយរាជកុមារសូត្រ

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះ អភយរាជកុមារ ចូលទៅរកនិគន្ថនាដបុត្ត លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំនិគន្ថនាដបុត្ត រួចអង្គុយនៅក្នុងទីសមគួរ ។

និគន្ថនាដបុត្ត បាននិយាយនឹងអភយរាជកុមារ ដែលអង្គុយនៅក្នុងទីសមគួរយ៉ាងនេះថា ម្នាលរាជកុមារ ទ្រង់ចូរមក ចូរទ្រង់លើកឡើងនូវវាទៈ គឺលើកវាទៈ ចំពោះព្រះសមណគោតម ទ្រង់នឹងមានកិត្តិសព្ទដ៏ពីរោះល្បីខ្ចរខ្ចាយទៅយ៉ាងនេះថា អភយ-រាជកុមារហ៊ានលើកវាទៈព្រះសមណគោតម ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ។ អភយរាជកុមារសួរថា បពិត្រលោកដ៏ចម្រើន ខ្ញុំនឹងលើកទោសព្រះសមណគោតម ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ដោយ





ប្រការដូចម្តេច ។ និគន្ថនាដបុត្តឆ្លើយថា ម្នាលរាជកុមារ ទ្រង់ចូរមក ចូរទ្រង់ទៅរកព្រះសមណគោតម លុះចូលទៅដល់ហើយ ចូរពោលយ៉ាងនេះនឹងព្រះសមណគោតមថា បពិត្រព្រះអង្គដ៏ចម្រើន វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ ព្រះតថាគតគប្បីពោលវាចានោះដែរឬទេ ប្រសិនបើទ្រង់សួរយ៉ាងនេះហើយ ព្រះសមណគោតម នឹងដោះស្រាយយ៉ាងនេះថា ម្នាលរាជកុមារ វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ តថាគត គប្បីពោលវាចានោះដែរ ទ្រង់គប្បីពោលនឹងព្រះសមណគោតម យ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ អំពើរបស់ព្រះអង្គ ផ្សេងអ្វីអំពីបុថុជ្ជន ព្រោះថា វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ បុថុជ្ជនក៏ពោលនូវវាចានោះដែរ ប្រសិនបើទ្រង់សួរយ៉ាងនេះហើយ ព្រះសមណគោតម គង់នឹងដោះស្រាយយ៉ាងនេះថា ម្នាលរាជកុមារ វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ តថាគតមិនពោលនូវវាចានោះទេ ទ្រង់គប្បីពោលនឹងសមណគោតម យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះហេតុអ្វី បានជាព្រះអង្គទ្រង់ព្យាករទេវទត្តថា ទេវទត្តកើតក្នុងអបាយ ទេវទត្តកើតក្នុងនរក

ទេវទត្តឋិតនៅអស់ ១ កប្ប ទេវទត្ត (បើទុកជាពាន់នៃព្រះពុទ្ធ ) ក៏មិនអាចជួយកែបាន ហើយទេវទត្តក៏ខឹងអាក់អន់ចិត្ត ដោយវាចារបស់ព្រះអង្គនោះ ។ ម្នាលរាជកុមារ កាលបើទ្រង់សួរបញ្ហាប្រកបដោយទីបំផុតទាំងពីរខាងនេះហើយ ព្រះសមណគោតម ក៏មិនអាចនឹងលេបចូល មិនអាចខ្ជាក់ចេញបានឡើយ ដូចក្រចាប់ដែកស្ទាក់នៅក្នុងបំពង់កនៃបុរស បុរសនោះមិនអាចលេបចូល មិនអាចខ្ជាក់ចេញបាន យ៉ាងណា ម្នាលរាជកុមារ កាលបើទ្រង់សួរបញ្ហាប្រកបដោយទីបំផុតទាំងពីរខាងនេះហើយ ព្រះសមណ-គោតម ក៏មិនអាចលេបចូល មិនអាចខ្ជាក់ចេញបានយ៉ាងនោះឯង ។ អភយរាជកុមារ ទទួលស្គាល់ពាក្យនិគន្ថនាដបុត្តដោយពាក្យថា ករុណាលោកម្ចាស់ ហើយក្រោកចាកទីអង្គុយ ក្រាបថ្វាយបង្គំនិគន្ថនាដបុត្ត ធ្វើប្រទក្សិណហើយ ចូលសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគរួចអង្គុយក្នុងទីសមគួរ ។ លុះអភយរាជកុមារ អង្គុយក្នុងទីសមគួរហើយ ក៏ក្រឡេកមើលព្រះអាទិត្យ មានសេចក្តីត្រិះរិះ យ៉ាងនេះថាថ្ងៃនេះជាកាលមិនសមគួរ ដើម្បីលើកវាទៈចំពោះព្រះមានព្រះភាគឡើយ អាត្មាអញនឹងលើកវាទៈចំពោះព្រះមានព្រះភាគក្នុងលំនៅរបស់ខ្លួន ក្នុងថ្ងៃស្អែកវិញ ។ ឯអភយរាជកុមារ ក៏ក្រាបទូលព្រះ



មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ មានភិក្ខុជាគំរប់ ៤ នឹងព្រះអង្គទៅទទួលភត្តរបស់ខ្ញុំក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ លំដាប់នោះ អភយរាជកុមារ ដឹងច្បាស់នូវការទទួលនិមន្តន៍របស់ព្រះមានព្រះភាគហើយ ក្រោកចាកទីអង្គុយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។ គ្រាកាលរាត្រីកន្លងទៅហើយ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ទ្រង់យាងសំដៅទៅកាន់លំនៅនៃអភយរាជកុមារលុះទ្រង់ពុទ្ធដំណើរទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លំដាប់នោះ អភយរាជកុមារ បានអង្គាសខាទនីយភោជ-នីយាហារដ៏ឆ្ងាញ់ពិសារដោយដៃខ្លួនឯង ថ្វាយព្រះមានព្រះភាគសោយ ឱ្យឆ្អែតស្កប់ស្កល់ ។ គ្រានោះ អភយរាជកុមារ ដឹងថាព្រះមានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏កាន់យកនូវអាសនៈទាបមួយអង្គុយក្នុងទីសមគួរ ។

លុះអភយរាជកុមារ អង្គុយក្នុងទីសមគួរហើយ បានក្រាប-ទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ ព្រះតថាគត គប្បីពោលវាចានោះដែរឬទេ ។ ព្រះអង្គត្រាស់ថា ម្នាល

រាជកុមារ ការដោះស្រាយក្នុងបញ្ហានេះ មិនតែមួយចំណែកទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បើដោះស្រាយបញ្ហានេះ មិនតែមួយចំណែកនោះហើយ និគ្រន្ថទាំងឡាយ មុខជាវិនាសមិនខាន ។ ម្នាលរាជកុមារ ហេតុដូចម្តេចបានជាពោលយ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន បើការដោះស្រាយក្នុងបញ្ហានេះ មិនតែមួយចំណែកនោះហើយ ពួកនិគ្រន្ថមុខជានឹងវិនាសពុំខាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមកក្នុងទីនេះ ព្រោះខ្ញុំព្រះអង្គ បានចូលទៅរកនិគន្ថនាដបុត្ត លុះចូលទៅដល់ហើយ ថ្វាយបង្គំនិគន្ថនាដបុត្ត ហើយអង្គុយក្នុងទីសមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះខ្ញុំព្រះអង្គអង្គុយក្នុងទីសមគួរហើយ និគន្ថនាដបុត្ត ក៏បាននិយាយថា ម្នាលរាជកុមារ សូមទ្រង់មក សូមទ្រង់លើកវាទៈ ចំពោះព្រះសមណគោតម ទ្រង់នឹងមានកិត្តិសព្ទ ល្បីខ្ចរខ្ចាយទៅយ៉ាងនេះថា អភយរាជកុមារហ៊ានលើកវាទៈ ចំពោះព្រះសមណគោតម ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះបាន កាលនិគន្ថនាដបុត្ត ពោលយ៉ាងនេះហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានពោលពាក្យនេះ នឹងនិគន្ថនាដបុត្តថា បពិត្រលោកដ៏ចម្រើន ខ្ញុំនឹងលើកវាទៈ ចំពោះព្រះសមណគោតម ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ដោយ





ប្រការដូចម្តេចទៅ និគន្ថនាដបុត្តពោលថា ម្នាលរាជកុមារសូមទ្រង់មក សូមទ្រង់ចូលទៅរកព្រះសមណគោតម លុះចូលទៅដល់ហើយ សូមទ្រង់ពោលយ៉ាងនេះនឹងព្រះសមណគោតមថា បពិត្រព្រះអង្គដ៏ចម្រើន វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ ព្រះតថាគតគប្បីពោលវាចានោះដែរឬទេ កាលបើទ្រង់សួរយ៉ាងនេះហើយ ព្រះសមណគោតម នឹងដោះស្រាយយ៉ាងនេះថា ម្នាលរាជកុមារ វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ តថាគតគប្បីពោលវាចានោះដែរ ទ្រង់គប្បីពោលនឹងព្រះសមណគោតម យ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ អំពើរបស់ព្រះអង្គ ផ្សេងអ្វីអំពីបុថុជ្ជនបាន ព្រោះថាវាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ បុថុជ្ជនក៏ពោលនូវវាចានោះដែរ ប្រសិនបើទ្រង់សួរយ៉ាងនេះហើយ ព្រះសមណគោតម មុខជានឹងដោះស្រាយយ៉ាងនេះថា ម្នាលរាជកុមារ វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ តថាគតមិនពោលវាចានោះឡើយ ទ្រង់គប្បីពោលនឹងសមណគោតមយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះហេតុអ្វីបានជាព្រះអង្គទ្រង់ព្យាករទេវទត្តថា ទេវទត្តកើតក្នុងអបាយ ទេវទត្តកើត

ក្នុងនរក ទេវទត្តឋិតនៅអស់ ១ កប្ប ទេវទត្តទុកជាពាន់នៃព្រះពុទ្ធទាំងឡាយ ក៏ជួយកែមិនបាន ដូច្នេះ ទេវទត្តក៏ខឹងអាក់អន់ចិត្ត ចំពោះព្រះអង្គដោយវាចានោះឯង ម្នាលរាជកុមារ កាលបើអ្នកសួរបញ្ហាប្រកបដោយទីបំផុតទាំងពីរខាងនេះហើយ ព្រះសមណគោតម ក៏មិនអាចលេបចូល មិនអាចខ្ជាក់ចេញបានឡើយ ដូចក្រចាប់ដែកដែលស្លាក់នៅក្នុងបំពង់កនៃបុរស បុរសនោះមិនអាចលេបចូល មិនអាចខ្ជាក់ចេញបាន យ៉ាងណា ម្នាលរាជកុមារ កាលបើទ្រង់សួរបញ្ហា ប្រកបដោយទីបំផុតទាំងពីរខាងនេះហើយ ព្រះសមណគោតម មិនអាចលេបចូល មិនអាចខ្ជាក់ចេញបាន យ៉ាងនោះឯង ។

សម័យនោះឯង មានកូនខ្ចីមិនទាន់ចេះក្រឡាប់ អង្គុយលើភ្លៅអភយរាជកុមារ ។ លំដាប់នោះ ព្រះមានព្រះភាគ មានព្រះតម្រាស់នឹងអភយរាជកុមារថា ម្នាលរាជកុមារ ទ្រង់សំគាល់កូនខ្ចីនោះដូចម្តេច បើកូនខ្ចីនេះ បៀមកំណាត់ឈើក្តី អំបែងក្តី លេបចូលទៅក្នុងមាត់ ព្រោះសេចក្តីធ្វេសប្រហែសរបស់ទ្រង់ ឬព្រោះសេចក្តី ធ្វេសប្រហែសរបស់មេនំ តើទ្រង់ត្រូវធ្វើក្មេងនោះដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គត្រូវល្វូកទាញចេញ បពិត្រព្រះអង្គដ៏ចម្រើន បើខ្ញុំព្រះអង្គមិនអាចល្វូកទាញចេញ ដោយប្រយោគ



ជាដំបូងបានទេ ខ្ញុំព្រះអង្គនឹងចាប់សង្កត់ក្បាលដោយដៃខាងឆ្វេង ខ្វេរម្រាមដៃស្តាំល្វូកខ្វេះទាញវត្ថុនោះ ចេញមកដោយទាំងឈាមផង ការខ្វេះទាញចេញវត្ថុនោះ ព្រោះហេតុដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាខ្ញុំព្រះអង្គមានសេចក្តីអាណិតកុមារ ។ ម្នាលរាជកុមារ យ៉ាងហ្នឹងឯង តថាគត ដឹងនូវវាចាណា ដែលមិនពិតមិនទៀង មិនប្រកបដោយប្រយោជន៍ វាចានោះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃផង តថាគតក៏មិនពោលវាចានោះ តថាគតដឹងនូវវាចាណា ពិត ទៀង តែមិនប្រកបដោយប្រយោជន៍ វាចានោះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ តថាគត ក៏មិនពោលនូវវាចានោះ មួយវិញទៀត តថាគតដឹងនូវវាចាណា ដែលពិត ទៀង ប្រកបដោយប្រយោជន៍ តែថាវាចានោះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ តថាគត ស្គាល់កាលគួរនឹងពោលវាចានោះ ក្នុងព្យាករណ៍នោះដែរ តថាគតដឹងនូវវាចាណា ដែលមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ វាចានោះទោះបីជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ តថាគត ក៏មិនពោលវាចានោះឡើយ តថាគតដឹងនូវវាចាណា ដែលពិត ទៀង តែមិនប្រកបដោយប្រយោជន៍ វាចានោះទោះបី

ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ តថាគត ក៏មិនពោលវាចានោះដែរ មួយវិញទៀត តថាគតដឹងនូវវាចាណា ដែលពិត ទៀង ប្រកបដោយប្រយោជន៍ ទាំងវាចានោះ ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃផង តថាគតស្គាល់កាលគួរនឹងពោលនូវវាចានោះ ក្នុងព្យាករណ៍នោះ ម្នាលរាជកុមារ ព្រោះហេតុអ្វី ព្រោះថា តថាគត មានសេចក្តីអនុគ្រោះ ចំពោះសត្វទាំងឡាយ ។

អភយរាជកុមារ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងឡាយជាខត្តិយបណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតិ-បណ្ឌិតក្តី សមណបណ្ឌិតក្តី បានតាក់តែងបញ្ហា ហើយចូលមកសួរព្រះតថាគត បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ បានត្រិះរិះបញ្ហានុ៎ះទុកក្នុងព្រះហឫទ័យ ស្រេចតាំងពីកាលមុនថា ជនទាំងឡាយណា ចូលមករកតថាគត ហើយសួរយ៉ាងនេះ លុះជនទាំងឡាយនោះសួរតថាគតយ៉ាងនេះហើយ តថាគតនឹងដោះស្រាយយ៉ាងនេះដែរឬ ឬថាបញ្ហាកម្មនុ៎ះស្រាប់តែប្រាកដឡើងដល់ព្រះតថាគត ដោយញាណកើតឡើងទាន់ពេលតែម្តង ។ ព្រះអង្គត្រាស់ថា ម្នាលរាជកុមារ បើដូច្នោះ តថាគតនឹងត្រឡប់សួរទ្រង់ ក្នុងដំណើរនុ៎ះវិញ ទ្រង់គាប់ចិត្តយ៉ាងណា គប្បីដោះស្រាយ



ដំណើរនោះយ៉ាងនោះចុះ ម្នាលរាជកុមារ ទ្រង់សំគាល់ហេតុនោះដូចម្តេច ទ្រង់ជាបុគ្គលឈ្លាសក្នុងអវយវៈតូចធំទាំងឡាយនៃរថដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកឈ្លាសក្នុងអវយវៈតូចធំនៃរថដែរ ។ ម្នាលរាជកុមារ ទ្រង់សំគាល់ដំណើរនោះដូចម្តេច ជនទាំងឡាយណា ចូលទៅរកទ្រង់ហើយសួរយ៉ាងនេះថា អវយវៈតូចធំនៃរថនេះឈ្មោះអ្វី ទ្រង់បានត្រិះរិះហេតុនេះទុកក្នុងចិត្ត ស្រេចតាំងពីកាលមុនថា ជនទាំងឡាយណា នឹងចូលមករកអាត្មាអញហើយសួរយ៉ាងនេះ ជនទាំងឡាយនោះ លុះសួរអាត្មាអញយ៉ាងនេះហើយ អាត្មាអញនឹងដោះស្រាយយ៉ាងនេះឬ ឬថាដំណើរនុ៎ះ ក៏ស្រាប់តែប្រាកដដល់ទ្រង់ ដោយញាណកើតឡើងទាន់ពេលតែម្តង ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកចាំបាននូវរថ ជាអ្នកឈ្លាសក្នុងអវយវៈតូចធំនៃរថ អវយវៈតូចធំទាំងអស់របស់រថ ខ្ញុំព្រះអង្គស្គាល់ហើយ បានជាដំណើរនុ៎ះប្រាកដដល់ខ្ញុំព្រះអង្គ ដោយញាណកើតឡើងទាន់ពេលតែម្តង ។ ម្នាលរាជកុមារ ជនទាំងឡាយ ជាខត្តិយបណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតិបណ្ឌិតក្តី សមណបណ្ឌិតក្តី បានតាក់តែងបញ្ហា ហើយចូលមកសួរតថាគត ដំណើរនុ៎ះប្រាកដ ដល់តថាគត ដោយញាណកើតឡើងទាន់ពេលបាន ក៏យ៉ាងនោះដែរ ដំណើរ

នោះ ព្រោះហេតុដូចម្ដេច ម្នាលរាជកុមារ ព្រោះថាធម្មធាតុ (សព្វញ្ញុតញ្ញាណ) ដែលតថាគតចាក់ធ្លុះហើយ បានជាដំណើរនុ៎ះប្រាកដដល់តថាគត ដោយញាណកើតឡើងទាន់ពេលតែម្ដង ។

កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ អភយរាជកុមារ ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្ដែងបំភ្លឺហើយ ដោយអនេកបរិយាយយ៉ាងនេះ ដូចគេផ្ងាររបស់ដែលផ្កាប់ ឬដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាគេទ្រោលប្រទីបបំភ្លឺក្នុងទីងងឹត ឱ្យមនុស្សមានភ្នែកភ្លឺមើលឃើញរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះសូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង ភិក្ខុសង្ឃផង ជាទីពឹង ទីរលឹក សូមព្រះមានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសកដល់នូវសរណគមន៍ស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះតទៅ ។

☆☆☆



**កំណាព្យ**

## រក្សាព្រះត្រៃបិដក

សិក្សាបិដកមរតកព្រះ　　មានជ័យជម្នះឈ្នះមោហា
គឺជាកុសលផ្ដល់បញ្ញា　　ឆ្លងវដ្ដសង្សារឆ្ពោះនិព្វាន ។
ដូច្នេះយើងត្រូវថែរក្សា　　បិដកថ្លៃថ្លាជាធម្មទាន
ព្រះធម្មចេតិយប្រាជ្ញាញាណ　　សាស្ដានៅមានយើងត្រូវប្រឹង ។
រក្សាបិដកមានគុណក្រៃ　　លកលៃបែងចែកញែកឱ្យដឹង
ប្រាំពីរប្រការគិតជញ្ជឹង　　ល្អម៉ឺងប្រឹងថែខ្មែរមានធម៌ ។
មួយគឺរក្សាព្រះសាសនា　　មរតកអស្ចារ្យជាពុទ្ធពរ
ពាក្យពិតពាក្យពុទ្ធសុទ្ធបវរ　　ចេតិយព្រះធម៌ វិ.សុ.អ. ។
ពីរគឺរក្សាព្រះសាស្ដា　　វិន័យធម៌អាថ៌ចារទុកដាក់
ឋិតនៅជាគ្រូដ៏សមសក្ដិ　　ប្រចក្សធម្មាជាសាស្ដា ។
បីគឺរក្សាការងារសង្ឃ　　ទ្រទ្រង់តម្រង់ព្រះសាសនា
សង្គាយនាធម៌វិន័យណា　　ត្រាស់អស់វស្សាសែសិបប្រាំ ។
បួនគឺរក្សាគុណសម្បត្តិ　　នៃពុទ្ធបរិស័ទចាត់ជាឆ្នាំ
ព្រះធម៌វិន័យព្រះអង្គផ្ដាំ　　ឋិតច្រើនពាន់ឆ្នាំព្រោះបរិស័ទ ។

ប្រាំគឺរក្សាត្រៃសទ្ធម្ម　　បរិយត្តិនាំចំបដិបត្តិ
បដិវេធៈជាក់កម្ចាត់　　កិលេសបង់បាត់ស្ងាត់សន្ដាន ។
ប្រាំមួយរក្សាត្រៃរតនៈ　　ឋិតនៅប្រចក្សសរណឋាន
ព្រះពុទ្ធព្រះធម៌នាំសុខសាន្ត　　ព្រះសង្ឃកល្យាណមានវិន័យ ។
ប្រាំពីររក្សាត្រៃសិក្ខា　　សាសនាចារជាប់ដួងហឫទ័យ
សីលសមាធិធម៌ប្រពៃ　　ផុតភ័យអាស្រ័យដោយបញ្ញា ។
ព្រះត្រៃបិដកមានប្រវត្តិ　　រឿងរ៉ាវបានកត់ចារអក្ខរា
អរិយធម៌វប្បធម៌មនុស្សទេវតា　　បុព្វយ៉ាងណាចារឱ្យដឹង ។
បិដកជាច្បាប់ប្រាប់ភពត្រៃ　　អ្នកមាននិស្ស័យលៃលកប្រឹង
សិក្សាបដិបត្តិកម្ចាត់ខឹង　　ជញ្ជីងសម្ទឹងដឹងត្រៃលក្ខណ៍ ។
បិដកច្បាប់ដើមព្រះសាសនា　　បាលីអក្ខរាសាស្ដាជាក់
បដិបត្តិបូជាធានាមគ្គ　　កំណត់ត្រៃលក្ខណ៍លាត្រៃលោក ។
កសាងចេតិយបិដកខ្មែរ　　យើងនាំគ្នាហែព្រះមានជោគ
សាធុ! សាធុ! ផុតចាករោគ　　សាធុផុតលោក អនុមោទនា !

☆ ☆ ☆



## សរុបយោនិសោមនសិការទាំង ១០

ដូចដែលបានពោលមកទាំងប៉ុន្មាន ក៏ជាការបញ្ជាក់ឱ្យឃើញថា កិច្ចការរបស់យោនិសោមនសិការ ធ្វើការទាំងពីរផ្នែក គឺទាំងផ្នែកទទួលអារម្មណ៍អំពីខាងក្រៅ ទាំងផ្នែកគិតពិចារណាអារម្មណ៍ដែលសន្សំទុកជាខាងក្នុង ។

លក្ខណៈដែលគួរសង្កេតផ្នែកខាងការទទួលអារម្មណ៍ដោយយោនិសោមនសិការ គឺការទទួលគ្រាន់តែដើម្បីដឹងតាមសេចក្ដីពិតប៉ុណ្ណោះ និងដើម្បីរៀបចំដំណើរជីវិតឱ្យបានដល់នូវសេចក្ដីសុខពិតប្រាកដ ដូចដែលបានរៀបរាប់ពីខាងដើមនៃសៀវភៅហើយ ។

សូមជ្រាបថា ការហ្វឹកហាត់អប់រំនូវយោនិសោមនសិការនេះ គឺដើម្បីកាត់បន្ថយនូវការទទួលអារម្មណ៍ដែលនាំមកនូវបញ្ហាដល់ជីវិត ។ ហ្វឹកហាត់ទទួលអារម្មណ៍នាំឱ្យចម្រើននូវសតិបញ្ញាដើម្បីកែខៃដោះស្រាយបញ្ហា ឬដើម្បីរំលត់ទុក្ខ ។

ឯយោនិសោមនសិការផ្នែកគិតពិចារណាអារម្មណ៍ជាខាងក្នុងក៏មានន័យដូចគ្នាដែរ គឺគិតពិចារណាឱ្យបានជាការសិក្សាពោលគឺគិតឱ្យជាបទដ្ឋាននៃ **សីល សមាធិ** និង **បញ្ញា** ។

**ចប់**

## ទិភាគធានានៃការពិចារណា

រស់រិះរៀន មានគុណធម៌ ពណ៌សច្ចៈ
វិចារណៈ ឥស្សរភាព រៀបជីវិត
រស់ភ្លឺស្វាង សាងបញ្ញា គតិបណ្ឌិត
មិនប្រព្រឹត្ត ងងឹតខ្មៅ ខ្មៅអវិជ្ជា ។

ដោយភិក្ខុ **ព្រហ្ម មេត្តា**

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈

### ... ជាមនុស្ស ...

...ជាមនុស្ស រស់ក្នុងលោក រោគជីវិត
បើមិនគិត ពិតវង្វេង លេងតណ្ហា
ភាពអវិជ្ជា ជាចំណង ក្រងបញ្ហា
ទុក្ខខ្លោចផ្សា បារទំនាស់ ព្រោះចំណង់ ។
ចង់ម្តងនេះ រិះម្តងនោះ រុះរើចិត្ត
ចង់ជានិច្ច ជ្បិតលោភៈ ទាក់ចំណង់
រោគតណ្ហា សែនសាវា ប្រាថ្នាចង់
បាត់ស្មោះត្រង់ បង់គំនិត គិតលែងត្រូវ ។
លានចំណង់ ចង់មិនចប់ គ្រប់ដង្ហើម





ចង់បំផើម ផ្តើមជំពាក់ ព្រោះល្ងង់ខ្លៅ
រឿងជីវិត គិតមើលចុះ ឆ្លុះឱ្យជ្រៅ
វិលវល់នៅ ទៅមិនឆ្ងាយ ស្តាយតណ្ហា ។
បើមិនគិត ពិតជាលង់ ក្នុងជីវិត
រស់ងងឹត ឥតពន្លឺ ឈឺខ្លោចផ្សា
អវិជ្ជា ជាប្រភព ខ្ទប់វិចារណ៏
ភ្ញាស់តណ្ហា ឧបាទាន ស្រេកឃ្លានរស់។
មនុស្សច្រើនយ៉ាង អាងច្រើនបែប អែបច្រើនបទ
គួសកំណត់ កត់តាមធុន គុណទាបខ្ពស់
មនុស្សធម្មតា ស្រវាទ្រព្យ រាប់ស័ក្តិយស
ស្រេកសម្ដស្ស ស្រស់ខាងក្រៅ ឆៅវិចារណ៏ ។
ប្រាជ្ញបណ្ឌិត ពិតបណ្តុះ ផុសសច្ចៈ
មិនលោភៈ លាក់គំនុំ ផ្តុំហិង្សា
អប់រំចិត្ត គិតសីលទាន មានមេត្តា
ចិត្តស្ងប់ថា ត្រាមារយាទ ជាតិបណ្ឌិត ។
បណ្ឌិតស្នេហ៍ តែសច្ចៈ ស្ម័គ្រខន្តី
វាចាស្តី លៃប្រមាណ បានថ្លឹងគិត
មិនអួតអាង សាងអញឯង ក្លែងប្រឌិត

កាន់សុចរិត ឥតលំអៀង ផ្ទៀងទម្ងន់ ។
ជាតិបណ្ឌិត ចិត្តសច្ចៈ អហិង្សា
ដោះបញ្ហា មេត្តាជាប់ រាប់ជាគុណ
មិនអាងអួត ឆ្លួតជំនោរ ដោរលោភលន់
ចិត្តវែងធ្ងន់ គុណធម៌ពិត ឥតរវាត ។
វីពាលពិត ចិត្តអវិជ្ជា មារជំពាក់
ស្នេហ៍លោភៈ លាក់គំនុំ គុំប្រមាថ
មិនស្គាល់យល់ ផលពីហេតុ កើតព្យាបាទ
ចិត្តប្រមាទ ខាតគំនិត គិតបំភ្លៃ ។
រង្វាស់បី ស្ដីខាងលើ ធ្វើជាខ្នាត
វាស់មារយាទ លាតវិចារណ៍ ស្ពារនិស្ស័យ
រស់ជាមនុស្ស ទោះស្រេកឃ្លាន មានវិន័យ
រកតម្លៃ ថ្នៃជីវិត ពិតប្រាកដ ។
សីលជាស្ពាន ទានជាស្បៀង ទៀងជាខ្លឹម
ចិត្តតម្រឹម ត្រឹមតម្រង់ ត្រង់តាមបទ
ថ្លឹងបញ្ញា ករុណាចិត្ត គិតផ្ទៀងផ្ទាត់
គុណធម៌បទ កត់បំភ្លឺ ឮប្រចាំ ។

ដោយភិក្ខុ **ព្រហ្ម** **មេត្តា**



# ជីវិត

...ចាកឧទរ ទ្រដង្ហើម ផ្ដើមជីវិត
ជួបទុក្ខពិត ជីវិតមនុស្ស រស់ឈឺផ្សា
មិនស្រណុក សុខលាយទុក្ខ ផ្ទុកបញ្ហា
វដ្ដសំសារ តណ្ហាជ្រៅ (នាំ)ទៅងងឹត ។
ទុក្ខលាស់កើន ច្រើនស្រទាប់ ជាប់បំណុល
សុខខ្ទីបុល បំណុលរស់ ព្រោះជីវិត
ចង់មិនចង់ មិនស្ដាប់ចិត្ត ជ្បិតមិនគិត
ផ្ដាប់ជីវិត ស្និទ្ធតណ្ហា ទារមិនឈប់ ។
រស់មួយថ្ងៃ ខ្ទីជីវិត ទៅជិតស្លាប់
ជាបម្រាប់ ប្រាប់រំលឹក ព្រឹកថ្ងៃយប់
ថាការពិត ឥតមានពីរ ទីបញ្ចប់
ត្រូវចេះគ្រប់ ទប់ចិន្ដា ថ្លាជីវិត ។
ភពលោកិយ បុរីទុក្ខ សុខមានតិច
ខ្វះជានិច្ច ជ្បិតតណ្ហា វាប្រឌិត
បើចង់គ្រប់ ត្រូវឈប់ចង់ តម្រង់គិត
ឃើញជីវិត ពិតគ្រប់គ្នា ជាបញ្ហា ។

ទុក្ខដើរតាម ស្នាមតណ្ហា ឧបាទាន
នាំបំពាន គ្មានអៀនខ្មាស ប្រាសវិចារណ៍
បាត់ភ្លឺស្វាង ជោរអាងអួត ឆ្កួតតណ្ហា
ភ្លេចពិចារណ៍ ថាមរណៈ ស្ទាក់ជីវិត ។

ដោយភិក្ខុ **ព្រហ្ម មេត្តា**

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈

## ត្រៃគុណ

ស្គាល់ត្រៃគុណ នរជននោះ ឈ្មោះបណ្ឌិត
ព្រោះគំនិត គិតឃើញត្រូវ ផ្លូវកុសល
ស្គាល់ព្រះគុណ ទុនថ្លាថ្លៃ គ្មានអ្វីដល់
ស្គាល់ហេតុផល យល់ដឹងច្បាស់ ព្រះគុណបី ។

កើតមកបានរស់ព្រោះគុណឪម៉ែ លោកថ្នាក់ថ្នមថៃចិត្តស្នេហ៍ប្រណី
ធំឡើងទៅរៀនមានវិជ្ជាល្បី គុណគ្រូប្រុសស្រីគួរលៃគោរព ។
ដូនតាមីងមាដូចជាម៉ែឪ ប្រឹងប្រៀនប្រដៅចាកខ្លៅឧបទ្រព
គុណថ្លៃទាំងបីប្រពៃដូចម្លប់ ត្រជាក់ថ្ងៃយប់គឺម្លប់ព្រះធម៌ ។

ដោយភិក្ខុ **ព្រហ្ម មេត្តា**





## ឧស្សាហ៍គួរពិចារណា

អត្ថិភាពជីវិតអាចស្ថិតនៅបាន ក្រឹត្យក្រមវត្តមានកាយហើយនិងចិត្ត
តម្លៃនៃមនុស្សកម្ពស់ជីវិត វប្បធម៌គំនិតគិតសាងសង្គម ។
សង្គមល្អូតលាស់ព្រោះយុត្តិធម៌ បុគ្គលភាពល្អព្រោះការអប់រំ
សីលធម៌គុណធម៌គឺជាទ្រនំ សង្គមសុខសាន្តមានសន្តិភាព ។
មនុស្សគ្រប់អាត្មាប្រាថ្នាកិត្តិយស រស់រៀនរៀនរស់ខ្ពស់ដោយមារយាទ
មិនមែនដោយទ្រព្យរាប់ថ្លៃថោកទាប មានឥស្សរភាពរៀបរយជីវិត។

ដោយភិក្ខុ **ព្រហ្ម មេត្តា**

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈

## ជំងឺជីវិត

កើតភ្លាមស្រែកយំស្វាគមន៍ជីវិត បញ្ជាក់ការពិតជីវិតវេទនា
អវិជ្ជាបន្លំបំផើមវេទនា នាមរូបមាយាបំភាន់ការពិត ។
តណ្ហាជីវិតពិតដូចវាតា បោកបក់ចិន្តាបញ្ឆោតជីវិត
រស់ជាជំងឺឈឺចាប់មែនពិត ជំងឺជីវិតរួបរឹតឥតស្ងប់ ។
ខ្យល់ចូលខ្យល់ចេញប្រដេញដង្ហើម ប្តូរផ្លាស់ដណ្តើមផ្តើមហើយបញ្ចប់
រសជាតិជីវិតគិតឃើញធុញថប់ ពីដើមដល់ចប់ផ្គាប់ចិត្តមាយា ។
មើលឃើញការពិតគួរគិតពិចារណ៍ **អនិច្ចំ អនត្តា** មរណាវេលា
រៀនរស់ត្រឹមត្រូវតាមផ្លូវមជ្ឈិមា សាងសីលសទ្ធាត្រៀមលាជីវិត ។

ដោយភិក្ខុ **ព្រហ្ម មេត្តា**

## **មរតកគតិបណ្ឌិត**

ឱកូនប្រុសស្រីសំដីឪពុក ចាំជាទំនុកទុកជាគំនិត
មរតកសច្ចៈគតិបណ្ឌិត រស់រៀបជីវិតរៀនគិតប្រមាណ ។
ចំណេះវិជ្ជារួមគ្នាសុខភាព ចរិយាមារយាទរៀបយសថ្កើងថ្កាន
គុណធម៌ជាម៉ែត្រវាស់មនុស្សគ្រប់ប្រាណ សំអាតសន្តានស្នាមដានអវិជ្ជា ។
រស់នៅត្រូវស្គាល់ឫសគល់តម្លៃ នាទីយប់ថ្ងៃនៃពេលវេលា
កុំរស់ខ្ជះខ្ជាយរាយមាយខ្ជីខ្ជា ព្រោះពេលវេលាគឺជាជីវិត ។
រស់កុំប្រមាទសំអាតចិន្តា បើពុលតណ្ហានេត្រាងងឹត
រស់មានសតិគតិបណ្ឌិត រៀបចំជីវិតប្រព្រឹត្តកុសល ។
រស់រៀនរៀនរស់ជាមនុស្សឧត្តម រស់មានក្រឹត្យក្រមមិននាំកង្វល់
បញ្ញាភ្លឺថ្លាវិចារណ៍ហេតុផល រស់សាងកុសលបន្សល់គុណធម៌ ។

ដោយភិក្ខុ **ព្រហ្ម មេត្តា**

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈

## **សច្ចធម៌**

ឱពេលវេលាប្រៀបជាអាជ្ញា ឥតខ្លាចអ្នកណាតវ៉ាឆ្លងឆ្លើយ
បញ្ជាថ្ងៃខែគ្មានប្រែប្រួលឡើយ ពេលមកដល់ហើយគ្មានឆ្លើយប្រកែក។
ព្រឹកល្ងាចថ្ងៃយប់បង្គ្រប់ខែឆ្នាំ វិលជាប្រចាំគ្មានចាំថ្ងៃស្អែក
ដំណើរទៅមុខរុលរុកមុជជ្រែក ទម្លុះជើងមេឃជ្រែកភពផែនដី ។
ដំណើរដដែលតែហែលឥតឈប់ ថ្ងៃយប់សង្គ្រប់ខ្ទប់ចាប់លោកិយ
បន្សឹកពង្រេចជីវិតរាល់ថ្ងៃ ភ្លើងខ្យល់ទឹកដីកម្មឹធម្មជាតិ ។





ជីវិតឃ្លេងឃ្លោងពឹងពោងផលកម្ម ថ្ងៃយប់ខែឆ្នាំចាំឃ្លាំឥតឃ្លាត
បើរស់ប្រមាទខាតបង់មារយាទ ផលកម្មជ្រែកជ្រៀតបៀតបៀនវាសនា។
ហេតុនៃផលកម្មចាំសច្ចៈរះ ព្រះពុទ្ធទ្រង់ត្រាស់តម្រាស់ថ្លៃថ្លា
**រូបំ ទុក្ខំ អនិច្ចំ អនត្តា** សង្ខារវិញ្ញាណព្រោះមានអវិជ្ជា។
តណ្ហាឧបាទានស្រេកឃ្លានគ្មានឈប់ ព្រោះមានប្រភពនាមរូបមាយា
សឡាយតនៈបញ្ចក្ខន្ធទ្វារ ផស្សៈវេទនាជរាទុក្ខភ័យ ។
ការពិតតែមួយជួយប្រាប់គំនិត រំលឹកជីវិតគិតស្វែងរកន័យ
រស់ឃើញសច្ចៈមិនខ្វាក់ស្មារតី តណ្ហាអប្រិយនាំយើងវង្វេង ។
សតិជាថ្នាំចាំជួយរំលឹក ដាស់តឿនល្ងាចព្រឹកនឹកថាមិនទៀង
រស់នៅញាប់ញ័រប្រដូចចង្កៀង ធាតុប្រេងស្ងួតរីងចង្កៀងរលត់ ។
ភ្លើងខ្យល់ទឹកដីចំណីទាំងបួន នៅពេលមាំមួនខ្លួននៅធំធាត់
ធាតុបួនរង្គោះរលស់ប្រុងព្រាត់ ព្រមានប្រាយប្រាប់ឆាប់រកធម៌អាថ៌។
បើអ្នកខ្លាចស្លាប់ប្រញាប់សាងល្អ ស្វែងរកគុណធម៌ស្មោះសរចិន្តា
បន្សុទ្ធជីវិតបន្សាបតណ្ហា អប់រំបញ្ញាភ្លឺថ្លាគំនិត ។
កុំរស់អត្តទត្ថបុគ្គល មិនយល់ហេតុផលមិនស្គាល់ការពិត
កុំលោភលន់ហួសខឹងខុសងងឹត តណ្ហារួបរឹតព្រោះជ្សិតអវិជ្ជា ។
ជីវិតមិនទៀងតែទៀងមរណៈ រស់ស្គាល់សច្ចៈខ្ជាក់ចោលមាយា
តណ្ហាអ្នកភ្វាស់ទំនាស់អវិជ្ជា សាងសីលសទ្ធាផ្ចាញ់មារក្នុងចិត្ត។

ដោយភិក្ខុ **ព្រហ្ម មេត្តា**

## ដំណើរធម្មយាត្រាទៅស្រីលង្កា

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈

ស្រុកស្រីលង្កាសម្បូរបុណ្យ ទឹកដីអរហន្តលោកគង់នៅ
ព្រះពុទ្ធក៏ទ្រង់ធ្លាប់យាងទៅ ភ្នំខ្ពស់ជ្រោះជ្រៅត្រជាក់ចិត្ត ។
តែទីដែលគួរឱ្យជ្រះថ្លា គឺព្រះសាស្តាស្តេចអាណិត
បន្សល់ព្រះធាតុថ្លៃពិតៗ ឱ្យពុទ្ធបរិស័ទទាំងប្រុសស្រី ។
បានថ្វាយបង្គំធាតុពីរនាឡិ ក្នុងសុវណ្ណមាលិកចេតិយ
បង្កើតសទ្ធាទាំងយប់ថ្ងៃ ដោយឧបនិស្ស័យផ្សំពីមុន ។
